ហ្វូណាន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
富南小額信貸公司 FUNAN Microfinance Plc.
បុត្រសម្ព័ន្ធរបស់ធនាគារ CPBank

# របាយការណ៍ប្រចាំឆ្នាំ ២០២០



# ស្កេន QRCODE ដើម្បីស្នើសុំឥណទាន!













# មាតិកា


## ១ ប្រវត្តិសាជីវកម្ម

- ប្រវត្តិរបស់គ្រឹះស្ថាន
- ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ
- អភិបាលកិច្ចសាជីវកម្ម
- ការគ្រប់គ្រងហានិភ័យ និង ការអនុលោមតាមច្បាប់
- ក្រមសីលធម៌វិជ្ជាជីវៈ

## ២ ថ្នាក់ដឹកនាំ

- រចនាសម្ព័ន្ធរបស់គ្រឹះស្ថាន
- ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល
- ចំណាប់អារម្មណ៍របស់ប្រធាននាយកប្រតិបត្តិ
- សមាជិក និងប្រវត្តិក្រុមប្រឹក្សាភិបាល
- គណៈគ្រប់គ្រង

## ៣ របាយការណ៍លទ្ធផល

- របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល
- របាយការណ៍របស់សវនករឯករាជ្យ
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- របាយការណ៍លទ្ធផលលម្អិត
- របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
- របាយការណ៍លំហូរទឹកប្រាក់
- កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

## ៤ សកម្មភាពទំនួលខុសត្រូវសង្គម

- ការរួមចំណែកក្នុងទំនួលខុសត្រូវសង្គម
- ការទទួលបានវ៉ាក់សាំង ( កូវីដ១៩ ) នៃគណៈគ្រប់គ្រង និងបុគ្គលិកហ្វូណន
- សកម្មភាព និងសុខមាលភាពបុគ្គលិក

## ៥ សាខាឆ្នើម និងតំបន់ប្រតិបត្តិការ

- សាខាឆ្នើម និងបុគ្គលិកនាំមុខ
- ទីតាំងការិយាល័យ និងតំបន់ប្រតិបត្តិការ



# ព័ត៌មានអំពីគ្រឹះស្ថាន

- ប្រវត្តិរបស់គ្រឹះស្ថាន
- ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ
- អភិបាលកិច្ចសាជីវកម្ម
- ការគ្រប់គ្រងហានិភ័យ និង ការអនុលោមតាមច្បាប់
- ក្រមសីលធម៌វិជ្ជាជីវៈ

# ប្រវត្តិរបស់គ្រឹះស្ថាន




## ឆ្នាំ២០១១-ទទួលបានអាជ្ញាប័ណ្ណជាអង្គការក្រៅរដ្ឋាភិបាល

អង្គការក្រៅរដ្ឋាភិបាលដែលហៅថា សមាគមន៍អភិវឌ្ឍន៍ប្រជាជនកម្ពុជា បង្កើតឡើងនៅក្នុងខែកក្កដា ឆ្នាំ២០១១ និងបានចុះបញ្ជីស្របច្បាប់ជាមួយក្រសួងមហាផ្ទៃ ក្នុងការផ្តល់ប្រាក់កម្ចីខ្នាតតូចទៅដល់ជនក្រីក្រសម្រាប់អភិវឌ្ឍន៍សហគមន៍របស់ពួកគេ។ នៅចុងឆ្នាំ២០១៤ សមាគមន៍អភិវឌ្ឍន៍ប្រជាជនកម្ពុជា មានសាខាចំនួន ៤៩សាខា បុគ្គលិកចំនួន ៨២១នាក់ អតិថិជនច្រើនជាង ៣០,០០០នាក់ និងសម្បត្តុលឥណទាន ៤លានដុល្លារអាមេរិក។

## ឆ្នាំ២០១៥-ការវិវត្តន៍ទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ សមាគមន៍អភិវឌ្ឍន៍ប្រជាជនកម្ពុជាបានទទួលបានអាជ្ញាប័ណ្ណពី ធនាគាជាតិ នៃកម្ពុជា ដែលមានឈ្មោះថា ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី និងបានចុះបញ្ជីស្របច្បាប់ជាមួយអាជ្ញាធររដ្ឋាភិបាលផ្សេងទៀតដូចជា ក្រសួងពាណិជ្ជកម្ម នៅក្នុងខែមិថុនា ឆ្នាំ២០១៥ និងអគ្គនាយកដ្ឋានពន្ធដារ នៅខែកក្កដា ឆ្នាំ២០១៥។ រាល់ទ្រព្យសម្បត្តិ និងបំណុលទាំងអស់របស់សមាគមន៍អភិវឌ្ឍន៍ប្រជាជនកម្ពុជា ត្រូវបានផ្ទេរ និងទទួលបានការអនុម័តជាផ្លូវការពី ធនាគាជាតិ នៃកម្ពុជា នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥។ នៅក្នុងឆ្នាំ២០១៦ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានសាខាចំនួន ៤៩សាខា បុគ្គលិកចំនួន ៧៣៣នាក់ និងអតិថិជនច្រើនជាង ៣០,៣១១ នាក់ និងសម្បត្តុលឥណទាន ១០លានដុល្លារអាមេរិក។

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ធនាគារប្រៃសណីយ៍កម្ពុជា ក.អ បានចុះកិច្ចព្រមព្រៀងទិញភាគហ៊ុន ១០០%របស់គ្រឹះស្ថាន ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។

## ឆ្នាំ២០១៧-ការវិវត្តន៍អាជីវកម្ម

គ្រឹះស្ថានទទួលបានការអនុម័តស្តីពីការផ្លាស់ប្តូរភាគទុនិកពី ធនាគារជាតិ នៃកម្ពុជា នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ និងការអនុម័តពី ក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៧។ នៅថ្ងៃទី១២ ខែ ឧសភា ឆ្នាំ២០១៧ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានរៀបចំព្រឹត្តិការណ៍ផ្ទេរភាគហ៊ុនជាផ្លូវការមួយដែលមានការចូលរួមពីភាគទុននិក ក៏ដូចជា អាជ្ញាធរ បុគ្គលិក រួមទាំងថ្នាក់គ្រប់គ្រងជាតិ និងអន្តរជាតិចូលរួមផងដែរ។ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានផ្លាស់ប្តូរទីផ្សារគោលដៅថ្មី ដើម្បីបំពេញទីផ្សារគោលដៅរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ដែលជាក្រុមហ៊ុនមេសម្ព័ន្ធផ្តោតលើគោលដៅទីផ្សារភាគធំនៃកម្រិតចំណូលរបស់ប្រជាជន (Mass Market)។

ដើម្បីកាត់បន្ថយការប្រមូលឥណទានតាមតំបន់ប្រតិបត្តិការ ដោយមន្ត្រីឥណទាន ដែលពេលនោះអតិថិជនស្ទើរទាំងអស់ធ្វើការបង់ប្រាក់តាមតំបន់ប្រតិបត្តិការ។ ហ្វូណន បានចុះកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន ផ្តល់សេវាទូរទាត់ គឺក្រុមហ៊ុនវីង ក្នុងខែមិថុនា ឆ្នាំ២០១៧ ហើយអនុញ្ញាតិអោយអតិថិជនធ្វើការទូរទាត់តាមភ្នាក់ងារវីងដែលនៅជិតពួកគេ បន្ថែមលើជម្រើស នៃការបង់ឥណទាននៅការិយាល័យ។ នៅខែធ្នូ ឆ្នាំ២០១៧ ហ្វូណន បានចុះកិច្ចព្រមព្រៀងបន្ថែមជាមួយក្រុមហ៊ុនផ្តល់សេវាទូរទាត់ផ្សេងទៀត គឺក្រុមហ៊ុនតារាផេរ។

## ឆ្នាំ២០១៨/ កំណើន និងការអភិវឌ្ឍន៍អាជីវកម្ម

ក្នុងខែមិថុនា ឆ្នាំ២០១៨ យើងបានចាប់ផ្តើមអនុវត្តលើការបញ្ចេញឥណទានតាមភ្នាក់ងារ តារ៉ាផេ (ក្រុមហ៊ុនផ្តល់សេវាទូទាត់) ទៅតាមតំបន់ប្រតិបត្តិការគ្មានសាខា ហើយបន្ទាប់មកធ្វើការពង្រីកការអនុវត្តន៍ បន្ថែមទៀតនៅគ្រប់តំបន់ប្រតិបត្តិការដើម្បីជាជម្រើសបន្ថែមដល់អតិថិជន។ នៅក្នុងឆ្នាំដដែលនេះ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានពង្រីកតំបន់ប្រតិបត្តិការគ្មានសាខា ចំនួន២កន្លែង។

ខែកក្កដា ឆ្នាំ២០១៨ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានចុះកិច្ច សហប្រតិបត្តិការ អាជីវកម្ម ជាមួយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតសុវណ្ណភូមិឡាយ លើការផ្តល់ការធានារ៉ាប់រងជីវិតជូនអតិថិជន។

និងបានបន្តសហប្រតិបត្តិការ អាជីវកម្មជាមួយក្រុមហ៊ុន តារ៉ាផេរ ធនាគារប្រៃសណីយ៍កម្ពុជា និងតាមបណ្តាហាងដៃគូរលក់សម្ភារៈអេឡិចត្រូនិចប្រើប្រាស់ក្នុងផ្ទះ ក្នុងកិច្ចប្រតិបត្តិការណែនាំកម្ចី។

ក្នុងឆ្នាំនេះផងដែរ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានសាខាចំនួន ៥១ បុគ្គលិកចំនួន ៦៤៦នាក់ អតិថិជនចំនួន ១៩,៨៥៦នាក់ និងសម្បត្តុលឥណទានសរុបកើនដល់ ៤៧លានដុល្លារអាមេរិក។

## ឆ្នាំ២០២០-ការទទួលយកនូវទម្រង់បច្ចេកវិទ្យាក្នុងតំណើការអាជីវកម្ម

ការផ្ទុះឡើងនៃជម្ងឺរាតត្បាតជាសកល (ជម្ងឺកូវីដ១៩) តាមរយៈការអនុវត្តន៍គម្លាតសង្គម និងការអនុវត្តន៍របៀបរស់នៅថ្មី ធ្វើឱ្យមនុស្សចាប់ផ្តើមប្រើប្រាស់ទម្រង់នៃប្រព័ន្ធបច្ចេកវិទ្យាក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកក្នុងការរស់នៅប្រចាំថ្ងៃ។ ដូច្នោះក្នុងឆ្នាំ២០២០នេះ គ្រឹះស្ថានបាននឹងកំពុង ធ្វើការអភិវឌ្ឍន៍ប្រព័ន្ធដំណើរការប្រាក់កម្ចី ហើយគ្រឹះស្ថាននឹងខិតខំឱ្យប្រព័ន្ធនេះដាក់ដំណើរការក្នុងឆ្នាំ២០២១។ ក្នុងឆ្នាំ២០២០ ហ្វូណនបានធ្វើការផ្លាស់ប្តូរពណ៌នៃអត្តសញ្ញាណរបស់ខ្លួនឱ្យស្របតាមអត្តសញ្ញាណរបស់ក្រុមហ៊ុនមេគឺធនាគារប្រៃសណីយ៍កម្ពុជា ក.អ។

ហ្វូណន មានការិយាល័យប្រតិបត្តិការចំនួន៥១សាខា តំបន់ប្រតិបត្តិការចំនុះសាខាចំនួន៥កន្លែង(Branchless areas) មានបុគ្គលិកសរុបចំនួន៥៤៧នាក់ និងផលប័ត្រឥណទានសរុប៥៦,៨លានដុល្លារអាមេរិក។

# ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ

## ទស្សនវិស័យ

ជាស្ថាប័នមីក្រូហិរញ្ញវត្ថុឈានមុខគេ ជួយលើកកម្ពស់ជីវភាពរស់នៅ និងភាពជោគជ័យដល់ពលរដ្ឋកម្ពុជា។

## បេសកកម្ម

ផ្តល់នូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុ ប្រកបដោយភាពច្នៃប្រឌិតដែលមាន លក្ខណៈ សាមញ្ញ ងាយស្រួល សេវារហ័ស និងប្រតិបត្តិតាមច្បាប់ ប្បញ្ញត្តិនានា។

## គុណតម្លៃ

1. ទំនុកចិត្ត
2. សហគ្រិនភាព
3. គណនេយ្យភាព
4. សីលធម៌

1. ជាដៃគូផ្តល់ទំនុកចិត្តដល់ភាពជោគជ័យរបស់ភាគីពាក់ព័ន្ធ។ យើងមានសេចក្តីជឿជាក់ខ្ពស់ ចំពោះបុគ្គលិកគ្រប់រូបដើម្បីរួមចំណែកក្នុងការ សម្រេចគោលដៅរួមជាមួយហ្វូណន។
2. យើងជាម្ចាស់នៃសកម្មភាពដោយភាពឧស្សាហ៍ ព្យាយាម និងភាពស្មោះត្រង់របស់យើង។
3. យើងលើកទឹកចិត្តដល់និយោជិតគ្រប់រូបឱ្យមានការចូលរួម ការផ្តួចផ្តើមគំនិត និងតម្លាភាពដើម្បីបន្តកែលម្អអភិវឌ្ឍផលិតផលសេវាកម្មនិងដំណើរការប្រតិបត្តិការរបស់យើង។
4. យើងមានទំនួលខុសត្រូវក្នុងសង្គមយ៉ាងម៉ឺងម៉ាត់។ យើងប្រកាន់ភ្ជាប់ខ្ពស់បំផុតនូវសីលធម៌សង្គម និងបទដ្ឋានក្រមសីលធម៌វិជ្ជាជីវៈចំពោះគ្រប់ទង្វើទាំងក្នុង និងខាងក្រៅស្ថាប័ន។

ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃ

៖៖តិចិនជោគជ័យ

**ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី** បង្កើតនូវអភិបាលកិច្ចសាជីវកម្មឡើងដើម្បីកៀងគរទំនុកចិត្តខ្ពស់ពីភាគីពាក់ព័ន្ធ រួមមាន ដៃគូវិនិយោគ អ្នកផ្តត់ផ្គង់ម្ចាស់បំណុល អតិថិជន និង ធ្វើឱ្យមានអនុលោមភាពតាមបទប្បញ្ញត្តិដែលចែងក្នុងប្រកាសលេខធ៧-០៨-២១១ ប្រក,ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីអំពីអភិបាលកិច្ចគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ មិនត្រឹមតែប៉ុណ្ណោះ អភិបាលកិច្ចសាជីវកម្មល្អធានាបាននូវនិរន្តរភាពប្រតិបត្តិការ គ្រប់គ្រង និងដោះស្រាយហានិភ័យអាជីវកម្មចម្បងៗបានទាន់ពេលវេលា។

ការបង្កើតនូវរចនាសម្ព័ន្ធអភិបាលកិច្ចសាជីវកម្មគឺរួមបញ្ចូលធាតុសំខាន់ៗដូចជា៖ (i) បង្កើតឱ្យមានឯករាជ្យភាពនៃមុខងារសវនករផ្ទៃក្នុងដោយត្រូវរាយការណ៍ផ្ទាល់ទៅកាន់ប្រធានគណៈកម្មាធិការសវនកម្មផ្ទៃក្នុងកម្រិតក្រុមប្រឹក្សាភិបាល ហើយក្រុមសវនករផ្ទៃក្នុង ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល និងទទួលស្គាល់ដោយធនាគារជាតិ នៃកម្ពុជា (ii) សវនករឯករាជ្យខាងក្រៅត្រូវបានតែងតាំងដោយ BOD និងបានទទួលបានការអនុម័តការពី (NBC) លើការតែងតាំងនេះ។ ហើយផ្នែកសវនៈកម្មទាំងពីរនេះត្រូវបានដាក់អោយរាយការណ៍ទៅ BOD ដោយផ្ទាល់។ (iii) ផ្នែកគ្រប់គ្រង ហានិភ័យត្រូវរាយការណ៍ជាប្រចាំទៅ គណៈកម្មាធិការគ្រប់គ្រងហានិភ័យក្នុងកម្រិតក្រុមប្រឹក្សាភិបាល (iv) បង្កើតឱ្យមានគណៈកម្មាធិការប្រតិបត្តិ ក្នុងជួរគណៈគ្រប់គ្រងដើម្បីធានានូវប្រសិទ្ធភាព ក្នុងការអនុវត្តន៍កិច្ចការប្រតិបត្តិការប្រចាំ (v) បង្កើតឱ្យមានក្រមសីលធម៌វិជ្ជាជីវៈក្នុងការអនុវត្តន៍ការងារ និងគោលនយោបាយនិវេទនកម្ម (vi) គណៈកម្មាការកម្រិតក្រុមប្រឹក្សាភិបាលមានតួនាទីត្រួតពិនិត្យ និងសម្រេចនូវកិច្ចការសំខាន់ៗដូចជាផែនការថវិកាប្រចាំឆ្នាំ ផែនការធនធានមនុស្ស ផែនការសវនកម្ម គោលនយោបាយឥណទាន ។ល។

ជាមួយនឹងការអនុវត្តន៍លើផែនការ និងគោលនយោបាយ ទាំងនេះគឺជាកាតព្វកិច្ចរបស់គណៈគ្រប់គ្រង។ តួនាទីរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានកំណត់តាមខ្នាតគំរូអន្តរជាតិដោយអនុលោមទៅតាមក្របខ័ណ្ឌ ច្បាប់ និងបទប្បញ្ញត្តិប្រទេស និងតំបន់។ រចនាសម្ព័ន្ធអភិបាលកិច្ចបច្ចុប្បន្នត្រូវបានរួមបញ្ចូលទាំងក្រុមប្រឹក្សាភិបាល អនុគណៈកម្មាធិការក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ។

## គណៈកម្មាធិការកម្រិតក្រុមប្រឹក្សាភិបាល

ដោយយល់ឃើញថាក្រុមប្រឹក្សាភិបាលដែលមានបទពិសោធន៍ច្រើនឆ្នាំក្នុងវិស័យហិរញ្ញវត្ថុ មានភាពចាំបាច់ក្នុង ការធានាបាននូវបទដ្ឋានអភិបាលកិច្ចរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលរបស់ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ត្រូវបានតែងតាំង និងទទួលស្គាល់ដោយ ធនាគារជាតិនៃកម្ពុជាដែលមាន សមាជិកចំនួន ៥រូប ក្នុងនោះសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យមានចំនួន ២រូប។ ក្រុមប្រឹក្សាភិបាល ហ្វូណនមីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានការទទួលខុស ត្រូវលើការប្រតិបត្តិតាមនូវអភិបាល កិច្ចសាជីវកម្ម ត្រួតពិនិត្យលទ្ធផល និងការអនុវត្តន៍ការងារ របស់គណៈគ្រប់គ្រង ហើយធានាការពារនូវគុណតម្លៃ រយៈពេលវែងរបស់ភាគទុនិក ដោយមានការចូលរួមយ៉ាងសកម្ម ពីសមាជិកក្រុម ប្រឹក្សាភិបាលឯករាជ្យ ។ ដើម្បីយកចិត្តទុកដាក់លើមុខងារសំខាន់ៗរបស់ក្រុម ហ៊ុន ក្រុមប្រឹក្សាភិបាល របស់ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតឱ្យមាន គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ចំនួន ០៣ ជួយ ដល់ក្រុមប្រឹក្សាភិបាលក្នុងការផ្តោតលើបញ្ហាជាក់លាក់ បំពេញតួនាទី និងភារកិច្ចដែលបានធ្វើប្រតិភូកម្ម ដោយក្រុមប្រឹក្សាភិបាល រាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាលលើការសម្រេចចិត្ត និងធ្វើការតាមដាន និងអនុវត្តផែនការសកម្មភាព របស់គណៈគ្រប់គ្រងហើយផ្តល់អនុសាសន៍ចាំបាច់ផ្សេងៗដល់គណៈគ្រប់គ្រង។

គណៈកម្មាធិការទាំងនោះរួមមាន៖

**១. គណៈកម្មាធិការសវនកម្ម**
**២. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ**
**៣. គណៈកម្មាធិការតម្លៃការ និងតែងតាំង**

### ១. គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការនេះ ត្រូវបានបង្កើតក្រោមគោលការណ៍អភិបាលកិច្ចសាជីវកម្ម និងត្រូវបានផ្តល់ឱ្យនូវអំណាចពិសេសចាំបាច់ដូចបានកំណត់ក្នុងតួនាទី និង ភារកិច្ច របស់ គណៈកម្មាធិការទាំងនេះដើម្បីសម្រេចបាននូវគោលដៅរបស់ខ្លួន។ អំណាច តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម មានភាពទូលំទូលាយ និងគោរពតាមលក្ខខណ្ឌដូចបាន កំណត់ក្នុងមាត្រា១៣១នៃច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ក៏ដូចជាមាត្រា៨នៃធនាគារជាតិតាមប្រកាស ធ៧-០៨-២១១ របស់ប្រទេសកម្ពុជា លើអភិបាលកិច្ចក្នុងធនាគារ និងស្ថាប័នហិរញ្ញវត្ថុ។ ប្រធានគណៈកម្មាធិការនេះគឺជាសមាជិកឯករាជ្យ ហើយក៏ត្រូវឆ្លើយសំណួរទាំងអស់ពីភាគទុនិកនៅក្នុងកិច្ចប្រជុំទូទៅប្រចាំឆ្នាំ។

#### សមាជិកភាព

គណៈកម្មាធិការមានសមាជិក៣រូប។

ប្រធាននៃគណៈកម្មាធិការគឺជាសមាជិក ក្រុមប្រឹក្សាភិបាលដែលមិនប្រតិបត្តិ ហើយជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ នៅក្នុងក្រុមហ៊ុន។ សមាជិកទាំងអស់នៃគណៈកម្មាធិការមានឯករាជ្យភាពក្នុងក្រុមហ៊ុន។

- **លោក Giang Sovann** — **ប្រធាន**
- **លោក Toe Meng Poh Philip** — **សមាជិក**
- **លោក តូច ចៅចេក** — **សមាជិក**

#### កិច្ចប្រជុំ

គណៈកម្មាធិការនេះជួបជុំគ្នាជាញឹកញាប់ទៅតាមការស្នើសុំប៉ុន្តែមិនត្រូវតិចជាង ៤ដងក្នុងមួយឆ្នាំនោះទេ។

### ២. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

គណៈកម្មាធិការ នេះមានសមាជិក៣រូប ដែលត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាភិបាល។ ប្រធានគណៈកម្មាធិការនេះគឺជាបុគ្គលិកដែលមានបទពិសោធន៍ និងជំនាញ ក្នុងការគ្រប់គ្រងហានិភ័យ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ គណៈកម្មាធិការនេះមានភារកិច្ចសំខាន់ៗដូចមានចែងក្នុងតួនាទី និង ភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និង អនុវត្តភារកិច្ចផ្សេងៗទៀត តាមការចាត់តាំង របស់ក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការនេះមានភារកិច្ចត្រួតពិនិត្យ លើការអនុវត្តន៍នៃគោលនយោបាយគ្រប់គ្រងហានិភ័យដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការនេះ ដើរតួនាទីយ៉ាងសំខាន់ផងដែរក្នុងការផ្តល់ប្រឹក្សាលើកិច្ចការពាក់ព័ន្ធនឹងហានិភ័យ របស់ក្រុមហ៊ុនស្របតាមស្តង់ដារអន្តរជាតិ។





#### សមាជិកភាព

ក្រុមប្រឹក្សាភិបាលជាអ្នកជ្រើសតាំង ប្រធានគណៈកម្មាធិការគ្រប់ គ្រង ហានិភ័យដែលមានអាណត្តិរយៈពេល៣ឆ្នាំ សម្រាប់តំណែងនេះរាប់ចាប់ពីកាលបរិច្ឆេទនៃការជ្រើសតាំង។ គណៈកម្មាធិការគ្រប់គ្រងហានិភ័យគឺជាសមាជិកក្រុមប្រឹក្សាភិបាលដែលមិនប្រតិបត្តិ និងមានឯករាជ្យភាព ពីគណៈគ្រប់គ្រង មិនជាប់ពាក់ព័ន្ធនឹងមុខជំនួញណាមួយ ឬទំនាក់ទំនងផ្សេងៗទៀត ដែលអាចជ្រៀតជ្រែកលើការវិនិច្ឆ័យឯករាជ្យរបស់ពួកគាត់។

#### សមាជិកភាព

- **លោក Toe Meng Poh Philip** — **ប្រធាន**
- **លោក Giang Sovann** — **សមាជិក**
- **លោក តូច ចៅចេក** — **សមាជិក**

#### កិច្ចប្រជុំ

កិច្ចប្រជុំនឹងត្រូវបានប្រារព្ធធ្វើឡើង នៅពេលដែលសមរម្យ ប៉ុន្តែយ៉ាងហោចណាស់ ៤ដងក្នុងមួយឆ្នាំ។ ប្រធានគណៈ កម្មាធិការគ្រប់គ្រងហានិភ័យនេះអាចកោះប្រជុំបន្ថែមទៀតប្រសិនបើមានករណីចាំបាច់។

### ៣. គណៈកម្មាធិការតម្លៃការ និងតែងតាំង

គណៈកម្មាធិការ នេះ ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលស្របតាមតម្រូវការអភិបាលកិច្ចដើម្បីផ្តល់នូវការអនុវត្តន៍ដ៏ល្អបំផុតសម្រាប់គ្រឹះស្ថាន។ ប្រធានគណៈកម្មាធិការគឺជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ។ គណៈកម្មាធិការ នេះទទួលខុសត្រូវ អនុវត្តគោលនយោបាយតម្លៃការ ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងទិសដៅរយៈពេលវែង និងតម្លៃសាជីវកម្មរបស់ក្រុមហ៊ុន។ គណៈកម្មាធិការនេះ ផ្តល់អនុសាសន៍ខ្លះៗ លើនីតិវិធីដើម្បីជ្រើសរើស និងបំពេញបន្ថែមនូវសមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យដែលមានសក្តានុពលដើម្បីក្លាយជាសមាជិកគណៈកម្មាធិការនេះ។ គណៈកម្មាធិការតម្លៃការ និងតែងតាំងនឹងអនុម័តជ្រើសតាំងគណៈគ្រប់គ្រងជាន់ខ្ពស់ផងដែរ។

គណៈកម្មាធិការនេះត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាលដែលមានសមាជិកមិនតិចជាង៣រូបនិងលេខាធិការនៃគណៈកម្មាធិការម្នាក់។ ក្រុមប្រឹក្សាភិបាលមានអំណាចគ្រប់ពេលក្នុងការដក សមាជិកណាមួយចេញពីគណៈកម្មាធិការនេះ និងតែងតាំងសមាជិកថ្មី ដើម្បីបំពេញកន្លែងទំនេរក្រោយពីការដកចេញនោះ។

#### សមាជិកភាព

- **លោក Neo Poh Kiat** — **ប្រធាន**
- **លោក Toe Meng Poh Philip** — **សមាជិក**
- **លោក តូច ចៅចេក** — **សមាជិក**

#### កិច្ចប្រជុំ

ការប្រជុំនឹងត្រូវបានប្រារព្ធឡើង នៅពេលដែលសមរម្យ។ ប៉ុន្តែយ៉ាងហោចណាស់ ៤ដងក្នុងមួយឆ្នាំ។ ប្រធានគណៈកម្មាធិការនេះអាចរៀបចំឱ្យមានការប្រជុំបន្ថែមទៀតប្រសិនបើចាំបាច់។

## គណៈកម្មាធិការនាយក

គណៈកម្មាធិការគ្រប់គ្រងទាំង០៨នឹងជួយដល់ប្រធាននាយកប្រតិបត្តិក្នុងការផ្តោតទៅលើបញ្ហាជាក់លាក់តាមរយៈការត្រួតពិនិត្យ និងតាមដានដំណើរការប្រតិបត្តិការប្រចាំថ្ងៃរបស់គ្រឹះស្ថាន ហើយថែមទាំងធ្វើកិច្ចការផ្សេងៗទៀតតាមការចាត់តែងដោយគណៈកម្មាធិការកម្រិតក្រុមប្រឹក្សាភិបាល និងប្រធាននាយកប្រតិបត្តិ ហើយរាយការណ៍ជូនប្រធាននាយកប្រតិបត្តិដើម្បីធ្វើសេចក្តីសម្រេចចិត្ត និងដោះស្រាយនូវបញ្ហាផ្សេងៗត្រួតពិនិត្យលទ្ធផលការងាររបស់ក្រុមហ៊ុន និងផ្តល់អនុសាសន៍ចាំបាច់មួយចំនួនដើម្បីដោះស្រាយនូវប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ។

គណៈកម្មាធិការនាយកទាំង០៨ នោះរួមមាន៖

**១. គណៈកម្មាធិការគណៈគ្រប់គ្រងជាន់ខ្ពស់ (EXCO)**
**២. គណៈកម្មាធិការទ្រព្យសកម្ម និងបំណុល (ALCO)**
**៣. គណៈកម្មាធិការឥណទាន (CC)**
**៤. គណៈកម្មាធិការលទ្ធកម្ម (PROCO)**
**៥. គណៈកម្មាធិការធនធានមនុស្ស (HRC)**
**៦. គណៈកម្មាធិការគ្រប់គ្រងហានិភ័យប្រតិបត្តិការ (ORMC)**
**៧. គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាអតិថិជន (CCHC)**
**៨.គណៈកម្មាធិការអភិវឌ្ឍអាជីវកម្ម(BDC)**

### ១. គណៈកម្មាធិការគណៈគ្រប់គ្រងជាន់ខ្ពស់

គណៈកម្មាធិការនេះមានសមាជិក៨នាក់ ត្រូវបានអញ្ជើញជាអចិន្ត្រៃយ៍នៅរៀងរាល់កិច្ចប្រជុំ EXCO។ ប្រធាននាយកប្រតិបត្តិគឺជាប្រធានគណៈកម្មាធិការនេះ។ គោលបំណងនៃការបង្កើត គណៈកម្មាធិការ គណៈគ្រប់គ្រងជាន់ខ្ពស់ គឺដើម្បីគាំទ្រដល់ប្រធាននាយប្រតិបត្តិក្នុងការត្រួតពិនិត្យ និងតាមដានដំណើរការអនុវត្តន៍ប្រតិបត្តិការទាំងមូលរបស់ក្រុមហ៊ុន និងរាយការណ៍ពីវឌ្ឍនភាពការងារប្រចាំថ្ងៃពីគ្រប់ផ្នែកពាក់ព័ន្ធទៅកាន់ប្រធាននាយកប្រតិបត្តិ ព្រមទាំងផ្តល់នូវអនុសាសន៍ ដើម្បីគាំទ្រដល់ការអនុម័តលើបញ្ហាទូទៅកើតមានឡើងនៅក្នុងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ។

#### សមាជិកភាព

គណៈកម្មាធិការគណៈគ្រប់គ្រងជាន់ខ្ពស់គឺជានាយកប្រតិបត្តិដែលរាយការណ៍ផ្ទាល់ទៅកាន់ប្រធាននាយកប្រតិបត្តិរួមមាន៖

**១. ប្រធាននាយកប្រតិបត្តិ**
**២. ប្រធាននាយកប្រតិបត្តិអាជីវកម្ម**
**៣. នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ**
**៤. នាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង**
**៥. នាយកប្រតិបត្តិហិរញ្ញវត្ថុ**
**៦. នាយកប្រតិបត្តិបច្ចេកវិជ្ជាព័ត៌មាន**
**៧. នាយកប្រតិបត្តិធនធានមនុស្ស និង រដ្ឋបាល**
**៨. នាយកប្រតិបត្តិ ប្រតិបត្តិការ**
**៩. ប្រធានផ្នែកអនុឡោមតាម**

# សមាជិក និងប្រវត្តិក្រុមប្រឹក្សាភិបាល

**កិច្ចប្រជុំ**

កិច្ចប្រជុំនឹងត្រូវបានប្រារព្ធធ្វើឡើងនៅពេលណាមួយសមរម្យប៉ុន្តែយ៉ាងហោចណាស់ធ្វើឡើង ១ដងក្នុងមួយសប្តាហ៍ ។ ប្រធានគណៈកម្មាធិការនេះអាចរៀបចំឱ្យមានការប្រជុំបន្ថែមទៀតប្រសិនបើចាំបាច់។

## ២. គណៈកម្មាធិការទ្រព្យសកម្ម និងបំណុល

គោលបំណងនៃ គណៈកម្មាធិការទ្រព្យសកម្ម និងបំណុល គឺដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងនូវទ្រព្យសម្បត្តិ និងបំណុលរបស់ក្រុមហ៊ុនទាំងមូល។ រួមទាំងការគ្រប់គ្រងសន្ទនីយភាព គម្លាតនៃកាលបរិច្ឆេទកំណត់របស់ទ្រព្យសកម្ម និងបំណុល ព្រមទាំងអាត្រាការប្រាក់ ជាប្រយោជន៍ដល់ក្រុមហ៊ុនការគ្រប់គ្រងធាតុទាំងឡាយនៃទ្រព្យសកម្ម និងបំណុល ត្រូវធ្វើឡើងដោយភាពច្បាស់លាស់ និងតម្លាភាព។

**សមាជិកភាព**

គណៈកម្មាធិការគ្រប់គ្រងហានិភ័យកម្រិតក្រុមប្រឹក្សាភិបាលមានតួនាទីតែងតាំង ប្រធានគណៈកម្មាធិការទ្រព្យសកម្ម និងបំណុល ហើយមានអាណត្តិ ៣ឆ្នាំ ដោយរាប់ចាប់ពីពេលតែងតាំង។

គណៈកម្មាធិការនេះមានសមាជិកដូចខាងក្រោម៖

**សមាជិកភាព**

| | |
|---|---|
| ១. ប្រធាននាយកប្រតិបត្តិ ( CEO ) | ប្រធាន |
| ២. ប្រធាននាយកប្រតិបត្តិអាជីវកម្ម ( CBO ) | សមាជិក |
| ៣. នាយកប្រតិបត្តិហិរញ្ញវត្ថុ ( HFD ) | សមាជិក |
| ៤. នាយប្រតិបត្តិគ្រប់គ្រងហានិភ័យ ( HRM ) | សមាជិក |

**កិច្ចប្រជុំ**

កិច្ចប្រជុំនឹងត្រូវបានប្រារព្ធធ្វើឡើងនៅពេលណាមួយសមរម្យប៉ុន្តែយ៉ាងហោចណាស់ធ្វើឡើង១ដងក្នុងមួយខែ។ ប្រធានគណៈកម្មាធិការនេះអាចរៀបចំឱ្យមានការប្រជុំ បន្ថែមទៀតប្រសិនបើចាំបាច់ ។

## ៣. គណៈកម្មាធិការឥណទាន

គោលបំណងនៃការបង្កើត គណៈកម្មាធិការឥណទាន គឺដើម្បី អនុម័តលំហូរការងារឥណទាន អនុលោមតាមបទដ្ឋានគោលនយោបាយឥណទាននិងអនុម័តកម្រិតឥណទានជូនអតិថិជនរូបវន្តបុគ្គលិក ឬក្រុមនៃប្រភេទអតិថិជន ស្របតាមកម្រិត សិទ្ធិអនុម័តដែលបានផ្តល់ជូន។ លើសពីនេះគណៈកម្មាធិការ ឥណទានទទួលខុសត្រូវក្នុងការអនុវត្តន៍ និងត្រួតពិនិត្យលើ ហានិភ័យឥណទាន និងគោលនយោបាយ ពាក់ព័ន្ធនឹង អាជីវកម្មក្រុមហ៊ុនទាំងមូល និងធ្វើឱ្យប្រាកដថាបទដ្ឋានអភិបាលកិច្ចនិងនីតិវិធីនៃការត្រួតពិនិត្យត្រូវបានអនុលោមតាម។

**សមាជិកភាព**

គណៈកម្មាធិការឥណទានមានសមាជិកដូចខាងក្រោម:

| | |
|---|---|
| ១. នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ | ប្រធាន |
| ២. ប្រធាននាយកប្រតិបត្តិ | សមាជិក |
| ៣. ប្រធាននាយកប្រតិបត្តិអាជីវកម្ម | សមាជិក |
| ៤. នាយកប្រតិបត្តិហិរញ្ញវត្ថុ | សមាជិក |

**កិច្ចប្រជុំ**

កិច្ចប្រជុំជាផ្លូវការត្រូវបានធ្វើឡើងយ៉ាងហោចណាស់១ដងក្នុង១ខែ។ ប្រធានគណៈកម្មាធិការឥណទានអាចរៀបចំឱ្យមានការប្រជុំបន្ថែមទៀតប្រសិនបើចាំបាច់។

## ៤. គណៈកម្មាធិការលទ្ធកម្ម

គោលបំណងរបស់គណៈកម្មាធិការលទ្ធកម្ម គឺស្វែងយល់ពីតម្លៃនៃសាច់ប្រាក់នៅគ្រប់ការធ្វើលទ្ធកម្ម។ តម្លៃដែលត្រូវបានសម្រេចជ្រើស រើសតាមរយៈការប្រកួតប្រជែងដោយបើកចំហនៅពេលដែលអ្នកផ្គត់ផ្គង់ណាមួយអាចជឿទុកចិត្តបានថាគម្រោងសំណើរបស់ពួកគេត្រូវបានវាយតម្លៃថាអាចទទួលយកបានមិនមានន័យថា"តម្លៃទាប" ជានិច្ចកាលត្រូវបានជ្រើសរើស ដោយស្វ័យប្រវត្តិនោះទេ ពោលគឺរួមបញ្ចូលទាំងការពិចារណា ភាពសមស្រប និងគោលបំណងតម្លៃទីផ្សារ ចំណូលលើការវិនិយោគ ការចំណាយទាំងអស់នៃមួយ វដ្តជីវិតការផ្គត់ផ្គង់ទាន់ពេលវេលា ការគាំទ្របន្ទាប់ពីផ្គត់ផ្គង់រួច និងនិរន្តរភាពបរិស្ថាន ការទទួលខុសត្រូវសង្គម ភស្តុតាងនៃបទពិសោធន៍ដែលបានអនុវត្តពីមុន ការធានាបាននូវប្រសិទ្ធភាព និងការអនុលោមទៅតាមច្បាប់។

**សមាជិកភាព**

គណៈកម្មាធិការលទ្ធកម្មរួមមានសមាជិក០៥រូបដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. នាយកប្រតិបត្តិហិរញ្ញវត្ថុ | ប្រធាន |
| ២. ប្រធាននាយកប្រតិបត្តិ | សមាជិក |
| ៣. ប្រធាននាយកប្រតិបត្តិអាជីវកម្ម | សមាជិក |
| ៤. នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ | សមាជិក |
| ៥. នាយកប្រតិបត្តិធនធានមនុស្ស និងរដ្ឋបាល/នាយករដ្ឋបាល | សមាជិក |

**កិច្ចប្រជុំ**

កិច្ចប្រជុំនឹងត្រូវបាន រៀបចំតាមពេលវេលាសមស្របយ៉ាងហោចណាស់ធ្វើឡើង ១ដងក្នុងមួយខែ។ ប្រធានគណៈកម្មាធិការនេះអាចនឹងកោះហៅប្រជុំបន្ថែម ប្រសិនបើមានការចាំបាច់ ។

## ៥. គណៈកម្មាធិការធនធានមនុស្ស

គោលបំណងនៃការបង្កើតគណៈកម្មាធិការធនធានមនុស្ស គឺដើម្បីធ្វើការត្រួតពិនិត្យ និងផ្តល់អនុសាសន៍ លើនីតិវិធីជ្រើសរើសបុគ្គលិកខាងក្នុង ការដំឡើងឋានៈ ការផ្លាស់ប្តូរទីកន្លែងការងារ និងការដំឡើងប្រាក់បៀវត្សរ៍បុគ្គលិកប្រកបដោយតម្លាភាពនិងយុត្តិធម៌។ គណៈកម្មាធិការគួរតែមានការប្រុងប្រយ័ត្ន ដើម្បីជៀសវាង ទំនាស់ផលប្រយោជន៍របស់ពួកគេ ក្នុងការវិនិច្ឆ័យ រកមូលហេតុឱ្យបានត្រឹមត្រូវ ហើយគួរតែជៀសវាង ពីកិច្ចការសម្រេចចិត្តទាំងឡាយណា ដែលជាប់ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍របស់ពួកគេ។

**សមាជិកភាព**

គណៈកម្មាធិការធនធានមនុស្សមានសមាជិក០៥រូបដែលមានសមាភាពដូចខាង ក្រោម៖

| | |
|---|---|
| ១. នាយកប្រតិបត្តិធនធានមនុស្ស និងរដ្ឋបាល | ប្រធាន |
| ២. ប្រធាននាយកប្រតិបត្តិអាជីវកម្ម | សមាជិក |
| ៣. នាយកប្រតិបត្តិហិរញ្ញវត្ថុ | សមាជិក |
| ៤. នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ | សមាជិក |
| ៥. មន្ត្រីជាន់ខ្ពស់ធនធានមនុស្ស | លេខាធិកា |

**កិច្ចប្រជុំ**

កិច្ចប្រជុំនឹងត្រូវបានធ្វើឡើងនៅពេលណាមួយសមរម្យ។ ប្រធានគណៈកម្មាធិការនេះ អាចរៀបចំឱ្យមានការប្រជុំបន្ថែមទៀតប្រសិនបើមានការចាំបាច់។

## ៦. គណៈកម្មាធិការគ្រប់គ្រងហានិភ័យប្រតិបត្តិការ

គណៈកម្មាធិការគ្រប់គ្រងហានិភ័យប្រតិបត្តិការ (ORMC) ដែលមានប្រធានមួយរូប ជានាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ និងសមាជិកប្រាំមួយរូបផ្សេងទៀតមកគណៈកម្មាធិការនាយក។ គោលបំណងនៃគណៈកម្មាធិការ នេះគឺដើម្បី តាមដាននូវការអនុវត្តន៍ជាប្រចាំ លើប្រព័ន្ធគ្រប់គ្រងហានិភ័យប្រតិបត្តិការរបស់ក្រុមហ៊ុន និង ធ្វើការរុករកនូវហានិភ័យប្រតិបត្តិការនានាកើតមានឡើង ព្រមទាំងរៀបចំផែនការកាត់បន្ថយហានិភ័យទាំងនោះ។ គណៈកម្មាធិការនេះធ្វើការត្រួតពិនិត្យផងដែរលើកម្មវិធីស្វ័យត្រួតពិនិត្យហានិភ័យ(Risk Control Self-Assessment (RCSA) ដើម្បីធានាដល់ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព។

**សមាជិកភាព**

គណៈកម្មាធិការនេះមាន មានសមាជិកអចិន្ត្រៃយ៍ដូចខាងក្រោម៖

| | |
|---|---|
| ១. នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ | ប្រធាន |
| ២. ប្រធាននាយកប្រតិបត្តិ | សមាជិក |
| ៣. ប្រធាននាយកប្រតិបត្តិអាជីវកម្ម | សមាជិក |
| ៤. នាយកប្រតិបត្តិហិរញ្ញវត្ថុ | សមាជិក |
| ៥. នាយកប្រតិបត្តិធនធានមនុស្ស និងរដ្ឋបាល | សមាជិក |
| ៦. នាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង | សមាជិក |
| ៧. នាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មាន | សមាជិក |
| ៨. នាយកប្រតិបត្តិប្រតិបត្តិការ | សមាជិក |

## ៧. គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាអតិថិជន

គណៈម្មាធិការនេះ ត្រូវបានបង្កើតឡើងដើម្បី អនុវត្ត និងរក្សាឱ្យបាននូវប្រសិទ្ធភាពក្នុងការដោះស្រាយបណ្តឹងតវ៉ាអតិថិជន។ ធ្វើការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍ លើគ្រប់តថភាពនៃបណ្តឹងអតិថិជន។

**សមាជិកភាព**

គណៈកម្មាធិការនេះមាន មានសមាជិកអចិន្ត្រៃយ៍ដូចខាងក្រោម៖

| | |
|---|---|
| ១. នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ | ប្រធាន |
| ២. ប្រធាននាយកប្រតិបត្តិ | សមាជិក |
| ៣. ប្រធាននាយកប្រតិបត្តិអាជីវកម្ម | សមាជិក |
| ៤. នាយកប្រតិបត្តិធនធានមនុស្ស និងរដ្ឋបាល | សមាជិក |
| ៥. ប្រធានផ្នែកប្រតិបត្តិតាម | ជាលេខាធិការ |

## ៨. គណៈកម្មាធិការអភិវឌ្ឍអាជីវកម្ម

គោលបំណងនៃគណៈកម្មាធិការអភិវឌ្ឍអាជីវកម្មរួមមាន៖

- ធ្វើការត្រួតពិនិត្យលើការអភិវឌ្ឍន៍ និងការអនុវត្តន៍យុទ្ធសាស្ត្រអាជីវកម្មការបង្កើតថ្មីនានាដែលស្របទៅនឹងទិសដៅអាជីវកម្ម
- ធ្វើការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាដែលរាំងស្ទះដល់វឌ្ឍនៈភាពអាជីវកម្ម និងពិនិត្យជាប្រចាំនូវស្ថានភាពនៃទីផ្សារទូទៅទាំងឱកាសអាជីវកម្ម និងការគម្រាមគម្ហែង។
- ធ្វើការរៀបចំ និងពិនិត្យនូវផែនការ ឬសេនាយ៉ូអាជីវកម្មសម្រាប់គណៈគ្រប់គ្រងដើម្បីជម្រុញនូវវឌ្ឍនៈភាពអាជីវកម្ម ឬការធ្វើពិពាធកម្មអាជីវកម្មស្របតាមកាលានុវឌ្ឍនភាពថ្មីៗ។
- ធ្វើការពិនិត្យនូវលទ្ធផលអាជីវកម្មធៀបនឹងសូចនាករអាជីវកម្មប្រចាំឆ្នាំ និងកំណត់ឱ្យបាននូវទិសដៅបន្ត ដើម្បីធានាបានការសម្រេចសមត្ថិផលអាជីវកម្មតាមការរំពឹងទុក។
- ធ្វើរបាយការណ៍វឌ្ឍនៈភាពនៃស្ថានភាពហិរញ្ញវត្ថុរបស់ដៃគូប្រកួតប្រជែងធៀបនឹងស្ថានភាពរបស់គ្រឹះស្ថាន ជាប្រចាំ។
- ធ្វើការស្នើសុំការអនុវត្តន៍យុទ្ធសាស្ត្រ ឬផលិតផលថ្មីៗ ក្នុងការទន្ទ្រានទីផ្សារ
- សិក្សានិងឱកាសនៃការធ្វើសមាហរន្តកម្ម ឬកិច្ចសហប្រតិបត្តិការអាជីវកម្មរវាងក្រុមសម្ព័ន្ធដើម្បីបង្កើនប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។

**សមាជិកភាព នៃគណៈកម្មាធិការអភិវឌ្ឍអាជីវកម្ម**

- ប្រធាននាយកប្រតិបត្តិ — ជាប្រធាន
- ប្រធាននាយកប្រតិបត្តិអាជីវកម្មជា — សមាជិក និងជាប្រធានបម្រុង
- នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ — ជាសមាជិក
- នាយកប្រតិបត្តិហិរញ្ញវត្ថុ — ជាសមាជិក
- នាយកប្រតិបត្តិប្រតិបត្តិការ — ជាសមាជិក
- នាយកប្រតិបត្តិព័ត៌មានវិទ្យា — ជាសមាជិក
- នាយកប្រតិបត្តិព័ត៌មានវិទ្យា — ជាសមាជិក
- ប្រធានផ្នែកប្រតិបត្តិតាម — ជាសមាជិក
- លេខាធិការនៃគណៈកម្មាធិការនេះត្រូវបានជ្រើសតាំងដោយប្រធាននាយកប្រតិបត្តិអាជីវកម្ម ពីអគ្គនាយកដ្ឋានអាជីវកម្ម

# ការគ្រប់គ្រងហានិភ័យ និងការអនុលោមតាមច្បាប់

នៅក្នុងឆ្នាំ២០១៧ ភាគហ៊ុន ១០០% របស់ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ត្រូវបានផ្ទេរឱ្យធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដោយមានការជួយគាំទ្រផ្នែកបច្ចេកទេសពីធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ។ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានកំណែទម្រង់ស៊ីជម្រៅ តាមរយៈ ការកែតម្រូវរចនាសម្ព័ន្ធគ្រប់គ្រងឱ្យស្របតាមអភិបាលកិច្ចសាជីវកម្ម ប្រព័ន្ធនៃការគ្រប់គ្រងហានិភ័យ និងការអនុមតិគោលនយោបាយថ្មីៗហើយឃ្លាំមើលការអនុវត្តន៍ ជាប្រចាំដោយគណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល ក្នុងគោលបំណងដើម្បីធានាបាននូវវឌ្ឍនភាពនិងនិរន្តរភាពអាជីវកម្មទាំងមូល។ បន្ទាប់ពីគោលនយោបាយនានាៗត្រូវបានកំណែទម្រង់ជាពិសេសក្នុងឆ្នាំ២០១៨ គណៈគ្រប់គ្រងរបស់ហ្វូណន បានធ្វើការពង្រឹងនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងតាមរយៈ ការដាក់ចេញនូវកម្មវិធីស្វ័យត្រួតពិនិត្យហានិភ័យ (Risk Control Self-Assessmemnt)ក្នុងគោលបំណងបង្កើតឱ្យមាននូវវប្បធម៌គិតដល់ហានិភ័យជាមុន សម្រាប់គ្រប់បុគ្គលិកទាំងអស់ទូទាំងហ្វូណន ព្រមទាំងធ្វើការផ្សព្វផ្សាយបណ្តុះបណ្តាល និងតម្រង់ទិសដល់ បុគ្គលិកគ្រប់ជាន់ថ្នាក់ជាប្រចាំនូវ គោលនយោបាយ នីតិវិធី សេចក្តី ណែនាំ ដើម្បីធានាបាននូវការអនុវត្តន៍ត្រឹមត្រូវ។

ក្នុងឆ្នាំ២០១៨ ហ្វូណនបានទទួលការចុះអធិការកិច្ចដល់ទីកន្លែងដោយធនាគារជាតិ នៃកម្ពុជា លើការត្រួតពិនិត្យទូទៅរួមទាំងការធ្វើប្រតិបត្តិការប្រចាំថ្ងៃរបស់ហ្វូណន គោលនយោបាយគ្រប់គ្រងហានិភ័យ និងអនុទ្បោមភាព។ ហើយជាលទ្ធផល យើងទទួលបានអនុសាសន៍ មួយចំនួនដើម្បី ធ្វើឱ្យកាន់តែប្រសើរលើប្រតិបត្តិការអាជីវកម្ម។ ក្រោយមកមុខងារប្រតិបត្តិតាម ត្រូវបានបង្កើតឡើងក្នុងរចនាសម្ព័ន្ធនៃគណៈគ្រប់គ្រងរបស់ហ្វូណន

តាមរយៈរបាយការណ៍របស់សវនករឯករាជ្យខាងក្រៅបានបង្ហាញ ពីភាពត្រឹមត្រូវ និងជឿជាក់បាន នៃរបាយការណ៍ហិរញ្ញវត្ថុ អនុលោមភាពតាមច្បាប់បទប្បញ្ញត្តិ និងកម្រិតនៃការគ្រប់គ្រងហានិភ័យ របស់ក្រុមហ៊ុនអាចទទួលយកបាន។

## ការគ្រប់គ្រងហានិភ័យឥណទាន

ដើម្បីធានាបាននូវការគ្រប់គ្រងហានិភ័យឥណទាន និងស្របតាមចំណែកទីផ្សារគោលដៅថ្មីរបស់ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី គោលនយោបាយឥណទានថ្មីត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល ហើយគោលនយោបាយនេះទៀតសោត ត្រូវបានរៀបរៀង ដោយឆ្លុះបញ្ចាំងទៅនឹងច្បាប់បទប្បញ្ញត្តិ កម្រិតហានិភ័យដែលអាចទទួលយកបាន និងការកំណត់ពិដានដើម្បីធ្វើពិពាធកម្មសម្ពាធឥណទាន ហើយ កាត់បន្ថយហានិភ័យ ឥណទាននៃចំណែកឥណទានភាគធំ។ ហ្វូណន បានបង្កើតឱ្យមានក្រុមអ្នកវិភាគឥណទាននៅកម្រិត ការិយាល័យកណ្តាល ដើម្បីធ្វើការត្រួតពិនិត្យ សំណើឥណទានរបស់អតិថិជនស្របតាមលក្ខខណ្ឌ និងកម្រិតហានិភ័យដែលមានចែងក្នុងគោលនយោបាយឥណទាន។ ហ្វូណន ធ្វើការតម្រង់ទិសជាប្រចាំ និងកែតម្រូវទាន់ពេលវេលានូវការអនុវត្តន៍មិនទាន់បានត្រឹមត្រូវរបស់ បុគ្គលិកតាមរយៈ របាយការណ៍គំហើញរបស់មន្ត្រីត្រួតពិនិត្យគុណភាពឥណទាន ។ ប្រព័ន្ធគ្រប់គ្រងរបាយការណ៍ផលប័ត្រឥណទាន និងចំណាត់ថ្នាក់អតិថិជន ត្រូវបានត្រួតពិនិត្យជាប្រចាំដើម្បីកំណត់យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យឥណទាន ដូចជាការធ្វើតេស្តឥណទាន (Credit stress test) ការវាស់វែងកម្រិតហានិភ័យតាមចំណាត់ថ្នាក់អតិថិជន (Measurement of concentration of risk by customer segment) និងការវាស់វែងហានិភ័យអន្តរកាលទៅតាមចំណាត់ថ្នាក់អតិថិជន (Risk transition measurement by customer segment)។ល។ វិធីសាស្ត្រក្នុងការបង្ការផលប័ត្រឥណទានក៏ត្រូវបានបង្កើតឡើងដើម្បីអនុវត្តទូទាំងគ្រឹះស្ថាន។

ហ្វូណនបាននឹងកំពុងអភិវឌ្ឍនូវប្រព័ន្ធសិក្សារនិងវាយតម្លៃកម្ចីតាមប្រព័ន្ធបច្ចេកវិទ្យា(Loan Origination System) ដែលនឹងដាក់ឱ្យដំណើរការក្នុងឆ្នាំ២០២១ខាងមុខនេះ។ ជាមួយនឹងទម្រង់នៃបច្ចេកវិទ្យានេះ ហ្វូណននឹងក្លាយទៅជាគ្រឹះស្ថាននាំមុខគេ ដែលអនុវត្តនូវតំណើរការផ្តល់ប្រាក់កម្ចីតាម ប្រព័ន្ធបច្ចេកវិទ្យា។ មន្ត្រីឥណទានរបស់ហ្វូណននឹងត្រូវបានផ្តល់ឱ្យនូវឧបករណ៍ (tablet device) ដែលមានភ្ជាប់អ៊ីនធឺណែត អាចធ្វើការចាប់យកនូវទីតាំងអាជីវកម្ម អាស័យដ្ឋាន ឬទ្រព្យធានា តាមរយៈgoogle map របស់អតិថិជននៅពេលធ្វើការចុះសិក្សាកម្ចីដោយមន្ត្រីឥណទាន។ បន្ទាប់ពីការចុះឈ្មោះស្នើសុំកម្ចី ជាមួយនឹងតំណរភ្ជាប់នៃបណ្តុំទិន្នន័យមានស្រាប់របស់ហ្វូណនការិយាល័យឥណទានCredit Bureau ព័ត៌មានអតិថិជននឹងត្រូវបានបញ្ជូន និងផ្ទៀងផ្ទាត់ទៅនឹងលក្ខខ័ណ្ឌនានាដែលមានស្រាប់ដោយស្វ័យប្រវត្តិ ដែលនេះធ្វើឱ្យតំណើរការនៃការផ្តល់ប្រាក់កម្ចីកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ឡើង។ ហ្វូណនធ្វើការអភិវឌ្ឍប្រព័ន្ធLoSនេះឡើងដើម្បីធ្វើការពន្លឿននូវសេវាកម្មអតិថិជន និងគ្រប់គ្រងនូវហានិភ័យឥណទាន។

## ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ

ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បង្កើតគំរូបទដ្ឋាន គ្រប់គ្រងហានិភ័យដោយរួមបញ្ចូលទាំងគោលនយោបាយគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មាន និងប្រមូលទិន្នន័យ បាត់បង់ និងសូចនាករហានិភ័យសំខាន់ៗ ដើម្បីត្រួតពិនិត្យ និងតាមដានហានិភ័យនានា។ លើសពីនេះទៅទៀត គ្រឹះស្ថានបានអនុវត្តសកម្មភាពត្រួតពិនិត្យ និងប៉ាន់ប្រមាណហានិភ័យដើម្បីបង្កើតវប្បធម៌ ត្រួតពិនិត្យហានិភ័យប្រតិបត្តិការទូទាំងគ្រឹះស្ថាន។

សកម្មភាពបណ្តុះបណ្តាលពីរបៀបត្រួតពិនិត្យ និងប៉ាន់ប្រមាណហានិភ័យត្រូវបានបន្តអនុវត្តទៅគ្រប់ផ្នែក និងសាខាទាំងអស់នៅគ្រឹះស្ថានដើម្បីពង្រឹងការអនុវត្តន៍លើការត្រួតពិនិត្យហានិភ័យប្រតិបត្តិការ។

## ការគ្រប់គ្រងហានិភ័យសន្ទនីយភាព

ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី គ្រប់គ្រងស្ថានភាពសន្ទនីយភាព យ៉ាងប្រុងប្រយ័ត្នបំផុត ដោយអនុលោមតាមនីតិវិធីមួយចំនួនដូចជា ការវិភាគលំហូរសាច់ប្រាក់ លំហូរសាច់ប្រាក់អតិបរិមា និងធ្វើតេស្តលើអនុបាតសន្ទនីយភាព និងការអនុវត្តន៍គោលនយោបាយទាំងនេះជួយឱ្យគ្រឹះស្ថានមានលទ្ធភាព គ្រប់គ្រងស្ថានភាពសាច់ប្រាក់ល្អប្រសើរ ប្រកបដោយភាពរលូនទាំងក្នុងស្ថានភាពធម្មតា និងស្ថានភាពមិនប្រក្រតី ព្រមទាំងជួយឱ្យគ្រឹះស្ថានរក្សាបាននូវស្ថានភាពសន្ទនីយភាពល្អ ។

## ការប្រតិបត្តិតាម

ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានប្តេជ្ញាដើម្បីប្រតិបត្តិតាមបទដ្ឋានទីផ្សារ និងខ្នាតគំរូល្អប្រសើរដូចជា គណនេយ្យភាព តម្លាភាព ក្រមសីលធម៌ក្នុងការប្រកបអាជីវកម្មដើម្បី ជម្រុញនូវនិរន្តរភាព។ អភិបាលកិច្ចល្អ និងការរួមចំណែកទទួលខុសត្រូវសង្គមបង្កើតនូវបទដ្ឋានទីផ្សារ។ ចំណុចស្នូលទាំងនេះ គឺសំដៅលើសុច្ចរិតភាព និងហានិភ័យកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនដែលនឹងកំពុងប្រឈមក្នុងសកម្មភាព អាជីវកម្មរបស់ខ្លួន។

មុខងារឯករាជ្យត្រូវបានតែងតាំង និងទទួលបានការយល់ព្រមពី BOD និង NBC ដើម្បីតាមដាន និងប្រតិបត្តិតាមអនុលោមភាពរបស់ក្រុមហ៊ុន។

ការអនុវត្តន៍មុខងារប្រតិបត្តិតាមមានដូចខាងក្រោម៖

### ក).ការប្រតិបត្តិតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ:

ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានប្រកាន់ខ្ជាប់យ៉ាងពេញលេញនូវការប្រតិបត្តិច្បាប់ និង បទប្បញ្ញត្តិពាក់ព័ន្ធ។ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតបញ្ជីអនុលោមតាមដើម្បីវាយតម្លៃការអនុវត្តន៍របស់ស្ថាប័ន។ មុខងារ និងឯករាជ្យភាពនៃមន្ត្រីទទួលបន្ទុកច្បាប់ និងប្រតិបត្តិតាម ជាអ្នកសម្របសម្រួល និងការត្រួតពិនិត្យការអនុវត្តន៍របស់គ្រឹះស្ថានទាំងមូលក្នុងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។

### ខ).និវេទនកម្ម:

គ្រឹះស្ថានបានប្តេជ្ញាចិត្ត ក្នុងការថែរក្សា និងសម្រេចបាននូវបទដ្ឋានខ្ពស់បំផុតដូចជាការបើកចំហចំពោះការបញ្ចេញមតិសុចរិតភាព និងគណនេយ្យភាព។

សុចរិតភាព។ ការអនុវត្តនេះត្រូវបានពង្រឹងនៅក្នុងគ្រឹះស្ថានទាំងមូលដើម្បី

លើកទឹកចិត្តបុគ្គលិក គ្រឹះស្ថានរាយការណ៍ បញ្ហាសំខាន់ៗ ដោយគ្មានការរារាំង ដូចជា៖

សុចរិតភាព។ ការអនុវត្តនេះត្រូវបានពង្រឹងនៅក្នុងគ្រឹះស្ថានទាំងមូលដើម្បី

លើកទឹកចិត្តបុគ្គលិក គ្រឹះស្ថានរាយការណ៍ បញ្ហាសំខាន់ៗ ដោយគ្មានការរារាំង ដូចជា៖

ច្បាប់ការរំលោភបទប្បញ្ញត្តិ

អំពើខុសឆ្គងការចោទប្រកាន់មិនត្រឹមត្រូវឬការក្លែងបន្លំទាក់ទងនឹងការ

គ្រប់គ្រងផ្ទៃក្នុងគណនេយ្យភាពសវនកម្ម

- គ្រោះថ្នាក់សុខភាព និងសុវត្ថិភាពបុគ្គលិក
- ការរំលោភបំពានលើច្បាប់នៃការអនុវត្តន៍ការងារនៅក្នុងក្រុមហ៊ុន
- ការបិទបាំងដោយចេតនានូវចំណុចណាមួយខាងលើ
- ការប្រព្រឹត្តបទឧក្រិដ្ឋ រំលោភបំពានច្បាប់រដ្ឋប្បវេណី និងភាពថ្លោះធ្លោយនៃភាពយុត្តិធម៌
- ស្ថានភាពទំនាស់ផលប្រយោជន៍
- ការខូចខាតប៉ះពាល់ដល់បរិស្ថាន
- ការប្រព្រឹត្តមិនត្រឹមត្រូវ ឬឥរិយាបថគ្មានក្រមសីលធម៌
- ភាពដែលអាចប៉ះពាល់ដល់ជំហររបស់ក្រុមហ៊ុន

# ក្រមសីលធម៌វិជ្ជាជីវៈ

ហ្វូណន បានដាក់ឱ្យប្រើប្រាស់នូវគោលនយោបាយ ក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីជាបទដ្ឋានសម្រាប់បុគ្គលិកទាំងអស់ក្នុងការអនុវត្តន៍ការងារប្រចាំថ្ងៃ និងគាំទ្រតម្លៃ រួមរបស់ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។ ការដាក់ឱ្យប្រើប្រាស់នូវគោលកាណ៍នេះ ដើម្បីធានាដល់គ្រប់ ភាគីពាក់ព័ន្ធ និងជាមាគ៌ាសម្រាប់ការបំពេញការងាររបស់បុគ្គលិក ប្រកបដោយ ក្រមសីលធម៌វិជ្ជាជីវៈ តម្លាភាព ការរក្សាការសម្ងាត់ ទំនាស់ផលប្រយោជន៍ការទទួលយកអំណោយ ការលាងសម្អាតសាច់ប្រាក់ ការរើសអើង និវេទនកម្ម និងអាកប្បកិរិយាល្អ។ គោលនយោបាយក្រមសីលធម៌វិជ្ជាជីវៈ គឺជាមគ្គុទេស តម្រង់ទិសឱ្យបុគ្គលិកយល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន និងបង្កើតបាននូវវប្បធម៌រួមមួយ ក្នុងអង្គភាព ទោះបីជាពួកគេមកពីប្រភពផ្សេងៗក៏ដោយ។



# ថ្នាក់ដឹកនាំ

- របនាសម្ព័ន្ធរបស់គ្រឹះស្ថាន
- ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល
- ចំណាប់អារម្មណ៍របស់ប្រធាននាយកប្រតិបត្តិ
- សមាជិក និងប្រវត្តិក្រុមប្រឹក្សាភិបាល
- គណៈគ្រប់គ្រង

## គណៈគ្រប់គ្រង



# រចនាសម្ព័ន្ធគ្រប់គ្រងគ្រឹះស្ថាន



# ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល



ជាបឋមខ្ញុំសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងសកម្មភាពគ្រប់គ្រងទៅនឹងការរាតត្បាតនៃជម្ងឺកូវីដ១៩ក្នុងប្រទេសកម្ពុជាទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ដែលយើងអាចសម្គាល់ឃើញថាខណៈពេលដែលប្រទេសជាច្រើន ទាំងក្នុងតំបន់ ក៏ដូចជាក្នុងពិភពលោកទាំងមូលកំពុងបានឆ្លងរីករាលដាលនៃជម្ងឺកូវីដ១៩នេះ ហើយមានទីក្រុងជាច្រើនត្រូវបានអនុវត្តនូវវិធានការបិទខ្ទប់ និងបម្រាមនានាដើម្បីកាត់ផ្តាច់ខ្សែចង្វាក់នៃការចម្លង ប៉ុន្តែសម្រាប់ប្រទេសកម្ពុជាយើងមានករណីរកឃើញត្រឹម៣៦៣នាក់ប៉ុណ្ណោះ (គិតត្រឹមថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២០) ហើយភាគច្រើនជាករណីនាំចូល។ អាជ្ញាធរបានចាត់វិធានការ យ៉ាងឆាប់រហ័សនូវប្រភពនៃការចម្លងថ្មីៗតាមរយៈការធ្វើតេសបន្ទាន់ចំពោះអ្នកដែលមានទំនាក់ទំនងផ្ទាល់នឹងបុគ្គលវិជ្ជមាន និងអនុវត្តវិធានចត្តាឡីស័ក។ ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វូណាន និងក្នុងនាមខ្ញុំផ្ទាល់ យើងខ្ញុំប្តេជ្ញាចិត្ត ក្នុងការចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់នូវវិបត្តិនេះ ដើម្បីរួមចំណែករក្សាបាននូវសន្តិភាព និងស្ថេរភាពជាតិយើង។

ទោះបីជាការរាតត្បាតក្នុងស្រុកត្រូវបានគ្រប់គ្រងក៏ដោយសម្រាប់ឆ្នាំ២០២០នេះ ប៉ុន្តែជម្ងឺរាតត្បាតជាសកលនេះ បានធ្វើឱ្យរាំងស្ទះដល់សកលភាវូបនីយកម្ម ខ្សែចង្វាក់នៃការផ្គត់ផ្គង់ និងការផ្លាស់ប្តូរនៃរបៀបទំនាក់ទំនង និងការរស់នៅរបស់មនុស្សជាតិ។ ហើយវាពិតជាបានធ្វើឱ្យមានផលប៉ះពាល់ ជាពិសេសទៅលើវិស័យធំៗដែលគាំទ្រដល់ឃឿនសេដ្ឋកិច្ចជាតិទាំងមូល រួមមានវិស័យនាំចេញនាំចូល វិស័យទេសចរណ៍ និងវិស័យដឹកជញ្ជូនផងដែរ។ ចាប់តាំងពីដើមឆ្នាំ២០២០មក មានរោងចក្រសហគ្រាសមួយចំនួន បានធ្វើការ ពន្យាពេលប្រតិបត្តិការរបស់ខ្លួន ហើយបណ្តាលឱ្យការងារជាងពីររយកន្លែងត្រូវបានផ្អាកជាបណ្តោះអាសន្ន។ ផលប៉ះពាល់ទាំងអស់នេះ បានធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជា សម្រាប់ឆ្នាំ២០២០ ធ្លាក់ចុះអវិជ្ជមានពីរភាគរយ។

វិស័យហិរញ្ញវត្ថុនៅបន្តមានវឌ្ឍនៈភាពសម្រាប់ឆ្នាំ២០២០នេះ ដែលមានកំណើនទ្រព្យសកម្មសរុប១៥,៧ភាគរយ។ សម្រាប់ទំហំប្រាក់កម្ចីធនាគារ និងមីក្រូហិរញ្ញវត្ថុមានកំណើន១៤,៨ភាគរយ និងប្រាក់សន្សំមានកំណើន១៥,៤ភាគរយ។ ផលប័ត្រឥណទានក្នុងវិស័យមីក្រូហិរញ្ញវត្ថុ មានប្រមាណជាង៦,៨ពាន់លានដុល្លារអាមេរិក ដែលមានកំណើនប្រហែល១២,៥ភាគរយបើធៀបនឹងឆ្នាំ២០១៩កន្លងទៅ។ សកម្មភាពនៃការផ្តល់ប្រាក់កម្ចីរបស់មីក្រូហិរញ្ញវត្ថុមានបំណែងចែកដូចតទៅ ៣១,២ភាគរយទៅលើការប្រើប្រាស់ផ្ទាល់ខ្លួន ២០,៩ភាគរយជាដើមទុនអាជីវកម្ម ១៨,៩ភាគរយសម្រាប់វិស័យកសិកម្ម ១៦,២ភាគរយទៅលើវិស័យសេវាកម្ម ៦ភាគរយសម្រាប់វិស័យដឹកជញ្ជូន ៣,៨ភាគរយសម្រាប់វិស័យសំណង និង៣%លើវិស័យផ្សេងៗ។ ភាគរយនៃសកម្មភាពផ្តល់ប្រាក់កម្ចីរបស់វិស័យមីក្រូហិរញ្ញវត្ថុនេះគឺមានភាពប្រហាក់ប្រហែលគ្នាទៅសកម្មភាពនៃការផ្តល់ប្រាក់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វូណានផងដែរ។ការរាំងស្ទះនៃចំណូលរបស់អតិថិជនដែលរង់ពីអស្ថេរភាពនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ធ្វើឱ្យគ្រឹះស្ថានហិរញ្ញវត្ថុមានកំណើនឡើងចុះនៃផលប័ត្រឥណទានមានហានិភ័យ (DPD30+) ប្រែប្រួលសម្រាប់ខែនីមួយៗនៃឆ្នាំ២០២០។ ចាប់ពីត្រីមាសទី៤មក សកម្មភាពសេដ្ឋកិច្ចក្នុងស្រុកហាក់មានសន្ទុះឡើងវិញជាបណ្តើរៗ ធ្វើឱ្យអត្រាផលប័ត្រឥណទានមានហានិភ័យមាន១,៧១ភាគរយសម្រាប់វិស័យទាំងមូល ដែលវិស័យធនាគារមានអត្រា១,៦៤ភាគរយ និង១,៦៣ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ។

ក្នុងបរិបទនៃការអនុវត្តន៍នូវរបៀបរស់នៅថ្មី ជាពិសេសក្នុងការរក្សាគម្លាតសង្គមនោះ គ្រឹះស្ថានហិរញ្ញវត្ថុជាពិសេសធគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបាននឹងកំពុងធ្វើការជម្រុញការប្រើប្រាស់បច្ចេកវិទ្យាធនាគារចល័ត ដើម្បីធ្វើប្រតិបត្តិការផ្ទេរឬចំណាយ (QR Scan) ដោយមិនចាំបាច់ប្រើប្រាស់ក្រដាសប្រាក់ដោយផ្ទាល់។ កិច្ចគាំទ្រពីធនាគារជាតិនៃកម្ពុជា តាមរយៈការបង្កើតនូវប្រព័ន្ធធ្វើប្រតិបត្តិការឆ្លងធនាគារ ជាពិសេសប្រព័ន្ធបាគង អាចឱ្យគ្រឹះស្ថានហិរញ្ញវត្ថុ ធ្វើអន្តរកម្មនៃប្រតិបត្តិការឆ្លងធនាគារដោយមិនគិតថ្លៃសេវា ហើយនេះបានជម្រុញនូវសកម្មភាពប្រតិបត្តិការមិនប្រើប្រាស់សាច់ប្រាក់ ឬការបូបអេឡិចត្រូនិចសម្រាប់សង្គមកម្ពុជាក្នុងយុគ្គសម័យបច្ចេកវិទ្យានេះ។

ក្នុងនាមជាស្ថាប័នមីក្រូហិរញ្ញវត្ថុមួយ ហ្វូណានបាននឹងកំពុងគាំទ្រដល់អតិថិជន ដែលទទួលរងផលប៉ះពាល់ពីវិបត្តិ នៃការរីករាលដាលជាសកលនៃជម្ងឺនេះតាមរយៈការផ្តល់ការអនុគ្រោះ លើការរៀបចំឥណទានឡើងវិញដើម្បីធានានូវនិរន្តរភាពអាជីវកម្មរបស់ពួកគេ។ ដោយមានការគាំទ្រយ៉ាងយកចិត្តទុកដាក់ពីភាគទុនិក ទាំងប្រភពផ្តល់មូលនិធិ និងជំនួយបច្ចេកទេស ហ្វូណាននៅតែរឹងមាំ នឹងផ្លាស់ប្តូររាល់បញ្ហាប្រឈមទាំងនេះឱ្យទៅជាឱកាស ហើយទទួលបានការជឿទុកចិត្តកាន់តែច្រើនពីភាគីពាក់ព័ន្ធរួមមាន អតិថិជន និយ័តករ និងអ្នកផ្តល់ហិរញ្ញប្បទាននានា ដើម្បី រួមចំណែកដល់វឌ្ឍនៈភាពរបស់ហ្វូណាននាពេលខាងមុខជាបន្តទៀត។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាល បានយកចិត្តទុកដាក់ចាត់វិធាន ដល់គ្រប់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុទាំងអស់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ក្នុងការដោះស្រាយ រាល់បញ្ហាប្រឈម ឆ្លើយតបទៅនឹងវិបត្តិដោយរក្សាប្រយោជន៍ ដល់គ្រប់ភាគីពាក់ព័ន្ធ និងអតិថិជនផងដែរ។

ជាចុងបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណដល់អតិថិជន និយ័តករ បុគ្គលិក ភាគទុនិក និងគ្រប់ភាគីពាក់ព័ន្ធ សម្រាប់ការខិត ខំប្រឹងប្រែងរយៈពេលកន្លងមកក្នុងការជួយគាំទ្រ ផ្តល់ទំនុកចិត្ត ដល់គ្រឹះស្ថានហ្វូណានឲ្យទទួលបានលទ្ធផលល្អសម្រាប់ឆ្នាំ២០២០នេះ។

សូមទេវតាឆ្នាំថ្មី ប្រសិទ្ធិពរជ័យ សេរីមង្គល វិបុលសុខចម្រើនរុងរឿងដល់លោកអ្នកទាំងអស់ កុំបីឃ្លៀងឃ្លាតឡើយ។

សូមសុខសុវត្ថិភាព ពីជម្ងឺដង្កាត់ទាំងឡាយ។

**អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ**

**ប្រធានក្រុមប្រឹក្សាភិបាល**

# ចំណាប់អារម្មណ៍របស់ប្រធាននាយកប្រតិបត្តិ



ការរីករាលដាលនៃជម្ងឺកូវីត-១៩បានបង្រៀនយើងយ៉ាងច្រើន ជាពិសេសនូវរបៀបរស់នៅ និងការធ្វើអាជីវកម្មតាមគន្លងថ្មី ។ ការគ្រប់គ្រងការរីករាលដាលនៅកន្លែងធ្វើការ និងការបន្តនិរន្តភាពអាជីវកម្មក្នុងករណីមានករណីឆ្លង គឺជារបៀបវារៈសំខាន់សម្រាប់គណៈគ្រប់គ្រងហ្វូណានក្នុងឆ្នាំ ២០២០។ ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វូណានបាននឹងកំពុងធ្វើការអនុវត្តន៍ផែនការបន្តនិរន្តភាពអាជីវកម្ម (BCP) ក្នុងការធានានូវប្រតិបត្តិការអាជីវកម្មដូចប្រកតី និងបន្តផ្តល់សេវាកម្មជូនអតិថិជនដោយមិនមានការរំខាន់ឡើយ ហើយធានាបាននូវសុខមាលភាពបុគ្គលិកផងដែរ។ តាមការិយាល័យនិមួយៗរបស់ហ្វូណាន ត្រូវបានអនុវត្តនូវការវាស់កំដៅបុគ្គលិកនិងអតិថិជន និងការលាងសម្អាតដៃជាប្រចាំ។ ធ្វើការដាក់ឱ្យនៅដាច់ដោយឡែក ដោយធ្វើការពីផ្ទះសម្រាប់បុគ្គលិកដែលណាដែលមានហានិភ័យខ្ពស់ ធ្លាប់បានចូលរួមនូវកម្មវិធីជួបជុំ ឬកម្មវិធីសាសនានានា។ គ្រឹះស្ថានបានចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តការណែនាំរបស់អជ្ញាធរក្នុងការទប់ស្កាត់ជម្ងឺឆ្លងនេះ។ តាមរយៈនៃប្រព័ន្ធបណ្តាញសង្គមរបស់គ្រឹះស្ថាន កាធ្វើអនាម័យឬ កិច្ចការពារខ្លួនផ្សេងៗ ត្រូវបានផ្សព្វផ្សាយនិងចែកចាយបន្តដោយបុគ្គលិកនិងអ្នកដែលគាំទ្របណ្តាញ សង្គមហ្វូណាន។

រាល់ពេលមានការប្រកាសរបស់អជ្ញាធរស្តីពីការផ្ទុះឡើង នៃជម្ងឺកូវីដ១៩ក្នុងសហគមន៍ ការបែកចែកក្រុមការងារពីការិយាល័យខ្លះ ពីផ្ទះខ្លះ ឬពីទីកន្លែងដែលបានរៀបចំទុកផ្សេងទៀត ត្រូវបានអនុវត្តដើម្បីត្រៀមលក្ខណៈសម្បត្តិទុកជាមុនក្នុងករណីដែលបុគ្គលិកនៃទីកន្លែងមួយត្រូវបានដាក់ឱ្យធ្វើចត្តាឡីស័ក ១៤ថ្ងៃ គឺយើងមានក្រុមការងារមួយក្រុមផ្សេងទៀតដើម្បី ប្រតិបត្តិការអាជីវកម្មរបស់យើងបាន។ ក្នុងការអនុវត្តគម្លាត និងការជួបជុំនានា បុគ្គលិករបស់យើងទទួលបានបទពិសោធន៍ថ្មី និងស្និតស្នាល់ទៅនឹង ការបណ្តុះបណ្តាលឬការប្រជុំតាមប្រព័ន្ធបច្ចេកវិទ្យាអនឡាញ បើទោះបីជាយើងមានក្រុមការងារឬបណ្តាញសាខាការិយាល័យប្រតិបត្តិការទូទាំងប្រទេសដល់ទៅ៥១សាខាក៏ដោយ។ ការយកចិត្តទុកដាក់ទៅនឹងការជូនដំណឹង និងចំណាត់ការរបស់អជ្ញាធរជាប្រធានបទក្នុងកិច្ចពិភាក្សា ក្នុងក្រុមនៃគណៈគ្រប់គ្រងជាន់ខ្ពស់របស់យើងដើម្បីធ្វើឱ្យប្រាកដថាយើងបានអនុវត្ត និងណែនាំបន្តទៅកាន់បុគ្គលិក អតិថិជនរបស់យើងបានច្បាស់លាស់ និងត្រឹមត្រូវ។ ក្នុងន័យនេះទស្សនៈរបស់ខ្ញុំគឺៈ ការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ ១៩ មិនចំពោះតែយើងមានធនធានច្រើនដើម្បីឧត្តមដល់រដ្ឋាភិបាលនោះទេ ពោលគឺការរួមចំណែកធ្វើជាប្រជាពលរដ្ឋល្អ ដែលអនុវត្តនូវការណែនាំនិងបម្រាមនានា។

សម្រាប់ឆ្នាំ២០២០នេះ ស្ថានភាពហិរញ្ញវត្ថុរបស់ហ្វូណាននូវមានភាពល្អប្រសើរ បើទោះជាអត្រាប្រាក់ចំនេញមានការធ្លាក់ចុះ១២ភាគរយធៀបនឹងឆ្នាំ២០១៩ក៏ដោយ តែអត្រានេះគឺឆ្លើយតបទៅនឹងការព្យាករណ៍ដែលបានរំពឹងទុក។ ឆ្នាំ២០២០នេះដោយស្របតាមផែនការដែលបានគ្រោងទុក កំណើននៃទ្រព្យសកម្មរបស់ហ្វូណានមានសន្ទុះត្រឹម៥ភាគរយប៉ុណ្ណោះ ខណៈពេលដែលកំណើនជាមធ្យមប្រចាំឆ្នាំក្នុងរយៈពេល៥ឆ្នាំចុងក្រោយមាន៥០ភាគរយ ពោលគឺចាប់តាំងការផ្ទេរភាគហ៊ុនមក។ ដូច្នោះទ្រព្យសកម្មរបស់ហ្វូណានមានកំណើនរហូតដល់៦២លានដុល្លារអាមេរិក។ អនុបាតប្រាក់ចំណេញធៀបនឹងមូលធន (ROE) ទទួលបាន១៨,៤ភាគរយ និងអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) មាន៤,៤ភាគរយ។ បើប្រៀបធៀបអត្រាហានិភ័យឥណទានទៅនឹងវិស័យទាំងមូលដែលវិស័យលធនាគារមានអត្រាផលប័ត្រឥណទានក្នុងហានិភ័យ(DPD30+) មាន១,៦៤ភាគរយ និងមីក្រូហិរញ្ញវត្ថុមាន១,៦៣ភាគរយខណៈពេលដែលហ្វូណានមានផលប័ត្រឥណទានមានហានិភ័យ(DPD30+)ត្រឹម១,៥៦ភាគរយ។

ដោយចំណែកទីផ្សារគោលដៅរបស់ហ្វូណាន ផ្តោតលើអ្នកមានចំណូលទាបរួមទាំងអ្នកទទួលបានចំនូល ពីប្រាក់បៀវត្សរ៍ និងអ្នកដែលមានចំនូលពីអាជីវកម្មផ្ទាល់ខ្លួន ការរាំងស្ទះប្រាក់ចំណូលរបស់អតិថិជន ពីផលប៉ះពាល់នៃជម្ងឺកូវីដ១៩ គឺជាបញ្ហាប្រឈមដល់ការអនុវត្តកត្តព្វកិច្ចរបស់អតិថិជនជាមួយ គ្រឹះស្ថានផងដែរ។ ដូច្នោះដើម្បីធានា និរន្តភាពអតិថិជនរបស់យើង ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន បានធ្វើការអនុម័តិគោលនយោបាយឥណទានរៀបចំឡើងវិញ ក្នុងកិច្ចគាំទ្រដល់អតិថិជនដែលទទួលរងនូវផលប៉ះពាល់នេះ។ ក្នុងឆ្នាំ២០២០នេះ អតិថិជនប្រមាណជាង១៤,៨% ទទួលបានការធ្វើឥណទានរៀបចំឡើងវិញក្នុងលក្ខខ័ណ្ឌប្រកបដោយការអនុគ្រោះ និងយោគយល់បំផុត។

សម្រាប់ឆ្នាំ២០២១នេះ ការអូសបន្លាយនៃការផ្ទុះឡើងនៃជម្ងឺកូវីដ១៩ ធ្វើឱ្យប្រភពចំណូលអតិថិជនមានការធ្លាក់ចុះ និងធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចក្នុងស្រុកមានភាពមិនច្បាស់លាស់ផងដែរ។ ទោះបីយ៉ាងនេះក៏ដោយ យើងនូវតែមានសុទិដ្ឋិនិយមចំពោះរាជរដ្ឋាភិបាល ក្នុងវិធានការប្រឆាំងទៅនឹងជម្ងឺរាត ត្បាតនេះជាពិសេសទៅលើយុទ្ធនាការនៃការចាក់វ៉ាក់សាំងបង្ការជម្ងឺកូវីដ១៩ ដែលនឹងនាំមកនូវស្ថេរភាពឡើងវិញនៃសម្មភាពអាជីកម្មក្នុងស្រុក។ ហ្វូណាន បានត្រៀមលក្ខណៈសម្បត្តិរួចជាស្រេចដើម្បីជួយអតិថិជនរបស់ខ្លួន ស្តារឡើងវិញងើបចេញពីផលប៉ះពាល់ពីវិបត្តិនេះ។ ក្នុងឆ្នាំ២០២១នេះផងដែរយើងមាន ផែនការដាក់លាក់ក្នុងការដាក់ឱ្យតំណើរការ នៃប្រព័ន្ធដំណើរការប្រាក់កម្ចី (LOS) ដែលអាចជួយយើងឱ្យពន្លឿននូវការឆ្លើយតបក្នុងការផ្តល់សេវាកម្មប្រាក់កម្ចីជូនអតិថិជនរបស់យើង ដូចបានបញ្ជាក់ក្នុងបេសកម្មរបស់ ហ្វូណាន " *ផ្តល់នូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុ ប្រកបដោយភាពច្នៃប្រឌិត ដែលមានលក្ខណៈ សាមញ្ញ ងាយស្រួល សេវារហ័ស និងប្រតិបត្តិតាមច្បាប់ ប្បញ្ញត្តិនានា*"។ សម្រាប់ឆ្នាំ២០២១ការអភិវឌ្ឍអាជីវកម្ម នៅតែជាទិសដៅអទិភាពក្នុងការពង្រីក បណ្តាញ និងផ្តល់សេវាកម្មកាន់តែទូលំទូលាយជូនដល់អតិថិជន។

ជាចុងក្រោយ យើងសូមថ្លែងអំណរគុណចំពោះ អតិថិជន និយ័តករ ម្ចាស់ភាគហ៊ុន ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិករបស់ហ្វូណាន ហើយសូមថ្លែងអំណរគុណចំពោះការលើកទឹកចិត្ត ការលះបង់ ដែលជាផ្នែកមួយនៃភាពជោគជ័យ និងការរីកចម្រើនរបស់ហ្វូណាន។

**លោក ឃូ ប៊ុនទ្រី**



**ប្រធាននាយកប្រតិបត្តិ**

# សមាជិក និងប្រវត្តិក្រុមប្រឹក្សាភិបាល



## អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ

**ប្រធានក្រុមប្រឹក្សាភិបាល**

អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ ជាប្រធានក្រុមប្រឹក្សាភិបាល ធនាគារ កាណាឌីយ៉ា និងក្រុមហ៊ុនវិនិយោគទុនអាណិកជនកម្ពុជា (Overseas Cambodian Investment Corporation, OCIC)។ លោកបានចូលរួមយ៉ាង សកម្មក្នុងការវិនិយោគ និងការអភិវឌ្ឍន៍ក្រុមហ៊ុនទាំងពីរ។ លោកជាសហគ្រិនដ៏ឆ្នើម និងជាអ្នកដឹកនាំដ៏គួឱ្យគោរពក្នុងប្រទេសកម្ពុជា និងប្រទេសកាណាដា។ អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ បានបម្រើការងារជាប្រធាន ក្រុមប្រឹក្សាភិបាល ប្រធាននាយកប្រតិបត្តិ និងអភិបាលរបស់ក្រុមហ៊ុនជាច្រើនមានដូចជា៖ Oriental Ship Supplies, Oriental , Commercial Inc, ហើយលោកបានដឹកនាំ ធនាគារ កាណាឌីយ៉ា ឱ្យរីកចម្រើនចាប់តាំងពី ឆ្នាំ១៩៩១។ បន្ថែមពីនេះទៅទៀត លោកធ្លាប់កាន់តួនាទីជាប្រធានសមាគមធនាគារដោយធ្វើការជិតស្និទ្ធជាមួយថ្នាក់ដឹកនាំនានាក្នុងវិស័យទាំងនេះដើម្បីធ្វើការអភិវឌ្ឍន៍វិស័យធនាគារ និងសំណង់នៅក្នុងប្រទេសកម្ពុជាផងដែរ។

អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែទទួលបានពានរង្វាន់កិត្តិយសថ្នាក់ មហាសិរីវឌ្ឍនៈពីព្រះករុណាព្រះបាទ នរោត្តមសីហនុ ក្នុងឆ្នាំ២០០២ និងទទួលបានមេដៃស្ថាបនាជាតិថ្នាក់លេខមួយដែលប្រគល់ដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្រោមអធិបតីភាពរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០១២។ សម្រាប់ការចូលរួមដ៏សំខាន់ដែលលោកបានធ្វើ និងកំពុងបន្តធ្វើឱ្យមានការឆ្ពោះទៅរកការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា។

នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ លោកបានទទួលគោរមងារកិត្តិយសជា អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវស ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្នុងពិធីសម្ពោធអគារឥន្ទ្រទេវីនៃរាជ បណ្ឌិតសភាកម្ពុជា។

សមាជិក និងប្រវត្តិក្រុមប្រឹក្សាភិបាល



## លោក Teo Meng Poh Philip

**អនុប្រធានក្រុមប្រឹក្សាភិបាល**

លោក Teo គ្រប់គ្រងលើផ្នែកហានិភ័យផ្សេងៗនៃសិទ្ធិធុរកិច្ចរបស់ Fullerton Invesment Holding Pte Ltd, នៅក្នុងប្រទេសចិន និងឥណ្ឌូចិន។ ក្នុងតួនាទីមួយនេះ លោក Teo ក៏ទទួលខុសត្រូវបន្ថែមលើការគ្រប់គ្រងហានិភ័យប្រតិបត្តិការសវនកម្ម និងអនុលោមភាពរបស់ Fullerton Invesment Holding Pte Ltd, រួមទាំងការកំណត់គោលនយោបាយ និងក្របខ័ណ្ឌអភិបាលកិច្ច។ គាត់ក៏ជាអ្នកដឹកហានិភ័យសម្រាប់សកម្មភាពតាមដាន និងវាយតម្លៃ។

មុនពេលចូលរួមជាមួយ Fullerton Invesment Holding Pte Ltd, លោក Teo គឺជានាយកប្រតិបត្តិសវនកម្មអតិថិជន និងហិរញ្ញវត្ថុសាជីវកម្ម Standard Chartered Bank។ លោក Teo បានចាប់ផ្តើមអាជីពរបស់គាត់ជាមួយសាជីវកម្មធនាគារនៅក្រៅប្រទេសចិន ដែលមានតួនាទីជាន់ខ្ពស់ទទួលខុសត្រូវចំពោះអតិថិជននៅក្នុងសិទ្ធិអាជីវកម្មក្រៅប្រទេសរបស់ធនាគារ សៀងហៃ និងបាងកក។



## លោក តូច ចៅចេក

**អភិបាល**

លោក តូច ចៅចេក មានបទពិសោធជាង ២១ឆ្នាំ ក្នុងវិស័យធនាគារ និង ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ លោកធ្លាប់បម្រើការងារជាបុគ្គលិក ជាន់ ខ្ពស់និងជានាយកប្រតិបត្តិក្នុងអគ្គនាយកដ្ឋានឥណទាន នៃធនាគារ អេស៊ីលីដា មុនពេលដែលលោកបានចូលបម្រើការងារជាអនុប្រធាន នាយកប្រតិបត្តិ និងប្រធាននាយកប្រតិបត្តិប្រតិបត្តិការរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ហត្ថាកសិករលីមីតធីត ទទួលខុសត្រូវទាំងស្រុងទៅលើ ប្រតិបត្តិការអាជីវកម្មរបស់ គ្រឹះស្ថានមានដូចជា៖ ការគ្រប់គ្រប់សំពាធ ឥណទាន ការកេណ្ឌប្រមូលប្រាក់បញ្ញើសន្សំ ការអភិវឌ្ឍន៍អាជីវកម្ម និងការគ្រប់គ្រងសាខា។ ក្រៅពីវិស័យធនាគារ និងហិរញ្ញវត្ថុនេះ លោកធ្លាប់បម្រើការងារក្នុងវិស័យផលិតកម្មអស់រយៈពេល២ឆ្នាំ ដែលមានតួនាទីជានាយកប្រតិបត្តិទីផ្សារ។ បច្ចុប្បន្ននេះ លោកក៏ជាសមាជិកក្រុមប្រឹក្សាភិបាល របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វូណាន ផងដែរ ចាប់តាំងពីពេលទិញ គ្រឹះស្ថាននេះមក ។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកធនាគារ និងហិរញ្ញវត្ថុ ពី សាកលវិទ្យាល័យកម្ពុជាក្នុងឆ្នាំ២០០៦ និងបានបញ្ចប់ថ្នាក់ អនុបណ្ឌិតផ្នែកទីផ្សារពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាធារណៈក្នុងឆ្នាំ១៩៩៩ ហើយលោកក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្ររងផ្នែកវិជ្ជាជីវៈ ច្បាប់ក្នុងឆ្នាំ១៩៩៦ ពីសាកលវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ចផងដែរ ។

លោក តូច ចៅចេក បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលក្នុងស្រុក និង អន្តរជាតិជាច្រើនលើផ្នែក ធនាគារ និងហិរញ្ញវត្ថុ ដែលភាគច្រើនផ្តោតសំខាន់ទៅលើ ភាពជាអ្នកដឹកនាំ ការគ្រប់គ្រងការងារ និងការគ្រប់គ្រងហានិភ័យជាដើម...។ល។

# សមាជិក និងប្រវត្តិក្រុមប្រឹក្សាភិបាល



**លោក Giang Sovann**

**អភិបាលឯករាជ្យ**

លោក Giang ជាស្ថាបនិក និងជាប្រធាននាយកប្រតិបត្តិរបស់ Corporate Governance Atidimy និងជាសមាជិកគណៈកម្មាធិការវិន័យ និងដោះស្រាយបណ្តឹងរបស់ក្រុមហ៊ុន Public Accourtits Oversight Committee, Accounting & Corporate Regulatory Authority (ACRA) and Singapore ហើយលោកក៏ជានាយកក្រុមហ៊ុន ដែលបានចុះបញ្ជីជាមួយ ទីផ្សារភាគហ៊ុនស័ព្ទ។

លោក Giarg ជានាយកប្រតិបត្តិ Singapore Institute of Directors ជាកន្លែងដែលគាត់ដើរតួនាទី ជាគណៈកម្មាធិការរៀបចំរង្វាន់ សម្រាប់ក្រុមហ៊ុនសិង្ហបុរី និងជាសហប្រធានគ្រប់គ្រងចាត់ចែងពានរង្វាន់សម្រាប់ក្រុមហ៊ុនសិង្ហបុរីដែលបានចុះបញ្ជី។ លោកក៏ជាគ្រូបង្ហាត់លើមុខវិជ្ជាការទទួលខុសត្រូវ និងភារកិច្ចទទួលខុសត្រូវការចុះបញ្ជីភាគហ៊ុនសិង្ហបុរី ស្តីអំពីអភិបាលកិច្ចសាជីវកម្ម។ លោកបានសរសេរអត្ថបទជាច្រើនស្តីអំពីក្រុមប្រឹក្សាភិបាល ការគ្រប់គ្រងផ្ទៃក្នុង និងសកម្ម ហើយគាត់បានបម្រើការងារជាអ្នកដឹកនាំឯករាជ្យ ប្រធាននៃគណៈកម្មាធិការសវនកម្ម ប្រធាននៃគណៈកម្មាធិការគ្រប់គ្រហានីភ័យកម្រិតក្រុមប្រឹក្សាភិបាល សមាជិកគណៈកម្មាធិការជ្រើសតាំង នឹងគណៈកម្មាធិការវាយតម្លៃ ការចុះបញ្ជីរបស់ក្រុមហ៊ុន។

លោក Giang បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលដោយទទួលបានលទ្ធផលល្អប្រសើរមកពី University of Ragra ប្រទេសកាណាដា និងលោកជាអ្នកជំនាញគណនេយ្យរបស់ Canadian Institute of Chartered Accountants។ លោកក៏ជាគណនេយ្យករ និងសមាជិករបស់ Singapore Institute of Directors។

# សមាជិក និងប្រវត្តិក្រុមប្រឹក្សាភិបាល



**លោក Neo Poh Kiat**

**អភិបាលឯករាជ្យ**

បច្ចុប្បន្ននេះ លោក Neo គឺជានាយកគ្រប់គ្រង ក្រុមហ៊ុន Advisory Services of Octagon Advisors លោកបានចូលរួមយ៉ាងសកម្មជាមួយអតិថិជនលើជំនាញ M & A នៅក្នុងតំបន់។ លោកធ្លាប់ធ្វើជានាយក ប្រតិបត្តិនៃក្រុមហ៊ុនផ្តល់ប្រឹក្សាយោបល់ឈ្មោះ : Octagon Advisors Sanghai Limited, ដោយទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងពិគ្រោះយោបល់រាល់គម្រោងនានារបស់ក្រុមហ៊ុន ដែលមានមូលដ្ឋាននៅទីក្រុងប៉េកាំង ប្រទេសចិន។

មុនចូលបម្រើការងារជាទីប្រឹក្សា Octagon លោក Neo ជាអនុប្រធាននាយកជាន់ខ្ពស់ និងជា មន្ត្រីទំនាក់ទំនង ប្រទេស ចិននៃធនាគារ Singapore´s United Overseas Bank។ លោកជាអ្នក ទទួលខុសត្រូវផ្នែកទំនាក់ទំនងក្រុមហ៊ុន និងសាជីវកម្មរបស់ធនាគារUCE ដែលមានមូលដ្ឋាននៅទីក្រុង ហុងកុង(Great China Region) ។

មុនពេលដែលលោកបម្រើ ការងារក្នុង UOB លោក Neoកាន់តួនាទីជាច្រើនក្នុងធនាគារDBS ហើយតួនាទីចុងក្រោយរបស់លោកគឺជានាយកគ្រប់គ្រងនិងចាត់ការទូទៅរបស់ធនាគារDBSសាខា ហុងកុង។ ទន្ទឹមនឹងនេះ លោកក៏ធ្លាប់ជានាយកប្រតិបត្តិនិងជាសមាជិកនៃគណៈកម្មាធិការនាយក នៃធនាគារ DBS Kwong. និងជានាយកគ្រប់គ្រងក្រុមហ៊ុនវិនិយោគ DBS Asia Capital Limited ដែលជាបុត្រសម្ព័ន្ធរបស់ធនាគារ DBS ក្នុងទីក្រុងហុងកុង។ លោកចូលរួមយ៉ាងសកម្មនៅក្នុងការបង្កើត ក្រុមហ៊ុន DBS Securities Hong Kong និងក្រោយមកលោកបានក្លាយជានាយកគ្រប់គ្រងនាដើម ទសវត្សរ៍៩០។ លោក Neoទទួលបានបរិញ្ញាបត្រពាណិជ្ជកម្ម (Honours) ពីអតីត Nanyang University ប្រទេសសិង្ហបុរី។

# គណៈគ្រប់គ្រង



## លោក យូ ប៊ុនទ្រី

### ប្រធាននាយកប្រតិបត្តិ

លោក យូ ប៊ុនទ្រី មានបទពិសោធន៍ជាង ២១ឆ្នាំ នៅក្នុងវិស័យហិរញ្ញវត្ថុ មុនចូលបម្រើការងារជាមួយហ្វូណនមីក្រូហិរញ្ញវត្ថុភីអិលស៊ី លោកបានឆ្លងកាត់តួនាទីជាច្រើន រួមមាន ជាប្រធាននាយក ប្រតិបត្តិហិរញ្ញវត្ថុ នៃធនាគារប្រៃសណីយ៍កម្ពុជា ក.អ រយៈពេល ៤ឆ្នាំ ជានាយកហិរញ្ញវត្ថុ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ រយៈពេល ៥ឆ្នាំ លោកធ្លាប់បម្រើការងារនៅអង្គការ Room to Read Cambodia ជានាយកហិរញ្ញវត្ថុ រយៈពេល ២ឆ្នាំ ធ្លាប់ជានាយកហិរញ្ញវត្ថុនៅ Marie Stopes Cambodia រយៈពេល ៤ឆ្នាំ និង ធ្លាប់ជាគណនេយ្យករ នៅធនាគារកាណាឌីយ៉ា ២ឆ្នាំ ហើយនៅ Medecine Sans Frontier រយៈពេល១ឆ្នាំ។ លោកបានបញ្ចប់ការសិក្សាថ្នាក់ អនុបណ្ឌិតហិរញ្ញវត្ថុនៅសាកលវិទ្យាល័យ Charles Sturt នៅប្រទេសអូស្ត្រាលី និងថ្នាក់បរិញ្ញាប័ត្រគណនេយ្យនៅសកលវិទ្យាល័យជាតិ គ្រប់គ្រង (អតីតមហាវិទ្យាល័យពាណិជ្ជកម្ម)។



## លោក ហាន ប៊ុនហុន

### ប្រធាននាយកប្រតិបត្តិអាជីវកម្ម

លោកហាន ប៊ុន ហុន បាននឹងកំពុងបម្រើការងារក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុចាប់តាំងពីឆ្នាំ២០០៥មក ពោលគឺលោកទទួលបានបទពិសោធជាង ១៦ឆ្នាំក្នុងវិស័យនេះ។ លោកបានចូលរួមជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងតួនាទីជាប្រធានយកប្រតិបត្តិអាជីវកម្ម ចាប់តាំងពីខែ មិថុនា ឆ្នាំ២០១៧មក។ មុនចាប់ផ្តើមបម្រើការងារជាមួយហ្វូណនពោលចាប់ពីឆ្នាំ២០១៣មកលោកមានបទពិសោធន៍ជាង៤ឆ្នាំជាមួយ ធនាគារប្រៃសណយ៍កម្ពុជា ក.អ ក្នុងតួនាទីជាច្រើនរួមមាន ជានាយកសាខានៃការិយាល័យកណ្តាល ហើយបន្ទាប់មកត្រូវបានតម្លើងតួនាទីជានាយកគ្រប់គ្រងការលក់នៃធនាគារ ដែល ទទួលខុសត្រូវទាំងផ្នែកប្រាក់កម្ចី និងការប្រមូលប្រាក់បញ្ញើរសន្សំ។

លោកចាប់ផ្តើមបម្រើការងារក្នុងវិស័យហិរញ្ញវត្ថុ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវីសិនហ្វាន់កម្ពុជា(បច្ចុប្បន្ន WB Finance) ដែលដំបូងឡើយជាមន្រ្តីឥណទាន បន្ទាប់មកត្រូវបានតម្លើងតួនាទីជាបន្តបន្ទាប់ជា នាយកសាខាស្រុក នាយកសាខាខេត្ត(តួនាទីនេះបច្ចុប្បន្នត្រូវបានស្គាល់ជានាយកតំបន់) ក្នុងឆ្នាំ២០០៨ និងជានាយកសាខាខេត្តជាន់ខ្ពស់ (តួនាទីនេះបច្ចុប្បន្នត្រូវបានស្គាល់ជានាយកតំបន់ជាន់ខ្ពស់)ក្នុងឆ្នាំ២០១០ ដែលក្នុងតួនាទីនេះ លោកគ្រប់គ្រងសាខាស្រុកជាច្រើន ។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម និងទទួលបានបរិញ្ញាបត្រផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលលើភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងនានាខាងក្នុងប្រទេស និងខាងក្រៅប្រទេសជាអាទិ៍ យុទ្ធសាស្រ្តនៃគ្រប់គ្រងហានិភ័យឥណទាន (កម្រិត១) និងកំពុងចូមរួមវគ្គបណ្តុះបណ្តាលលើផ្នែកអ្នជំនាញមីក្រូហិរញ្ញវត្ថុ នៃសាលា Frankfurt.



## លោក មាង ឈុនអេង

### នាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង

លោក មាង ឈុនអេង មានបទពិសោធន៍ជាមួយវិស័យហិរញ្ញវត្ថុរយៈពេលជាង១៥ឆ្នាំ ក្នុងតួនាទីជាច្រើនរួមមាន ជានាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង រយៈពេល៧ឆ្នាំជាមួយ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។ មុនពេលលោកបម្រើការងារជាមួយ ហ្វូណនលោកបានបម្រើការងារជាសវនករផ្ទៃក្នុងរយៈពេល៥ឆ្នាំនិងជាមន្ត្រីឥណទានរយៈពេល៣ឆ្នាំជាមួយគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុប្រាសាក់។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ និង បរិញ្ញាបត្រផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ។

# គណៈគ្រប់គ្រង

## លោក ម៉ឹង សារ៉ុង

### នាយកប្រតិបត្តិហិរញ្ញវត្ថុ

លោក ម៉ឹង សារ៉ុង ចូលបម្រើការងារជាមួយ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក្នុងមុខតំណែងជា នាយកប្រតិបត្តិហិរញ្ញវត្ថុនៅខែកក្កដា ឆ្នាំ២០១៨។ មុនចូលបម្រើការងារជាមួយ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី លោកបានបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លីហ្សូ ក្នុងតួនាទីជា នាយករងនាយកដ្ឋានហិរញ្ញវត្ថុ។ គាត់មានបទពិសោធន៍ការងារជាង ៩ឆ្នាំ ក្នុងផ្នែកគណនេយ្យ និង ហិរញ្ញវត្ថុ (ភាគច្រើននៅក្នុងវិស័យហិរញ្ញវត្ថុ) ដែលបានផ្តល់ឱ្យគាត់នូវបទពិសោធន៍យ៉ាងទូលំទូលាយក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ការធ្វើ និងគ្រប់គ្រងផែនការហិរញ្ញវត្ថុ ការរៀបចំគម្រោងថវិការ និងអាជីវកម្ម និងការគ្រប់គ្រងផ្នែករតនាភិបាល។

លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រលើផ្នែកគណនេយ្យ និង ភាសាអង់គ្លេស ហើយថ្មីៗនេះ គាត់ទើបបញ្ចប់ការសិក្សាគណនេយ្យជំនាញ ACCA ជាស្ថាពរពី វិទ្យាស្ថានខេមអេដ។



## លោក គង់ វណ្ណៈ

### នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ

លោក គង់ វណ្ណៈ មានបទពិសោធន៍ជាង ១៣ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ នៅក្នុងតួនាទីជាច្រើន ជាមួយហ្វូណនលោកកាន់តួនាទីជា នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ។ មុនពេលបម្រើការងារជាមួយ ហ្វូណន លោកធ្លាប់បានបម្រើការងារ ធនាគារ ប្រៃណីយ៍កម្ពុជា ក.អ ក្នុងតួនាទីជានាយកឥណទាន ។ លោកធ្លាប់បម្រើការងារនៅក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ លីហ្សូ រយៈពេល២ឆ្នាំជានាយកនាយកដ្ឋានឥណទាន បន្ទាប់មកលោកបានចូលបម្រើការងារជានាយកសាខារង រយៈពេល២ឆ្នាំនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ។

លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រគណេយ្យ និងភាសាអង់គ្លេស។



## លោក វង ពណ្ណរាយ

### នាយកប្រតិបត្តិធនធានមនុស្ស & រដ្ឋបាល

លោក វង ពណ្ណរាយ ធ្លាប់មានបទពិសោធន៍ផ្នែកធនធានមនុស្ស និងរដ្ឋបាលរយៈពេល ១២ឆ្នាំ ដោយចាប់ផ្តើម តំណែងពីមន្រ្តីផ្នែកធនធានមនុស្ស រហូតដល់ក្លាយជានាយក នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល ។ នៅក្នុងកំឡុងពេល ១២ឆ្នាំនេះ លោកបានធ្វើការ និងទទួលបានបទពិសោធន៍ពីក្រុមហ៊ុនផ្សេងៗគ្នាចំនួន ០៥ក្រុមហ៊ុន ដូចជា៖ អង្គការអន្តរជាតិ Hagar ចំនួន ០៣ឆ្នាំជា ប្រធានផ្នែកជ្រើសរើសបុគ្គលិក ក្រុមហ៊ុនHuawei Cambodia ចំនួន ០២ឆ្នាំ ជាអ្នកជំនាញផ្នែកជ្រើសរើសបុគ្គលិក ទំនាក់ទំនងបុគ្គលិក និងបណ្តុះបណ្តាល ក្រុមហ៊ុន Tan Chong Motor ចំនួន ០២ឆ្នាំ ជានាយករងផ្នែកធនធានមនុស្ស ក្រុមហ៊ុន British American Tobacco ចំនួន ០២ឆ្នាំ ជានាយកផ្នែកសេវាកម្មបុគ្គលិក និងប្រធានផ្នែកធនធានមនុស្សនៅនាយកដ្ឋានប្រតិបត្តិការ និង ក្រុមហ៊ុន Newa Insurance ចំនួនជិតពីរឆ្នាំ ជានាយកនាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល ។

លោកក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ និង អនុបណ្ឌិតពាណិជ្ជកម្ម។



# របាយការណ៍លទ្ធផល




- របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល
- របាយការណ៍របស់សវនករឯករាជ្យ
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- របាយការណ៍លទ្ធផលលម្អិត
- របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
- របាយការណ៍លំហូរទឹកប្រាក់
- កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្សរីករាយ ធ្វើការបង្ហាញជូននូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ ហិរញ្ញវត្ថុរបស់ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗ ជូនអតិថិជនក្នុងស្រុក តាមរយៈទីស្នាក់ការកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងសាខាតាមបណ្តាខេត្ត និងស្រុកមួយចំនួនទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០ មានដូចខាងក្រោម៖

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| ប្រាក់ចំណេញមុនបង់ពន្ធ | ៣,២៧៧,២៥៦ | ៣,៧១០,១៦២ | ១៣,៣៦១,៣៧២ | ១៥,០៣៣,៥៧៧ |
| ពន្ធលើប្រាក់ចំណេញ | (៨២៨,៣៨៥) | (៧៤៩,៥១៤) | (៣,៣៧៧,៣២៦) | (៣,០៣៧,០៣១) |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ២,៤៤៨,៨៧១ | ២,៩៦០,៦៤៨ | ៩,៩៨៤,០៤៦ | ១១,៩៩៦,៥៤៦ |

## ដើមទុន

មិនមានការផ្លាស់ប្តូររចនាសម្ព័ន្ធភាគហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនោះទេ។ សូមមើលកំណត់សម្គាល់ ១៦សម្រាប់ ព័ត៌មានលម្អិត។

## ភាគលាភ

គ្មានភាគលាភត្រូវបានប្រកាសឬបង់ហើយអភិបាលមិនណែនាំអោយបែងចែកភាគលាភណាមួយដែលត្រូវបង់សម្រាប់ការិយបរិច្ឆេទទេ ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុនេះ ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ សមស្របដើម្បីបញ្ជាក់ថា វិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទាន និងបុរេប្រទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់ឥណទានដែលបានដឹងថាមិនអាចទារបាន ត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់លើការបាត់បង់ឥណទាន និងបុរេប្រទាន ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយ ដែលអាចនឹងបណ្តាលឲ្យ ចំនួននៃការលុបបំបាត់ចោលឥណទាននិងបុរេប្រទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើការបាត់បង់ឥណទាន និងបុរេប្រទានក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានចំនួនខ្វះខាតជាសារវន្តនោះឡើយ ។

## ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្ម លើកលែងឥណទាន ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលសន្និដ្ឋានថា មានតម្លៃមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការ អាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថា នឹងអាចប្រមូលបានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់ តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថា មានភាពមិនត្រឹមត្រូវនោះទេ ។



# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រ ដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថា មានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ ។

## បំណុលយថាភាព និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្នុងការធានា ចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមមហ៊ុន ។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលក្រុមហ៊ុន ត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែបន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទ នឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ ។

## ព្រឹត្តិការណ៍ក្រោយពីកាលបរិច្ឆេទនៃរបាយការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ពុំមានហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការក្នុងអំឡុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| **អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ** | **ប្រធានក្រុមប្រឹក្សាភិបាល** |
| **លោក Teo Meng Poh Philip** | **អនុប្រធានក្រុមប្រឹក្សាភិបាល** |
| **លោក Neo Poh Kiat** | **អភិបាលឯករាជ្យ** |
| **លោក Giang Sovann** | **អភិបាលឯករាជ្យ** |
| **លោក តូច ចៅចេក** | **អភិបាល** |

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមាន ផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈមិនប្រក្រតី នោះទេ ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងដំណាច់ឆ្នាំ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ លើកលែងការផ្ទុះឡើងនៃ ការរីវរាលដាលនៃជំងឺ("កូវីដ-១៩") ។

ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាលពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់កាន់កាប់ ឬមានការទាក់ទិននៅក្នុងភាគហ៊ុនរបស់ក្រុមហ៊ុនដោយផ្ទាល់ ឬដោយប្រយោល នៅក្នុងការិយបរិច្ឆេទហិរញ្ញ វត្ថុនេះទេ ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាល ណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មដទៃ ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមុន ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់របស់ក្រុមហ៊ុនបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុប ទទួលបាន ឬដល់កំណត់ទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន ដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវនៃ ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណ យ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព ។

(ខ) អនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ឬប្រសិន បើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(គ) រក្សាកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាង ព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់ មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការ ក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាព លើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ ទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមប្រឹក្សាភិបាលបានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់មកជាមួយដូចដែលបានបង្ហាញនៅទំព័រទី 10 ដល់ទី 50 ថាបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ។

ចុះហត្ថលេខាជំនួសឲ្យក្រុមប្រឹក្សាភិបាល

**អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ**

**ប្រធានក្រុមប្រឹក្សាភិបាល**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០២១

**លោក ឃូ ប៊ុនទ្រី**

**ប្រធាននាយកប្រតិបត្តិ**



# របាយការណ៍របស់សវនករឯករាជ្យ

## មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី ១០ ដល់ទី ៥០ (ដែលហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ") ។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធនតូច និងមធ្យម ។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ការទទួល ខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុង កថាខណ្ឌ ស្តីពី ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុនដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតម្រូវ ការរបស់ស្តង់ដារទាំងនោះ ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមាន លក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទនៃ របាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី ១ ដល់ទី ៦ ប៉ុន្តែមិនមានរួមបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករនោះទេ។

មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗទ្បើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអាន ព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុងឆ្គងជាសារវន្ត ។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះយើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង ។

យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗ នេះទេ ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយ អនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាស់ធនតូច និងមធ្យម ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយ ដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរ ភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

## ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការ បង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិសវនកម្មរបស់យើងខ្ញុំ ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាអាចរកឃើញនូវកាបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ កាបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារ ការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការ វិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម ។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជា សារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជា មូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែល

# របាយការណ៍របស់សវនករឯករាជ្យ

កើតឡើងដោយសារតែការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុស ឆ្គង ដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ។

- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បី រៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិ លើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។

- ការវាយតម្លៃលើភាពសមស្រប នៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុន បានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង ។

- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃ ការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជា សារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអស្ថិរភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ យ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម ។

- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំង ការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀត វិសាលភាព និងពេលវេលា ដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំង ចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**

**តាំង យុកហ្វុង**

**Partner**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២១



# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ពាន់រៀល (កំណត់សម្គាល់ ៥) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៦ | ៣,៤២៤,៧២៧ | ១,៦៣៤,៨៩៧ | ១៣,៨៥៣,០២១ | ៦,៦៦២,២០៥ |
| ប្រាក់តម្កល់តាមច្បាប់ | ៧ | ៤០០,០០០ | ៤០០,០០០ | ១,៦១៨,០០០ | ១,៦៣០,០០០ |
| ឥណទានផ្តល់ដល់អតិថិជន - សុទ្ធ | ៨ | ៥៦,០១៦,១៣០ | ៥៥,៧៧៩,០២៣ | ២២៦,៥៨៥,២៤៦ | ២២៧,២៩៩,៥១៩ |
| ទ្រព្យសកម្មផ្សេងៗ | ៩ | ៤១១,១៧០ | ៣៨២,៧៨២ | ១០,៦៦៣,១៨៣ | ១,៥៥៩,៨៣៧ |
| ទ្រព្យ និងបរិក្ខារ | ១០ | ៧៧៥,១៩៦ | ៥៩៩,១០៦ | ៣,១៣៥,៦៦៨ | ២,៤៤១,៣៥៧ |
| ទ្រព្យសកម្មអរូបី | ១១ | ៥២,០៨៧ | ១០៥,៥៤៥ | ២១០,៦៩២ | ៤៣០,០៩៦ |
| ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ | ១៥ | ២៥២,២៨៤ | ៤៤១,៧៧៩ | ១,០២០,៤៨៩ | ១,៨០០,២៤៩ |
| **ទ្រព្យសកម្មសរុប** | | **៦១,៣៣១,៥៩៤** | **៥៩,៣៤៣,១៣២** | **២៤៨,០៨៦,២៩៩** | **២៤១,៨២៣,២៦៣** |
| **បំណុល និងមូលធនបំណុល** | | | | | |
| ប្រាក់កម្ចី | ១២ | ៤៤,៤២១,៤៩៧ | ៤៤,៧៨៩,៨៨៩ | ១៧៩,៦៨៤,៩៥៥ | ១៨២,៥១៨,៧៩៨ |
| បំណុលផ្សេងៗ | ១៣ | ៨១២,២៦៤ | ៦៩២,២១៥ | ៣,២៨៥,៦០៨ | ២,៨២០,៧៧២ |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | ១៤ | ៤៣,១៧០ | ៥៣,៥២៤ | ១៧៤,៦២៣ | ២១៨,១១០ |
| បំណុលពន្ធលើប្រាក់ចំណេញ | ១៥ | ៥១៥,១៦៣ | ៧១៦,៨៧៥ | ២,០៨៣,៨៣៤ | ២,៩២១,២៦៦ |
| **បំណុលសរុប** | | ៤៥,៧៩២,០៩៤ | ៤៦,២៥២,៥០៣ | ១៨៥,២២៩,០២០ | ១៨៨,៤៧៨,៩៤៦ |
| **មូលធន** | | | | | |
| ដើមទុន | ១៦ | ៨,០០០,០០០ | ៨,០០០,០០០ | ៣២,២៩៦,០០០ | ៣២,២៩៦,០០០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ១៧ | - | ២៥១,៩៥៩ | - | ១,០១៦,១១៤ |
| ប្រាក់ចំណេញរក្សាទុក | | ៧,៥៣៩,៥០០ | ៤,៨៣៨,៦៧០ | ៣០,៥៩៥,៧២៨ | ១៩,៥៩៥,៥៦៨ |
| លម្អៀងពីការប្តូររូបិយបណ្ណ | | - | - | (៣៤,៤៤៩) | ៤៣៦,៦៣៥ |
| **មូលធនសរុប** | | ១៥,៥៣៩,៥០០ | ១៣,០៩០,៦២៩ | ៦២.៨៥៧.២៧៩ | ៥៣,៣៤៤,៣១៧ |
| **បំណុល និង មូលធនសរុប** | | **៦១,៣៣១,៥៩៤** | **៥៩,៣៤៣,១៣២** | **២៤៨,០៨៦,២៩៩** | **២៤១,៨២៣,២៦៣** |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០១៩ ដុល្លារអាមេរិក | ២០២០ ពាន់រៀល (កំណត់សម្គាល់ ៥) | ២០១៩ ពាន់រៀល (កំណត់សម្គាល់ ៥) |
|---|---|---|---|---|---|
| **ចំណូលពីប្រតិបត្តិការ** | | | | | |
| ចំណូលពីការប្រាក់ | ១៨ | ១២,៨៦៣,៩៩៩ | ១២,១៩១,០៧២ | ៥២,៤៤៦,៣៦១ | ៤៩,៣៩៨,២២៤ |
| ចំណាយលើការប្រាក់ | ១៩ | (៣,៧៣៥,០២២) | (៣,១២៥,៩១៥) | (១៥,២២៧,៦៨៥) | (១២,៦៦៦,២០៨) |
| ចំណូលការប្រាក់- សុទ្ធ | | ៩,១២៨,៩៧៧ | ៩,០៦៥,១៥៧ | ៣៧,២១៨,៦៧៦ | ៣៦,៧៣២,០១៦ |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | ២០ | ៤៤៧,៦៥៩ | ៣៧៤,៩៨៩ | ១,៨២៥,២០៦ | ១,៥១៩,៤៥៥ |
| **ចំណេញពីប្រតិបត្តិការសុទ្ធ** | | ៩,៥៧៦,៥៦៦ | ៩.៤៤០,១៤៦ | ៣៩,០៤៣,៨៨២ | ៣៨,២៥១,៤៧១ |
| ខាតបង់លើឱនភាពនៃតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ-សុទ្ធ | ២១ | (៦១៧,០៩៩) | (៣៦៧,៥០៤) | (២,៥១៥,៩១៣) | (១,៤៨៩,១២៦) |
| ចំណាយលើបុគ្គលិក | ២២ | (៣,២៥៤,៩០៤) | (៣,១៣១,១៩៧) | (១៣,២៧០,២៤៤) | (១២,៦៨៧,៦១០) |
| ចំណាយផ្សេងៗ | ២៣ | (២,៤២៧,៣៣៧) | (២,២៣១,២៨៣) | (៩,៨៩៦,២៥៣) | (៩,០៤១,១៥៨) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | ៣,២៧៧,២៥៦ | ៣,៧១០,១៦២ | ១៣,៣៦១,៣៧២ | ១៥,០៣៣,៥៧៧ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១៥ | (៨២៨,៣៨៥) | (៧៤៩,៥១៤) | (៣,៣៧៧,៣២៦) | (៣,០៣៧,០៣១) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | ២,៤៤៨,៨៧១ | ២,៩៦០,៦៤៨ | ៩.៩៨៤,០៤៦ | ១១,៩៩៦,៥៤៦ |
| លទ្ធផលលម្អិតផ្សេងៗ | | | | | |
| លម្អៀងលើការប្តូររូបិយប័ណ្ណ | | - | - | (៤៧១,០៨៤) | ៦៤៥,៤៧៥ |
| លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ | | | | | |
| **ទ្រព្យសកម្មសរុប** | | ២,៤៤៨,៨៧១ | ២,៩៦០,៦៤៨ | ៩,៥១២,៩៦២ | ១២,៦៤២,០២១ |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។



# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

| | ដើមទុន ដុល្លារអាមេរិក | ដើមទុន ពាន់រៀល (កំណត់សម្គាល់ ៥) | ទុនបម្រុងតាមបទប្បញ្ញត្តិ ដុល្លារអាមេរិក | ទុនបម្រុងតាមបទប្បញ្ញត្តិ ពាន់រៀល (កំណត់សម្គាល់ ៥) | ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក | ប្រាក់ចំណេញរក្សាទុក ពាន់រៀល (កំណត់សម្គាល់ ៥) | លម្អៀងពីការប្តូររូបិយប័ណ្ណ ដុល្លារអាមេរិក | លម្អៀងពីការប្តូររូបិយប័ណ្ណ ពាន់រៀល (កំណត់សម្គាល់ ៥) | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល (កំណត់សម្គាល់ ៥) |
|---|---|---|---|---|---|---|---|---|---|---|
| នាថ្ងៃទី1 ខែ មករា ឆ្នាំ២០១៩ | ៨,000,000 | ៣២,២៩៦,000 | ២៧៩,៤៥៣ | ១.១២៨.១៥២ | ១,៨៥០,៥២៨ | ៧,៤៨៦,៩៨៤ | - | (២០៨,៨៤០) | ១០,១២៩,៩៨១ | ៤០,៧០២,២៩៦ |
| **លទ្ធផលលម្អិតសរុប** | | | | | | | | | | |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | ២,៩៦០,៦៤៨ | ១១,៩៩៦,៥៤៦ | - | - | ២,៩៦០,៦៤៨ | ១១,៩៩៦,៥៤៦ |
| ការផ្ទេរទុនបម្រុងតាមបទប្បញ្ញត្តិ | | | (២៧,៤៩៤) | (១១២.០៣៨) | ២៧,៤៩៤ | ១១២,០៣៨ | - | - | - | - |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | | | | | | |
| លម្អៀងលើការប្តូរបិយប័ណ្ណ | - | - | - | - | - | - | - | ៦៤៥,៤៧៥ | - | ៦៤៥,៤៧៥ |
| | - | - | (២៧,៤៩៤) | (១១២.០៣៨) | ២,៩៨៨,១៤២ | ១២,១០៨,៥៨៤ | - | ៦៤៥,៤៧៥ | ២,៩៦០,៦៤៨ | ១២,៦៤២,០២១ |
| **នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ ២០១៩** | ៨,000,000 | ៣២,២៩៦,000 | ២៥១,៩៥៩ | ១,០១៦,១១៤ | ៤,៨៣៨,៦៧០ | ១៩,៥៩៥,៥៦៨ | - | ៤៣៦,៦៣៥ | ១៣,០៩០,៦២៩ | ៥៣,៣៤៤,៣១៧ |
| នាថ្ងៃទី1 ខែ មករា ឆ្នាំ២០២០ | ៨,000,000 | ៣២,២៩៦,000 | ២៥១,៩៥៩ | ១.០១៦.១១៤ | ៤,៨៣៨,៦៧០ | ១៩,៥៩៥,៥៦៨ | - | ៤៣៦,៦៣៥ | ១៣,០៩០,៦២៩ | ៥៣,៣៤៤,៣១៧ |
| **លទ្ធផលលម្អិតសរុប** | | | | | | | | | | |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | ២,៤៤៨,៨៧១ | ៩,៩៨៤,០៤៦ | - | - | ២,៤៤៨,៨៧១ | ៩,៩៨៤,០៤៦ |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (២៥១,៩៥៩) | (១.០១៦.១១៤) | ២៥១,៩៥៩ | ១,០១៦,១១៤ | - | - | - | - |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | | | | | | |
| លម្អៀងលើការប្តូរបិយប័ណ្ណ | - | - | - | - | - | - | - | (៤៧១.០៨៤) | - | (៤៧១,០៨៤) |
| | - | - | (២៥១,៩៥៩) | (១,០១៦,១១៤) | ២,៧០០,៨៣០ | ១១,000,១៦០ | - | (៤៧១.០៨៤) | ២,៤៤៨,៨៧១ | ៩,៥១២,៩៦២ |
| **នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ ២០២០** | ៨,000,000 | ៣២,២៩៦,000 | - | - | ៧,៥៣៩,៥០០ | ៣០,៥៩៥,៧២៨ | - | (៣៤.៤៤៩) | ១៥,៥៣៩,៥០០ | ៦២,៨៥៧,,២៧៩ |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

# របាយការណ៍លំហូរទឹកប្រាក់

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ២,៤៤៨,៨៧១ | ២,៩៦០,៦៤៨ | ៩,៩៨៤,០៤៦ | ១១,៩៩៦,៥៤៦ |
| និយ័តភាពលើ: | | | | |
| ចំណូលពីការប្រាក់ | (៩,១២៨,៩៣៧) | (៩,០៦៥,១៥៧) | (៣៧,២១៨,៦៧៦) | (៣៦,៧៣២,០១៦) |
| ខាតបង់លើឱនភាពនៃតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ | ៦១៧,០៩៩ | ៣៦៧,៥០៤ | ២,៥១៥,៩១៣ | ១.៤៨៩,១២៦ |
| រំលស់ | ២៧៥,៤៣០ | ២០៣,១១៩ | ១,១២២,៩២៨ | ៨២៣,០៣៨ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ៨២៨,៣៨៥ | ៧៤៩,៥១៤ | ៣,៣៧៧,៣២៦ | ៣,០៣៧,០៣១ |
| ចំណាយលើប្រយោជន៍របស់និយោជិត | ១៣៣,០៩៩ | ២២.០៧៩ | ៥៤២,៦៤៥ | ៨៩,៤៦៤ |
| | (៤,៨២៦,០៥៣) | (៤,៧៦២,២៩៣) | (១៩,៦៧៥,៨១៨) | (១៩,២៩៦,៨១១) |
| **បម្រែបម្រួលនៃ៖** | | | | |
| ឥណទានផ្តល់ដល់អតិថិជន | (៨៥៤,២០៦) | (៩,៨៦០,១៦៤) | (៣,៤៨២,៥៩៨) | (៣៩,៩៥៣,៣៨៤) |
| ទ្រព្យសកម្មផ្សេងៗ | ២៨,៣៨៨ | (៦៦,០១៤) | ១១៥,៧៣៨ | (២៦៧,៤៨៩) |
| បំណុលផ្សេងៗ | ១២០,០៤៩ | ៤១,៣៧២ | ៤៨៩,៤៤០ | ១៦៧,៦៣៩ |
| សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | (៥,៥៣១,៨២២) | (១៤,៦៤៧,០៩៩) | (២២,៥៥៣,២៣៨) | (៥៩,៣៥០,០៤៥) |
| ការប្រាក់សុទ្ធបានទទួល | ៩,០៧៧,៩៩៧ | ៩,០៤៩,៥២០ | ៣៧,០១០,៩៩៤ | ៣៦,៦៦៨,៦៥៤ |
| អត្ថប្រយោជន៍និយោជិតបានបង់ | (១៤៣,៤៥៣) | (១៣៥,២៨៤) | (៥៨៤,៨៥៨) | (៥៤៨,១៧១) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (៨៤៦,៤៣៨) | (៦៨៤,៩៨៧) | (៣,៤៥០,៩២៨) | (២,៧៧៥,៥៦៧) |
| **សាច់ប្រាក់សុទ្ធទទួលបានពី (ប្រើប្រាស់ក្នុង)** | | | | |
| **សកម្មភាពប្រតិបត្តិការ** | ២,៥៥៦,២៨៤ | (៦,៤១៧,៨៥០) | ១០,៤២១,៩៧០ | (២៦,០០៥,១២៩) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និង បរិក្ខារ | (៣៩៨,០៦២) | (៤៩៧,៤៧៨) | (១,៦២២,៨៩៩) | (២,០១៥,៧៨១) |
| ការទិញទ្រព្យសកម្មអរូបី | - | (៣៨,៥០០) | - | (១៥៦,០០២) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | **(៣៩៨,០៦២)** | **(៥៣៥,៩៧៨)** | **(១,៦២២,៨៩៩)** | **(២,១៧១,៧៨៣)** |



# របាយការណ៍លំហូរទឹកប្រាក់

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| ការទូទាត់សងប្រាក់កម្ចី | (៦,៣៦៨,៣៩២) | (៩៩៥,៥២០) | (២៥,៩៦៣,៩៣៤) | (៤,០៣៣,៨៤៧) |
| សាច់ប្រាក់ទទួលពីកម្ចី | ៦,០០០,០០០ | ៨,៩៦៤,៦៤៤ | ២៤,៤៦២,០០០ | ៣៦,៣២៤,៧៣៧ |
| **សាច់ប្រាក់(ប្រើប្រាស់ក្នុង)/ ទទួលបានពីសកម្មភាព ហិរញ្ញប្បទានសុទ្ធ** | (៣៦៨,៣៩២) | ៧,៩៦៩,១២៤ | (១,៥០១,៩៣៤) | ៣២,២៩០,៨៩០ |
| **ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | ១,៧៨៩,៨៣០ | ១,០១៥,២៩៦ | ៧,២៩៧,១៣៧ | ៤,១១៣,៩៧៨ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី ១ ខែ មករា** | ១,៦៣៤,៨៩៧ | ៦១៩,៦០១ | ៦,៦៦២,២០៥ | ២,៤៨៩,៥៥៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | (១០៦,៣២១) | ៥៨,៦៧០ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | | | |
| **នាថ្ងៃទី ៣១ ខែ ធ្នូ** (កំណត់សម្គាល់ ៦) | | | | |
| **នាថ្ងៃទី ៣១ ខែ ធ្នូ** (កំណត់សម្គាល់ ៦) | **៣,៤២៤,៧២៧** | **១,៦៣៤,៨៩៧** | **១៣,៨៥៣,០២១** | **៦,៦៦២,២០៥** |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។



## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

កំណត់សម្គាល់ខាងក្រោម គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ និងគួរអានរួមនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ជាមួយនេះ ។

### ១. ព័ត៌មានអំពីក្រុមហ៊ុន

ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលត្រូវបាន បង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ក្នុងទម្រង់ជា ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ Co. ២១៣៣ KH/២០១៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ។ ក្រុមហ៊ុន បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រតិបត្តិការជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥ ។

ក្រុមហ៊ុនធ្វើប្រតិបត្តិការក្នុង ៥១ ការិយាល័យ ដែលមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តចំនួន ១៨ រួមមាន ខេត្ត តាកែវ ព្រៃវែង ពោធិ៍សាត់ កំពង់ចាម កំពត សៀមរាប ស្វាយរៀង មណ្ឌលគិរី កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ បន្ទាយមានជ័យ បាត់ដំបង ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងព្រះសីហនុ ។

សកម្មភាពចម្បងៗរបស់ក្រុមហ៊ុន គឺការផ្ដល់កម្ចី តាមរយៈទីស្នាក់ការកណ្ដាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងតាមការិយាល័យផ្សេងៗទៀតរបស់ក្រុមហ៊ុនក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើនកម្រិតជីវភាពរបស់ ប្រជាជនក្នុងបរិបទអភិវឌ្ឍន៍ជនបទ ។

ការិយាល័យកណ្ដាលរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅ អគារលេខ ៩៥មហាវិថីព្រះមុនីវង្ស កែងផ្លូវលេខ 118 សង្កាត់មនោរម្យ ខណ្ឌ7មករា រាជធានីភ្នំពេញ ។

គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ ក្រុមហ៊ុនមានបុគ្គលិកចំនួន៥៤៧ នាក់ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩: ៦២២ នាក់) ។

### ២.មូលដ្ឋាននៃគណនេយ្យ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងដោយអនុលោមទៅ តាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធនតូច និងមធ្យម (ស.រ.ទ.ហ.អ.ក) ។

របាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងផ្ដល់សិទ្ធិផ្សាយនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២១ ។

ព័ត៌មានលម្អិតទាក់ទងនឹងគោលនយោបាយគណនេយ្យសំខាន់ៗរបស់ក្រុមហ៊ុនត្រូវបានលាតត្រដាងក្នុងកំណត់សម្គាល់២៧ ។

### ៣. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការ និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក ។ អ្នកគ្រប់គ្រងក៏បានកំណត់ថា ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងជារូបិយបណ្ណ័សម្រាប់ធ្វើការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន ។ តួលេខទាំងអស់ត្រូវបានបង្គត់ចំនួនមួយដុល្លារអាមេរិក ឬមួយពាន់រៀលដែលជិតបំផុត បើមិនដូច្នេះទេលុះត្រាតែមានការបង្ហាញផ្សេងពីនោះ ។

### ៤. ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោល នយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និង ចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និងការសន្មត់ដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែលើការប៉ាន់ស្មាន ត្រូវបានទទួលស្គាល់តាមវិធិសាស្ត្រទស្សនៈវិស័យ។

ព័ត៌មានអំពីភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន ដែលមានហានិភ័យជាសារវន្ត ដែលអាចធ្វើឲ្យមាននិយ័តភាពនៅក្នុងការិយបរិច្ឆេទ បញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ត្រូវបានកំណត់ដូចខាងក្រោមទាក់ទងនឹង ឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ។

- កំណត់សម្គាល់ ២៧(ឆ)(vii) ៖ ការកំណត់អត្តសញ្ញាណនិងការវាស់វែងលើឱនភាពនៃតម្លៃ ។

### ៥. ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រា នាកាលបរិច្ឆេទរាយការណ៍ ។ របាយការណ៍លទ្ធផលលម្អិត និងរបាយការណ៍លំហូរទឹកប្រាក់ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់ អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា “លម្អៀងពីការប្តូររូបិយប័ណ្ណ” នៅក្នុងរបាយការណ៍លទ្ធផលលម្អិត ។





## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ៥. ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ( ត )

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូររូបិយប័ណ្ណដូចខាងក្រោម៖

| | | | អត្រានាកាលបរិច្ឆេទ<br>រាយការណ៍ | អត្រាមធ្យម |
|---|---|---|---|---|
| ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | ១ ដុល្លារអាមេរិក | = | ៤,០៤៥ រៀល | ៤,០៧៧ រៀល |
| ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ | ១ ដុល្លារអាមេរិក | = | ៤,០៧៥ រៀល | ៤,០៥២ រៀល |

### ៦. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

#### ( ក ) សាច់ប្រាក់ នៅក្នុងដៃ

ថ្ងៃទី ៣១ ខែ ធ្នូ

| | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) | ២០១៩<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) |
|---|---|---|---|---|
| ការិយាល័យកណ្ដាល | ៧,០៣៩ | ១០,៥២៦ | ២៨,៤៧៣ | ៤២,៨៩៣ |
| សាខា | ៣៤៣,៧៨៣ | ៣៣៥,០៧២ | ១,៣៩០,៦០២ | ១,៣៦៥,៤១៩ |
| | ៣៥០,៨២២ | ៣៤៥,៥៩៨ | ១,៤១៩,០៧៥ | ១,៤០៨,៣១២ |

#### ( ខ ) ប្រាក់បញ្ញើនៅធនាគារនានា

| | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) | ២០១៩<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) |
|---|---|---|---|---|
| គណនីសន្សំ | ២,៤៤១,៥៨២ | ១,១០០,២៦១ | ៩,៨៧៦,១៩៩ | ៤,៤៨៣,៥៦៤ |
| គណនីចរន្ត | ៦៣២,៣២៣ | ១៨៩,០៣៨ | ២,៥៥៧,៧៤៧ | ៧៧០,៣២៩ |
| | ៣,០៧៣,៩០៥ | ១,២៨៩,២៩៩ | ១២,៤៣៣,៩៤៦ | ៥,២៥៣,៨៩៣ |
| សាច់ប្រាក់ និងសាច់ប្រាក់ សមមូល- ដុល | ៣,៤២៤,៧២៧ | ១,៦៣៤,៨៩៧ | ១៣,៨៥៣,០២១ | ៦,៦៦២,២០៥ |

### (ខ) ប្រាក់បញ្ញើនៅធនាគារនានា (ត)

ប្រាក់បញ្ញើនៅធនាគារនានា ត្រូវបានវិភាគបន្ថែមដូចខាងក្រោម៖

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| **(i) តាមកាលកំណត់** | | | | |
| ក្នុងរយៈពេល ១ ខែ | ៣,០៧៣,៩០៥ | ១,២៨៩,២៩៩ | ១២,៤៣៣,៩៤៦ | ៥,២៥៣,៨៩៣ |
| **(ii) តាមទំនាក់ទំនង** | | | | |
| ភាគីពាក់ព័ន្ធ | ២,០៤៦,៦៣៣ | ៦៦៣,០៥៣ | ៨,២៧៨,៦៣០ | ២,៧០១,៩៤១ |
| ភាគីមិនពាក់ព័ន្ធ | ១,០២៧,២៧២ | ៦២៦,២៤៦ | ៤,១៥៥,៣១៦ | ២,៥៥១,៩៥២ |
| | ៣,០៧៣,៩០៥ | ១,២៨៩,២៩៩ | ១២,៤៣៣,៩៤៦ | ៥,២៥៣,៨៩៣ |

**(iii) តាមអត្រាការប្រាក់ (ក្នុង ១ ឆ្នាំ)៖**

| | ២០២០ | ២០១៩ |
|---|---|---|
| គណនីសន្សំ | 0.00% - 0.៨0% | 0.00% - 0.៨0% |
| គណនីចរន្ត | 0.00% - ២.00% | 0.00% - ២.00% |

## ៧. ប្រាក់តម្កល់តាមច្បាប់

យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១-១៣៦ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តម្រូវឲ្យរក្សាប្រាក់តម្កល់តាមច្បាប់ចំនួន ៥% នៃដើមទុនរបស់ខ្លួន ។ ប្រាក់តម្កល់នេះ គឺមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួនបានឡើយ ប៉ុន្តែក្រុមហ៊ុនអាចដកវិញបាន នៅពេលដែលក្រុមហ៊ុនសម្រេចចិត្តឈប់ធ្វើអាជីវកម្ម នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដោយស្ម័គ្រចិត្ត ។

ប្រាក់តម្កល់នេះទទួលបានអត្រាការប្រាក់ 0.0៦% (២០១៩: 0.៥0%) ក្នុងមួយឆ្នាំ ។





## ៨. ឥណទានផ្តល់ដល់អតិថិជន - សុទ្ធ

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| ឥណទាន បុគ្គល | ៥៦,៥១៥,៩៦៣ | ៥៦,២៧៥,៨០៧ | ២២៨,៦០៧,០៧០ | ២២៩,៣២៣,៩១៤ |
| ឥណទាន បុគ្គលិក | ៣២៦,១៨៦ | ២៦៥,៤២៤ | ១,៣១៩,៤២២ | ១,០៨១,៦០៣ |
| | ៥៦៨៤២,១៤៩ | ៥៦,៥៤១,២៣១ | ២២៩,៩២៦,៤៩២ | ២៣០,៤០៥,៥១៧ |
| កម្រៃជើងសារមិនទាន់ចាត់ជាចំណូល | (៧៣២,៩៧៨) | (៧៨៧,៣៤៤) | (២,៩៦៤,៨៩៦) | (៣,២០៨,៤២៧) |
| ការប្រាក់បង្គរត្រូវទទួល | ៦២៧,០៣៦ | ៦២២,៦៥០ | ២,៥៣៦,៣៦១ | ២,៥៣៧,២៩៩ |
| ការកត់ត្រាបង្គរឡើងវិញនៃតម្លៃការប្រាក់ | (៩៥,៣១១) | (៨២,៨០៥) | (៣៨៥,៥៣៣) | (៣៣៧,៤៣១) |
| ឥណទានផ្តល់ដល់អតិថិជន- ដុល | ៥៦,៦៤០,៨៩៦ | ៥៦,២៩៣,៧៣២ | ២២៩,១១២,៤២៤ | ២២៩,៣៩៦,៩៥៨ |
| ដក: សំវិធានធនឱនភាពតម្លៃ | (៦២៤,៧៦៦) | (៥១៤,៧០៩) | (២,៥២៧,១៧៨) | (២,០៩៧,៤៣៩) |
| ឥណទានអតិថិជន-សុទ្ធ | ៥៦,០១៦,១៣០ | ៥៥,៧៧៩,០២៣ | ២២៦,៥៨៥,២៤៦ | ២២៧,២៩៩,៥១៩ |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| **សំវិធានធនខាតបង់ជាក្រុម** | | | | |
| នាថ្ងៃទី ១ ខែ មករា | ៥១៤,៧០៩ | ៤៤៩,៥៤០ | ២,០៩៧,៤៣៩ | ១,៨០៦,២៥២ |
| សំវិធានធនក្នុងការិយបរិច្ឆេទ (កំណត់សម្គាល់ ២១) | ៧១៥,១៩៨ | ៤៤៣,៧៧៤ | ២,៩១៥,៨៦២ | ១,៧៩៨,១៧២ |
| សំវិធានធនលុបចោលក្នុងការិយបរិច្ឆេទ | (៦០៥,១៤១) | (៣៧៨,៦០៥) | (២,៤៦៧,១៦០) | (១,៥៣៤,១០៧) |
| លម្អៀងលើការប្តូររូបិយប័ណ្ណ | - | - | (១៨,៩៦៣) | ២៧,១២២ |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ៦២៤,៧៦៦ | ៥១៤,៧០៩ | ២,៥២៧,១៧៨ | ២,០៩៧,៤៣៩ |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ៨. ឥណទានផ្តល់ដល់អតិថិជន - សុទ្ធ

ឥណទានផ្តល់ដល់អតិថិជនត្រូវបានវិភាគដូចខាងក្រោម៖

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ពាន់រៀល (កំណត់សម្គាល់ ៥) |
| **(ក) តាមកាលកំណត់** | | | | |
| រយៈពេល ១ ខែ | ៨២,១០០ | ១២១,៣១២ | ៣៣២,០៩៥ | ៤៩៤,៣៤៦ |
| ២ ទៅ ៣ ខែ | ១២៨,៨៦៤ | ២១២,២២៥ | ៥២១,២៥៥ | ៨៦៤,៨១៧ |
| ៤ ទៅ ១២ ខែ | ២,៣៨៥,០៩៣ | ២,៥០៩,៥០២ | ៩,៦៤៧,៧០០ | ១០,២២៦,២២១ |
| លើស ១២ ខែ | ៥៤,០៤៤,៨៣៩ | ៥៣,៤៥០,៦៩៣ | ២១៨,៦១១,៣៧៤ | ២១៧,៨១១,៥៧៤ |
| | ៥៦,៦៤០,៨៩៦ | ៥៦,២៩៣,៧៣២ | ២២៩,១១២,៤២៤ | ២២៩,៣៩៦,៩៥៨ |
| **(ខ) តាមវិស័យសេដ្ឋកិច្ច** | | | | |
| វិស័យកសិកម្ម | ១៤,៥១៩,២៣៤ | ១២,៦៩៩,៣៧៦ | ៥៨,៧៣០,៣០២ | ៥១,៧៤៩,៩៥៧ |
| វិស័យជំនួញ និងពាណិជ្ជកម្ម | ១០,០៤៥,៧៧១ | ៩,០៧១,៤៧៦ | ៤០,៦៣៥,១៤៤ | ៣៦,៩៦៦,២៦៥ |
| វិស័យសេវាកម្ម | ២,៣០៤,៦៣២ | ២,៣៩១,៤២១ | ៩,៣២២,២៣៦ | ៩,៧៤៥,០៤១ |
| វិស័យដឹកជញ្ជូន | ១,៦៩០,២៧៧ | ១,៨១៨,០៥០ | ៦,៨៣៧,១៧០ | ៧,៤០៨,៥៥៤ |
| វិស័យសំណង់ | ២,០១២,០៦៣ | ២,១៤៣,៤៩៦ | ៨,១៣៨,៧៩៥ | ៨,៧៣៤,៧៤៦ |
| វិស័យគ្រួសារ | ២៥,៦១៥,០៤៣ | ២៨,០១៩,០១៩ | ១០៣,៦១២,៨៤៩ | ១១៤.១៧៧,៥០២ |
| វិស័យផ្សេងទៀត | ៤៥៣,៨៧៦ | ១៥០,៨៩៤ | ១,៨៣៥,៩២៨ | ៦១៤,៨៩៣ |
| | ៥៦,៦៤០,៨៩៦ | ៥៦,២៩៣,៧៣២ | ២២៩,១១២,៤២៤ | ២២៩,៣៩៦,៩៥៨ |
| **(គ) តាមទំនាក់ទំនង** | | | | |
| អតិថិជនខាងក្រៅ | ៥៦,៣០៧,៨១៨ | ៥៦,០២៨,៣០៨ | ២២៧,៧៦៥,១២៤ | ២២៨,៣១៥,៣៥៥ |
| ឥណទានបុគ្គលិក | ៣៣៣,០៧៨ | ២៦៥,៤២៤ | ១,៣៤៧,៣០០ | ១,០៨១,៦០៣ |
| | ៥៦,៦៤០,៨៩៦ | ៥៦,២៩៣,៧៣២ | ២២៩,១១២,៤២៤ | ២២៩,៣៩៦,៩៥៨ |



# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ៨. ឥណទានផ្តល់ដល់អតិថិជន - សុទ្ធ

ឥណទានផ្តល់ដល់អតិថិជនត្រូវបានវិភាគដូចខាងក្រោម៖

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ពាន់រៀល (កំណត់សម្គាល់ ៥) |

| (ឃ) តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ) | ២០២០ | ២០១៩ |
|---|---|---|
| អតិថិជនខាងក្រៅ | ១២.០០% - ១៨.០០% | ១៣.២០% - ១៨.០០% |
| ឥណទានបុគ្គលិក | ១០.០០% | ១០.០០% |

### ៩. ទ្រព្យសកម្មផ្សេងៗ

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ពាន់រៀល (កំណត់សម្គាល់ ៥) |
| ចំណាយបង់មុន | ៣៦៨,៤៨៨ | ៣៦៨,០៧១ | ១,៤៩០,៥៣៤ | ១,៤៩៩,៨៩០ |
| ផ្សេងៗ | ៤២,៦៨២ | ១៤,៧១១ | ១៧២,៦៤៩ | ៥៩,៩៤៧ |
| | ៤១១,១៧០ | ៣៨២,៧៨២ | ១,៦៦៣,១៨៣ | ១,៥៥៩,៨៣៧ |



# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ១០. ទ្រព្យ និងបរិក្ខារ

| ២០២០ | ការកែលម្អការិយាល័យជួល ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | បរិក្ខារការិយាល័យ ដុល្លារអាមេរិក | កុំព្យូទ័រ ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និងបរិក្ខារបំពាក់ ដុល្លារអាមេរិក | ទ្រព្យ កំពុងបង្កើត ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល (កំណត់សម្គាល់៥) |
|---|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២០ | ៦៧,៦៤៧ | ២០១,៣២១ | ៨៩,៧៩៦ | ៧៦១,៩៤៦ | ៧៦,៣១០ | - | ១,១៩៧,០២០ | ៤,,៨៧៧,៨៤៧ |
| ការទិញបន្ថែម | ៩,៧២៤ | ៦១,២១៧ | ៥,១៨០ | ២៤០,៥៦៣ | - | ៨១,៣៧៨ | ៣៩៨,០៦២ | ១,៦២២,៨៩៩ |
| ការលុបចោល | - | - | - | (៣,៧៦០) | - | - | (៣,៧៦០) | (១៥,៣៣០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | (៤៨,៥២៨) |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | ៧៧,៣៧១ | ២៦២,៥៣៨ | ៩៤,៩៧៦ | ៩៩៨,៧៤៩ | ៧៦,៣១០ | - | ១,៥៩១,៣២២ | ៦,៤៣៦,៨៩៨ |
| **ដកៈ រំលស់បង្គរ** | | | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២០ | ២០,៩៦៣ | ១៩៣,២៦៥ | ៦១,១៣៨ | ៣០០,២២៨ | ៦២,៣២០ | - | ៥៩៧,៩១៤ | ២,៤៣៦,៥០០ |
| រំលស់ក្នុងការិយបរិច្ឆេទ | ១៩,០៣៧ | ៣០,៤៤៥ | ១៤,០១៥ | ១៤៩,៣៨១ | ៩,០៩៤ | - | ២២១,៩៧២ | ៩០៤,៩៤០ |
| ការលុបចោល | - | - | - | (៣,៧៦០) | - | - | (៣,៧៦០) | (១៥,៣៣០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | (២៤,៩២០) |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | ៤ ០,០០០ | ១៨៣,៧១០ | ៧៥,១៥៣ | ៤៤៥,៨៤៩ | ៧១,៤១៤ | - | ៨១៦,១២៦ | ៣,៣០១,២៣០ |
| **តម្លៃយោង** | | | | | | | | |
| **នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០** | **៣៧,៣៧១** | **៧៨,៨២៨** | **១៩,៨២៣** | **៥៥២,៩០០** | **៤,៨៩៦** | **៨១.៣៧៨** | **៧៧៥,១៩៦** | **៣,១៣៥,៦៦៨** |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ១០. ទ្រព្យ និងបរិក្ខារ

| ២០១៩ | ការកែលម្អការិយាល័យជួល ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | បរិក្ខារការិយាល័យ ដុល្លារអាមេរិក | កុំព្យូទ័រ ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និងបរិក្ខារបំពាក់ ដុល្លារអាមេរិក | ទ្រព្យ កំពុងបង្កើត ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល (កំណត់សម្គាល់៥) |
|---|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩ | ៣១,៦៥១ | ១៦៥,៧៨៦ | ៨០,៤៦០ | ៣៨៣,៩០៩ | ៧២,៥៥១ | ១២,៧២៥ | ៧០៧,០៨២ | ២,៨៤១,០៥៥ |
| ការទិញបន្ថែម | ៣៥,៩៩៦ | ៣៥,៥៣៥ | ១៣,៥៣៦ | ៤០៧,៣៣៧ | ៥,០៧៤ | - | ៤៩៧,៤៧៨ | ២,០១៥,៧៨១ |
| ការផ្ទេរ | - | - | - | ១២,៧២៥ | - | (១២,៧២៥) | - | - |
| ការលុបចោល | - | - | (៤,២០០) | (២,០២៥) | (១,៣១៥) | - | (៧,៥៤០) | (៣០,៥៥២) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | | ៥១,៥៧៣ |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ | ៦៧,៦៤៧ | ២០១,៣២១ | ៨៩,៧៩៦ | ៧៦១,៩៤៦ | ៧៦,៣១០ | - | ១,១៩៧,០២០ | ៤,៨៧៧,៨៤៧ |
| **ដកៈ រំលស់បង្គរ** | | | | | | | | |
| នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩ | ៨,៣៣២ | ១២៨,០៨០ | ៤៩,៥៣៣ | ២៤០,១២៤ | ៥១,៤៧៥ | - | ៤៧៧,៥៤៤ | ១,៩១៨,៧៧១ |
| រំលស់សម្រាប់ការិយបរិច្ឆេទ | ១២,៦៣១ | ២៥,១៨៥ | ១៥,៨០៥ | ៦២,១២៩ | ១២,១៦០ | - | ១២៧,៩១០ | ៥១៨,២៩១ |
| ការលុបចោល | - | - | (៤,២០០) | (២,០២៥) | (១,៣១៥) | - | (៧,៥៤០) | (៣០,៥៥២) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | ២៩,៩៩០ |
| នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ | ២០,៩៦៣ | ១៩៣,២៦៥ | ៦១,១៣៨ | ៣០០,២២៨ | ៦២,៣២០ | - | ៥៩៧,៩១៤ | ២,៤៣៦,៥០០ |
| **នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩** | **៤៦,៦៨៤** | **៤៨,០៥៦** | **២៨,៦៥៨** | **៤៦១,៧១៨** | **១៣,៩៩០** | **-** | **៥៩៩,១០៦** | **២,៤៤១,៣៤៧** |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ១១.ទ្រព្យសកម្មអរូបី

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី ១ ខែ មករា | ៣៨៤,០៧៦ | ៣៤៥,៥៧៦ | ១,៥៦៥,១១០ | ១,៣៨៨,៥២៤ |
| ការទិញបន្ថែម | - | ៣៨,៥០០ | - | ១៥៦,០០២ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | ២០,៥៨៤ |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ៣៨៤,០៧៦ | ៣៨៤,០៧៦ | ១,៥៦៥,១១០ | ១,៥៦៥,១១០ |
| **ដកៈ រំលស់បង្គរ** | | | | |
| នាថ្ងៃទី ១ ខែ មករា | ២៧៨,៥៣១ | ២០៣,៣២២ | ១,១៣៥,០១៤ | ៨១៦,៩៤៨ |
| រំលស់ សម្រាប់ការិយបរិច្ឆេទ | ៥៣,៤៥៨ | ៧៥,២០៩ | ២១៧,៩៤៨ | ៣០៤,៧៤៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | ១,៤៥៦ | ១៣,៣១៩ |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ៣៣១,៩៨៩ | ២៧៨,៥៣១ | ១,៣៥៤,៤១៨ | ១,១៣៥,០១៤ |
| **តម្លៃយោង** | | | | |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ៥២,០៨៧ | ១០៥,៥៤៥ | ២១០,៦៩២ | ៤៣០,០៩៦ |

### ១២.ប្រាក់កម្ចី

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| សម្ពន្ធ័ញាតិ (កំណត់សម្គាល់ ២៤ខ) | ៣១,៨៦៣,៧២១ | ៣៣,៧៧៤,៥៤១ | ១២៨,៨៨៨,៧៥១ | ១៣៧,៦៣១,២៥៤ |
| មិនមែនសម្ពន្ធ័ញាតិ | ១២,៣១៤,៨៩៥ | ១០,៨០៥,២១៤ | ៤៩,៨១៣,៧៥១ | ៤៤,០៣១,២៤៨ |
| | ៤៤,១៧៨,៦១៦ | ៤៤,៥៧៩,៧៥៥ | ១៧៨,៧០២,៥០២ | ១៨១,៦៦២,៥០២ |
| ការប្រាក់បង្គរត្រូវទូទាត់ | ២៤២,៨៨១ | ២១០,១៣៤ | ៩៨២,៤៥៣ | ៨៥៦,២៩៦ |
| | ៤៤,៤២១,៤៩៧ | ៤៤,៧៨៩,៨៨៩ | ១៧៩,៦៨៤,៩៥៥ | ១៨២,៥១៨,៧៩៨ |



# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ១២.ប្រាក់កម្ចី (ត)

ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងប្រាក់កម្ចីជាមួយអ្នកផ្តល់កម្ចីផ្សេងៗគ្នាដោយមិនមានការធានា ។ ការសងប្រាក់ដើមនិងប្រាក់ការត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានរៀងៗខ្លួនប្រចាំឆមាស ឬ ប្រចាំត្រីមាសតាមកាលវិភាគទូទាត់នៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចី ។

កម្ចីត្រូវបានវិភាគដូចខាងក្រោមៈ

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| **(ក) តាមកាលកំណត់** | | | | |
| ១ ទៅ ៣ ខែ | ៣,០០០,០០០ | - | ១២,១៣៥,០០០ | - |
| ៣ទៅ ១២ ខែ | ៧,៤៥៨,២៨២ | ២២,៨៦៦,៥៦៥ | ៣០,១៦៨,៧៥១ | ៩៣,១៨១,២៥២ |
| ១ ទៅ ៥ ឆ្នាំ | ២៩,៧៣១,៤៥៩ | ១៧,៧៣១,៥៩៥ | ១២០,២៦៣,៧៥២ | ៧២,២៥៦,២៥០ |
| លើសពី ៥ ឆ្នាំ | ៣,៩៨៨,៨៧៥ | ៣,៩៨១,៥៩៥ | ១៦,១៣៤,៩៩៩ | ១៦,២២៥,០០០ |
| | ៤៤,១៧៨.៦១៦ | ៤៤,៥៧៩,៧៥៥ | ១៧៨,៧០២,៥០២ | ១៨១,៦៦២,៥០២ |
| **(ខ) តាមប្រភេទ** | | | | |
| បំណុលជាន់ខ្ពស់ | ៤០,១៨៩,៧៤១ | ៤០,៥៩៨,១៥៩ | ១៦២,៥៦៧,៥០២ | ១៦៥,៤៣៧,៤៩៨ |
| អនុបំណុល | ៣,៩៨៨,៨៧៥ | ៣,៩៨១,៥៩៦ | ១៦,១៣៥,០០០ | ១៦,២២៥,០០៤ |
| | ៤៤,១៧៨,៦១៦ | ៤៤,៥៧៩,៧៥៥ | ១៧៨,៧០២,៥០២ | ១៨១,៦៦២,៥០២ |
| **(គ) តាមរូបិយប័ណ្ណ** | | | | |
| ដុល្លារអាមេរិក | ២៤.៥០០,០០០ | ២៧,៥០០,០០០ | ៩៩,១០២,៥០០ | ១១២,០៦២,៥០០ |
| ប្រាក់រៀល | ១៩,៦៧៨,៦១៦ | ១៧,០៧៩,៧៥៥ | ៧៩,៦០០,០០២ | ៦៩,៦០០,០០២ |
| | ៤៤,១៧៨,៦១៦ | ៤៤,៥៧៩,៧៥៥ | ១៧៨,៧០២,៥០២ | ១៨១,៦៦២,៥០២ |

| **(ឃ) តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)** | ២០២០ | ២០១៩ |
|---|---|---|
| | ៧.០០% - ៨.៨២% | ៧.០០% - ៨.៨២% |
| | ៨.០០% - ៨.៥០% | ៨.០០% - ៨.៥០% |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ១៣.បំណុលផ្សេងៗ

| | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០១៩<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) |
|---|---|---|---|---|
| គណនីត្រូវទូទាត់ | ១០,៨១៣ | ៤០,១៧៦ | ៤៣,៧៣៩ | ១៦៣,៧១៧ |
| ចំណាយបង្គរ | ៣៦៣,៤៦៣ | ៤៤៥,៧៩១ | ១,៤៧០,២០៨ | ១,៨១៦,៥៩៨ |
| ពន្ធផ្សេងៗត្រូវទូទាត់ | ១៥,១៧៣ | ១៨,៣២៥ | ៦១,៣៧៤ | ៧៤,៦៧៤ |
| បំណុលផ្សេងៗ | ៤២២,៨១៥ | ១៨៧,៩២៣ | ១,៧១០,២៨៧ | ៧៦៥,៧៨៣ |
| | ៨១២,២៦៤ | ៦៩២,២១៥ | ៣,២៨៥,៦០៨ | ២,៨២០,៧៧២ |

### ១៤.សំវិធានធនលើអត្ថប្រយោជន៍និយោជិត

| | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០១៩<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) |
|---|---|---|---|---|
| សំណងអតីតភាពការងារ | ៤៣,១៧០ | ៥៣,៥២៤ | ១៧៤,៦២៣ | ២១៨,១១០ |

សំវិធានធនលើអត្ថប្រយោជន៍និយោជិតសំដៅទៅលើ សំវិធានធនលើការទូទាត់សំណងអតីតភាពការងារដែលតម្រូវតាមប្រកាសលេខ ៤៤៣ ចេញដោយក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈនាថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៨ និងសេចក្តីណែនាំលេខ០៤២/១៩ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៩។

ប្រកាសនេះតម្រូវឲ្យនិយោជកទាំងអស់ទូទាត់ប្រាក់សំណងអតីតភាពការងារដល់និយោជិតរបស់ខ្លួន ដូចខាងក្រោម៖

- ប្រាក់អតីតភាពការងារថ្មីក្នុងឆ្នាំ៖ ចាប់តាំងពីឆ្នាំ ២០១៩ ត្រូវបានកំណត់យកចំនួនស្មើនឹង ១៥ ថ្ងៃ នៃប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ក្នុងមួយឆ្នាំ ។
- ប្រាក់រំលឹកអតីតភាពការងារ៖ ត្រូវបានកំណត់យកចំនួនស្មើនឹង 6 ថ្ងៃ នៃប្រាក់បៀវត្សរ៍សុទ្ធក្នុងមួយឆ្នាំដែលនឹងត្រូវទូទាត់ចាប់ពីឆ្នាំ ២០២១ តទៅ ។ សំវិធានធនលើប្រាក់អតីតភាពការងារ ត្រូវបានគណនាមិនឲ្យលើសពីចំនួន អតិបរមាស្មើនឹង 6 ខែ នៃប្រាក់បៀវត្សរ៍សុទ្ធរបស់និយោជិត ដែលមានអតីតភាពការងារមុនឆ្នាំ ២០១៩ (អាស្រ័យតាមរយៈពេលបម្រើការងាររបស់និយោជិត) ។

នៅថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០២០ ក្រសួងការងារបានចេញប្រកាសលេខ 018/20 សម្រាប់ការពន្យាពេលនៃការទូទាត់ប្រាក់អតីតភាពការងារសម្រាប់រយៈពេលមុនឆ្នាំ 2019 និងការពន្យារការទូទាត់អតីតភាពការងារ នៅឆ្នាំ 2020។ ក្រោមវិធានថ្មីនេះទាំងការទូទាត់ប្រាក់សំណងអតីតភាពអតីតភាព សម្រាប់រយៈពេល មុនឆ្នាំ ២០១៩និងការទូទាត់ប្រាក់អតីតភាពការងារ សម្រាប់ឆ្នាំ ២០២០ ត្រូវបានពន្យារពេលរហូតដល់ឆ្នាំ ២០២២ ។ ក្រុមហ៊ុនបានជ្រើសរើសអនុវត្តតាមបទប្បញ្ញត្តិហើយជាលទ្ធផលការទូទាត់ទាំងនេះនឹងត្រូវធ្វើឡើងនៅឆ្នាំ ២០២២ ។



# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ១៤.សំវិធានធនលើអត្ថប្រយោជន៍និយោជិត (ត)

ការទូទាត់នឹងត្រូវបានធ្វើឡើងពីរដងក្នុងមួយឆ្នាំ គឺនៅក្នុងខែ មិថុនា និងខែ ធ្នូ ជារៀងរាល់ឆ្នាំ ។ និយោជិតពុំមានសិទ្ធិទទួលបានសំណងរំលឹកអតីតភាពការងារនៅសល់ដែលមិនទាន់បានទូទាត់នោះទេ ប្រសិនបើគាត់លាលែងពីការងារ ។

បម្រែបម្រួលនៃសំវិធានធនលើអត្ថប្រយោជន៍របស់និយោជិតមានដូចខាងក្រោម:

| | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០១៩<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) |
|---|---|---|---|---|
| នាថ្ងៃទី 1 ខែ មករា | ៥៣,៥២៤ | ១៦៦,៧២៩ | ២១៨,១១០ | ៦៦៩,៩១៧ |
| ការបន្ថែមក្នុងការិយបរិច្ឆេទ | ១៣៣,០៩៩ | ២២,០៧៩ | ៥៤២,៦៤៥ | ៨៩,៤៦៤ |
| ប្រាក់បង់នៅក្នុងការិយបរិច្ឆេទ | (១៤៣,៤៥៣) | (១៣៥,២៨៤) | (៥៨៤,៨៥៨) | (៥៤៨,១៧១) |
| លម្អៀងលើការប្តូរូបិយប័ណ្ណ | - | - | (១,២៧៤) | ៦,៩០០ |
| នាថ្ងៃទី 31 ធ្នូ | ៤៣,១៧០ | ៥៣,៥២៤ | ១៧៤,៦២៣ | ២១៨,១១០ |

### ១៥.ពន្ធលើប្រាក់ចំណេញ

#### ក. ពន្ធពន្យារ- សុទ្ធ

| | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) | ២០១៩<br>ពាន់រៀល<br>(កំណត់សម្គាល់ ៥) |
|---|---|---|---|---|
| ពន្ធពន្យារលើទ្រព្យសកម្ម | ២៥២,២៨៤ | ៤៤១,៧៧៩ | ១,០២០,៤៨៩ | ១,៨០០,២៤៩ |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

## ១៥.ពន្ធលើប្រាក់ចំណេញ (ត)

### ក. ពន្ធពន្យារ- សុទ្ធ(ត)

ពន្ធពន្យារលើទ្រព្យសកម្មត្រូវបានបង្ហាញដូចខាងក្រោម៖

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| ទ្រព្យ និង បរិក្ខា | (៣៣,១៩២) | (១៨,៦៩៩) | (១៣៤,២៦២) | (៧៦,១៩៨) |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | ៤៩,៥៣១ | ៦៩,៣៤១ | ២០០,៣៥៣ | ២៨២,៥៦៥ |
| សំវិធានធនលើឱនភាពតម្លៃ | ៨៨,០៣៥ | ១០២,៩៤២ | ៣៥៦,១០២ | ៤១៩,៤៨៩ |
| ចំណូលពីកម្រៃជើងសារមិនទាន់ទទួលស្គាល់ | ១៤៦,៥៩៦ | ១៥៧,៤៦៩ | ៥៩២,៩៨១ | ៦៤១,៦៨៦ |
| ខាតឬចំណេញពីការប្តូររូបិយប័ណ្ណ | | | | |
| មិនទាន់កើតឡើង | ១,៣១៤ | ៩,០៤៨ | ៥,៣១៥ | ៣៦,៨៦៩ |
| ផ្សេងៗ | - | ១២១,៦៧៨ | - | ៤៩៥,៨៣៨ |
| | ២៥២,២៨៤ | ៤៤១,៧៧៩ | ១,០២០,៤៨៩ | ១,៨០០,២៤៩ |

បម្រែបម្រួលនៃពន្ធពន្យារជាទ្រព្យសកម្មមានដូចខាងក្រោម៖

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| នាថ្ងៃទី ១ មករា | ៤៤១,៧៧៩ | ៣៥៥,៦៥៦ | ១,៨០០,២៤៩ | ១,៤២៩,០២៦ |
| ទទួលស្គាល់ក្នុងរបាយការណ៍ លទ្ធផល | (១៨៩,៤៩៥) | ៨៦,១២៣ | (៧៧២,៥៧១) | ៣៤៨,៩៧០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | (៧,១៨៩) | ២២,២៥៣ |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ២៥២,២៨៤ | ៤៤១,៧៧៩ | ១,០២០,៤៨៩ | ១,៨០០,២៤៩ |




# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

## ១៥.ពន្ធលើប្រាក់ចំណេញ (ត)


### ខ. បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| នាថ្ងៃទី ១ មករា | ៧១៦,៨៧៥ | ៥៥៩,៣៤៨ | ២,៩២១,២៦៦ | ២,២៤៧,៤២៩ |
| ទទួលស្គាល់ក្នុងរបាយការណ៍ | | | | |
| លទ្ធផល | ៦៣៨,៨៩០ | ៨៣៥,៦៣៧ | ២,៦០៤,៧៥៥ | ៣,៣៨៦,០០១ |
| ពន្ធលើប្រាក់ចំណេញបានបង់ | (៨៤៦,៤៣៨) | (៦៨៤,៩៨៧) | (៣,៤៥០,៩២៨) | (២,៧៧៥,៥៦៧) |
| ផ្សេងៗ | ៥,៨៣៦ | ៦,៨៧៧ | ២៣,៧៩៣ | ២៧,៨៦៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | (១៥,០៥២) | ៣៥,៥៣៧ |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ៥១៥,១៦៣ | ៧១៦,៨៧៥ | ២,០៨៣,៨៣៤ | ២,៩២១,២៦៦ |

អនុលោមទៅតាមច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ ចំណេញ ដោយគណនាតាមអត្រា ២០% នៃប្រាក់ចំណេញជាប់ពន្ធ ឬក៏បង់ពន្ធអប្បបរមា ដោយគណនាតាមអត្រា ១% នៃប្រាក់ចំណូលសរុប ដោយកំណត់យកចំនួនត្រូវបង់ណាដែលធំជាង ។

### គ. ចំណាយពន្ធលើប្រាក់ចំណេញ

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| ពន្ធលើប្រាក់ចំណេញក្នុងការិយបរិច្ឆេទ | ៦៣៨,៨៩០ | ៨៣៥,៦៣៧ | ២,៦០៤,៧៥៥ | ៣,៣៨៦,០០១ |
| ពន្ធពន្យារ | ១៨៩,៤៩៥ | (៨៦,១២៣) | ៧៧២,៥៧១ | (៣៤៨,៩៧០) |
| ចំណាយពន្ធលើប្រាក់ចំណូល | ៨២៨,៣៨៥ | ៧៤៩,៥១៤ | ៣,៣៧៧,៣២៦ | ៣,០៣៧,០៣១ |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ១៥.ពន្ធលើប្រាក់ចំណេញ ( ត )

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញដែលត្រូវបានគណនាតាមអត្រាពន្ធផ្លូវការ 20% ចំពោះចំណាយពន្ធលើប្រាក់ចំណេញដូចបានបង្ហាញនៅក្នុងប្រាក់ចំណេញ ឬខាត ដូចខាងក្រោម:

| | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) | ២០១៩<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ៣,២៧៧,២៥៦ | ៣,៧១០,១៦២ | ១៣,៣៦១,៣៧២ | ១៥,០៣៣,៥៧៧ |
| ពន្ធគណនាតាមអត្រាពន្ធ20%លើ | ៦៥៥,៤៥១ | ៧៤២,០៣២ | ២,៦៧២,២៧៤ | ៣,០០៦,៧១៤ |
| ប្រាក់ចំណេញ | ១៣,៨៩៥ | ៧,៤៨២ | ៥៦,៦៥០ | ៣០,៣១៧ |
| ចំណាយមិនអាចកាត់កងបាន | ១៥៩,០៣៩ | - | ៦៤៨,៤០២ | - |
| ពន្ធពន្យារជាទ្រព្យសកម្មមិនបានទទួលស្គាល់ពីការិយបរិច្ឆេទមុន | ៨២៨,៣៨៥ | ៧៤៩,៥១៤ | ៣,៣៧៧,៣២៦ | ៣,០៣៧,០៣១ |
| ចំណាយពន្ធលើប្រាក់ចំណូល | | | | |

### ១៦.ដើមទុន

| | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) | ២០១៩<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) |
|---|---|---|---|---|
| បានចុះបញ្ជី បោះផ្សាយ និងបានបង់គ្រប់ចំនួននៃភាគហ៊ុន ១ ដុល្លារអាមេរិកក្នុងមួយហ៊ុន | ៨,០០០,០០០ | ៨,០០០,០០០ | ៣២,២៩៦,០០០ | ៣២,២៩៦,០០០ |

ភាគទុនិករបស់ក្រុមហ៊ុន និងចំណែកភាគហ៊ុនរបស់ភាគទុនិកមានដូចខាងក្រោម៖

| | ២០២០ | | | ២០១៩ | | |
|---|---|---|---|---|---|---|
| | % ម្ចាស់ក្រុមហ៊ុន | ចំនួនភាគហ៊ុន | ចំនួនទឹកប្រាក់ ដុល្លារអាមេរិក | % ម្ចាស់ក្រុមហ៊ុន | ចំនួនភាគហ៊ុន | ចំនួនទឹកប្រាក់ ដុល្លារអាមេរិក |
| ធនាគារ ប្រៃសណីយ៍ កម្ពុជា ក.អ | ១០០% | ៨,០០០,០០០ | ៨,០០០,០០០ | ១០០% | ៨,០០០,០០០ | ៨,០០០,០០០ |
| សមមូល ពាន់រៀល (កំណត់សម្គាល់ ៥) | | | ៣២,២៩៦,០០០ | | | ៣២,២៩៦,០០០ |



# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ១៧.ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិតំណាងឲ្យភាពខុសគ្នានៃសំវិធានធនរវាង ឱនភាពនៃតម្លៃលើឥណទានស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធនតូច និងមធ្យម និងសំវិធានធនតាមបទប្បញ្ញត្តិដោយអនុលោមតាមធនាគារជាតិនៃកម្ពុជា ។ នាថ្ងៃទី ៣១ ខែធ្នូឆ្នាំ ២០២០ ក្រុមហ៊ុនមានឱនភាពនៃតម្លៃស្របតាម ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យមច្រើនជាងការផ្តល់ជូនស្របតាមធនាគារជាតិនៃកម្ពុជា ។

### ១៨.ចំណូលពីការប្រាក់

| | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) | ២០១៩<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) |
|---|---|---|---|---|
| ឥណទានផ្តល់ដល់អតិថិជន | ១២,៨១៤,៧០៤ | ១២,១៧៨,២៥៣ | ៥២,២៤៥,៥៤៨ | ៤៩,៣៤៦,២៨១ |
| ប្រាក់បញ្ញើនៅធនាគារនានា | ៤៩,២៥៥ | ១២,៨១៩ | ២០០,៨១៣ | ៥១,៩៤៣ |
| | ១២,៨៦៣,៩៥៩ | ១២,១៩១,០៧២ | ៥២,៤៤៦,៣៦១ | ៤៩,៣៩៨,២២៤ |

### ១៩.ចំណាយលើការប្រាក់

| | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) | ២០១៩<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) |
|---|---|---|---|---|
| ប្រាក់កម្ចី | ៣,៧៣៥,០២២ | ៣,១២៥,៩១៥ | ១៥,២២៧,៦៨៥ | ១២,៦៦៦,២០៨ |

### ២០.ចំណូលពីប្រតិបត្តិការផ្សេងៗ

| | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) | ២០១៩<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) |
|---|---|---|---|---|
| ពិន័យលើឥណទាន | ៣២២,៥៤០ | ៣៤៣,៣៥៧ | ១,៣១៤,៩៩៦ | ១,៣៩១,២៨៣ |
| ចំណូលផ្សេងៗ | ១២៥,១១៩ | ៣១,៦៣២ | ៥១០,១១០ | ១២៨,១៧២ |
| | ៤៤៧,៦៥៩ | ៣៧៤,៩៨៩ | ១,៨២៥,១០៦ | ១,៥១៩,៤៥៥ |

### ២១.ការខាតបង់លើឱនភាពនៃតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ-សុទ្ធ

| | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) | ២០១៩<br>ពាន់រៀល<br>( កំណត់សម្គាល់ ៥ ) |
|---|---|---|---|---|
| សំវិធានធនសម្រាប់ការិយបរិច្ឆេទ(កំណត់សម្គាល់ ៨) | ៧១៥,១៩៨ | ៤៤៣,៧៧៤ | ២,៩១៥,៨៦២ | ១,៧៩៨,១៧២ |
| ការទទួលបានមកវិញពីឥណទានដែលបានលុបចោលកាលពីការិយបរិច្ឆេទមុន | (៩៨,០៩៩) | (៧៦,២៧០) | (៣៩៩,៩៤៩) | (៣០៩,០៤៦) |
| | ៦១៧,០៩៩ | ៣៦៧,៥០៤ | ២,៥១៥,៩១៣ | ១,៤៨៩,១២៦ |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ២២.ចំណាយលើបុគ្គលិក

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ពាន់រៀល (កំណត់សម្គាល់ ៥) |
| ប្រាក់បៀវត្សរ៍ | ២,៩៥៣,៥៤៣ | ២,៩៣៩,៨១១ | ១២,០៤១,៥៩៥ | ១១,៩១២,១១៤ |
| ចំណាយប្រាក់បំណាច់អតីតភាពការងារ | ១៣៣,០៩៩ | ២២,០៧៩ | ៥៤២,៦៤៥ | ៨៩,៤៦៤ |
| ការបណ្តុះបណ្តាលបុគ្គលិក | ២០,៧៨៩ | ៥៥,៦១៣ | ៨៤,៧៥៧ | ២២៥,៣៤៤ |
| ផ្សេងៗ | ១៤៧,៤៧៣ | ១១៣,៦៩៤ | ៦០១,២៤៧ | ៤៦០,៦៨៨ |
| | ៣,២៥៤,៩០៤ | ៣,១៣១,១៩៧ | ១៣,២៧០,២៤៤ | ១២,៦៨៧,៦១០ |

### ២៣.ចំណាយផ្សេងៗ

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ពាន់រៀល (កំណត់សម្គាល់ ៥) |
| ចំណាយលើការជួល | ៧៦០,២៤២ | ៦៥១,៤០៦ | ៣,០៩៩,៥០៧ | ២,៦៣៩,៤៩៧ |
| រំលស់ | ២៧៥,៤៣០ | ២០៣,១១៩ | ១,១២២,៩២៨ | ៨២៣,០៣៨ |
| ចំណាយជួសជុល និងថែទាំ | ១៨៥,៦៦៥ | ១៦១,៧២៩ | ៧៥៦,៩៥៦ | ៦៥៥,៣២៦ |
| ប្រេងឥន្ធនៈ | ១៥៥,២៦៦ | ១៨២,៤៤៥ | ៦៣៣,០១៩ | ៧៣៩,២៦៧ |
| ចំណាយសេវាធនាគារ | ១២៦,៦០២ | ១០១,៤៩៦ | ៥១៦,១៥៦ | ៤១១,២៦២ |
| ចំណាយសេវាទូរគមនាគមន៍ | ១០៥,០៤២ | ៩១,៧៩១ | ៤២៨,២៥៦ | ៣៧១,៩៣៧ |
| ចំណាយទឹក ភ្លើង | ៩០,៤៩៧ | ៨៣,៨១៧ | ៣៦៨,៩៥៦ | ៣៣៩,៦២៦ |
| ចំណាយលើការដឹកជញ្ជូន | ៨៨,០៨៩ | ៨៥,៣០៦ | ៣៥៩,១៣៩ | ៣៤៥,៦៦០ |
| ចំណាយលើសម្ភារៈ និងបរិក្ខារការិយាល័យ | ៨៦,៨០៩ | ៩៦,២៣៧ | ៣៥៣,៩២០ | ៣៨៩,៩៥២ |
| សេវាកម្មវិជ្ជាជីវៈនិងអាជ្ញាប័ណ្ណ | ៦៧,០៤២ | ១១៧,៥៧៤ | ២៧៣,៣៣០ | ៤៧៦,៤១០ |
| ចំណាយលើពន្ធផ្សេងៗ | ៣២,៩៣៥ | ៧២,៥២៩ | ១៣៤,២៧៦ | ២៩៣,៨៨៨ |
| ចំណាយសន្និសីទ / សន្និបាត | ១៩,១២៥ | ១៦,៥៨៩ | ៧៧,៩៧៣ | ៦៧,២១៩ |
| ចំណាយការផ្សព្វផ្សាយ | ៧,៣៧៦ | ៨,២១៧ | ៣០,០៧២ | ៣៣,២៩៥ |
| ចំណាយលើការបោះពុម្ពនិងទម្រង់ | ៤,៣២៨ | ១១,៨១៥ | ១៧,៦៤៥ | ៤៧,៨៧៤ |
| ចំណាយផ្សេងៗ | ៤២២,៨៨៩ | ៣៤៧,២១៣ | ១,៧២៤,១២០ | ១,៤០៦,៩០៧ |
| | ២,៤២៧,៣៣៧ | ២,២៣១,២៨៣ | ៩,៨៩៦,២៥៣ | ៩,០៤១,១៥៨ |



# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

### ២៤.សម្ព័ន្ធញាតិ

#### ក. អត្តសញ្ញាណរបស់សម្ព័ន្ធញាតិ

ទំនាក់ទំនាក់របស់សម្ព័ន្ធញាតិជាមួយនិងក្រុមហ៊ុន មានដូចខាងក្រោម៖

| ទំនាក់ទំនង | សម្ព័ន្ធញាតិ |
|---|---|
| ក្រុមហ៊ុនបុត្រសម្ព័ន្ធ | យោងតាមកំណត់សម្គាល់ ១៦ |
| អ្នកគ្រប់គ្រងសំខាន់ៗ | រាល់អភិបាលនៃក្រុមហ៊ុន ដែលជាអ្នកធ្វើការសម្រេចចិត្តសំខាន់ៗ ដែលទាក់ទងទៅនឹងទិសដៅយុទ្ធសាស្ត្រ និងបុគ្គលិកគណៈគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុន (រួមបញ្ចូលទាំងសមាជិកគ្រួសារ) ។ |

#### ខ. សមតុល្យជាមួយសម្ព័ន្ធញាតិ

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ពាន់រៀល (កំណត់សម្គាល់ ៥) |
| កម្ចីពីភាគទុននិក | ៩៨៨,៨៧៥ | ៩៨១,៥៩៦ | ៣,៩៩៩,៩៩៩ | ៤,០០០,០០៣ |
| កម្ចីពីសម្ព័ន្ធញាតិ | ៣០,៨៧៤,៨៤៦ | ៣២,៧៩២,៩៤៥ | ១២៤,៨៨៨,៧៥២ | ១៣៣,៦៣១,២៥១ |
| | ៣១,៨៦៣,៧២១ | ៣៣,៧៧៤,៥៤១ | ១២៨,៨៨៨,៧៥១ | ១៣៧,៦៣១,២៥៤ |
| | ២,០៤៦,៦៣៣ | ៦៦៣,០៥៣ | ៨,២៧៨,៦៣០ | ២.៧០១,៩៤២ |

#### គ. ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) | ពាន់រៀល (កំណត់សម្គាល់ ៥) |
| អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី | ៣១៨,៣១៥ | ២៧៤,៥៨២ | ១,២៩៧,៧៧០ | ១,១១៨,៩២១ |
| ចំណាយរបស់ក្រុមប្រឹក្សាភិបាល | ៦,០០០ | ៦,០៧០ | ២៤,៤៦២ | ២៤,៥៩៦ |
| ចំណាយការជួល | ២៦៩,១៧៣ | ១៩១,១១០ | ១,០៩៧,៤១៨ | ៧៧៨,៧៧៤ |
| ចំណាយលើការប្រាក់ពីកម្ចី | ២,៧៥៨,៧៧៩ | ២,២៩១,៤៥៧ | ១១,២៤៧,៥៤២ | ៩,៣៣៧,៦៨៩ |

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

## ២៥.កិច្ចសន្យា និងយថាភាព

### ក. កិច្ចសន្យាភតិសន្យាប្រតិបត្តិការ

ភតិសន្យាប្រតិបត្តិទាំងនេះ ភាគច្រើនពាក់ព័ន្ធទៅនឹងការជួលការិយាល័យដែលអាចជួលបន្តជាថ្មីទៀត បានអាស្រ័យលើកិច្ចព្រមព្រៀងរវាងក្រុមហ៊ុន និងម្ចាស់ទីតាំង ។ ក្រុមហ៊ុន គឺជាអ្នកជួល ហើយការចំណាយលើ ថ្លៃជួលអប្បបរមាសរុបនាពេលអនាគត ក្រោមកិច្ចសន្យាភតិសន្យាដែលមិនអាចលុបចោលបានមានដូចខាងក្រោម៖

| | ២០២០ | ២០១៩ | ២០២០ | ២០១៩ |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៥) | (កំណត់សម្គាល់ ៥) |
| តិចជាង ១ ឆ្នាំ | ៥៥៤,០០៥ | ៦១៤,២៨៥ | ២,២៥៧,៥៧០ | ២,៥០៣,២១៣ |
| ២ ទៅ ៥ ឆ្នាំ | ៦៩០,៤២៥ | ៩២២,៥៦៥ | ២,៨១៣,៤៨២ | ៣,៧៥៩,៤៥៤ |
| លើស ៥ ឆ្នាំ | ៥,៣៣៣ | - | ២១,៧៣២ | - |
| | ១,២៤៩,៧៦៣ | ១,៥៣៦,៨៥០ | ៥,០៩២,៧៨៤ | ៦,២៦២,៦៦៧ |

### ខ. យថាភាពលើពន្ធ

ពន្ធត្រូវបានស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានអង្កេតដោយក្រុមអាជ្ញាធរដែលផ្ដល់សិទ្ធិដោយច្បាប់ ក្នុងការដាក់ពិន័យ ដាក់ទណ្ឌកម្ម និងការគិតការប្រាក់ ។ ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពន្ធលើប្រតិបត្តិការ ច្រើនប្រភេទប្រឈមនឹងបំណកស្រាយផ្សេងៗ ។

បញ្ហាទាំងនេះ អាចបង្កើតឲ្យមានហានិភ័យពន្ធ នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈធំជាងនៅ ប្រទេសដទៃទៀត ។ អ្នកគ្រប់គ្រងជឿជាក់ថា ការធ្វើសំវិធានធនមានលក្ខណៈគ្រប់គ្រាន់ដោយផ្អែកទៅ លើការបកស្រាយនៃនីតិកម្មពន្ធ ។ ក៏ប៉ុន្តែអាជ្ញាធរជាប់ពាក់ព័ន្ធអាចនឹងមានបំណកស្រាយខុសគ្នា ហើយផលប៉ះពាល់អាចមានទំហំធំ ។

## ២៦.តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

តម្លៃសមស្រប សំដៅទៅលើតម្លៃដែលទ្រព្យសកម្មអាចត្រូវបានដោះដូរ ឬបំណុលអាចត្រូវបានទូទាត់តាម មូលដ្ឋានធម្មតា ។ ដោយសារតម្លៃសមស្របដែលអាចផ្ទៀងផ្ទាត់បាន មិនអាចរកបាន ដូច្នេះ តម្លៃសមស្រប សម្រាប់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុមួយភាគធំ មិនអាចរកបានទេ ។ ហេតុនេះ តម្លៃសមស្រប ផ្អែកលើការសន្មត របស់អ្នកគ្រប់គ្រងដោយយោងតាមប្រភេទនៃទ្រព្យសកម្ម និងបំណុលទាំងនោះ ។ តាមមតិយោបល់របស់អ្នកគ្រប់គ្រង តម្លៃយោងនៃទ្រព្យសកម្ម និងបំណុល ដែលបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ មានតម្លៃប្រហាក់ប្រហែល នឹងតម្លៃសមស្រប ។

## ២៧.គោលនយោបាយគណនេយ្យសំខាន់។

គោលនយោបាយគណនេយ្យសំខាន់ៗដែលបានបង្ហាញនៅខាងក្រោមនេះ ត្រូវបានអនុវត្តដោយសង្គតិភាព ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ លើកលែងតែការផ្លាស់ប្តូរនៅក្នុងកំណត់សម្គាល់ ២៧ឋ ។

### (ក) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានថ្លៃដើមដំបូង ។

### (ខ) ប្រតិបត្តិការជារូបិយប័ណ្ណបរទេស

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។





សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

២៧.គោលនយោបាយគណនេយ្យសំខាន់។

ទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ ដែលជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយ ប្រើអត្រានាកាលបរិច្ឆេទរាយការណ៍ ។ ភាពលម្អៀងពីការប្តូរ រូបិយប័ណ្ណបរទេសត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ។ ធាតុមិនមែនរូបិយវត្ថុ ត្រូវបានវាស់វែងផ្អែកលើមូលដ្ឋានថ្លៃដើមដំបូងដែលជារូបិយប័ណ្ណបរទេសផ្សេងទៀត ត្រូវបានប្តូរដោយប្រើអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃប្រតិបត្តិការដំបូង ។

### (គ) ការប្រាក់

ចំណូលការប្រាក់ និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ ចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹង ទូទាត់ ឬនឹងត្រូវទទួល តាមរយៈអាយុកាលរំពឹងទុករបស់ទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុ (ឬ ក្នុងករណីណាមួយ ដែលមានរយៈពេលខ្លី) តាមតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុនោះ ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ក្រុមហ៊ុនធ្វើការប៉ាន់ស្មានលើលំហូរទឹកប្រាក់នាពេលអនាគតដោយពិចារណារាល់លក្ខខណ្ឌទាំងអស់របស់កិច្ចសន្យាហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវ រំពឹងទុកលើការខាតបង់ឥណទាននោះទេ (ECL) ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព ។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែល ពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ។

### (ឃ) កម្រៃ និងជើងសារ

ចំណូល និងចំណាយកម្រៃ និងជើងសារ ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព ។

ចំណូលកម្រៃ និងជើងសារផ្សេងទៀត ត្រូវបានទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម ។ ប្រសិនបើ ឥណទានជាប់កិច្ចសន្យាមិនត្រូវបានគេរំពឹងថានឹងមានលទ្ធផលក្នុងការដកប្រាក់ឥណទាននោះ នៅពេលដែលថ្លៃកិច្ចសន្យាឥណទានភាគីពាក់ព័ន្ធត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានថេរក្នុងការិយបរិច្ឆេទកិច្ចសន្យា ។

ចំណាយកម្រៃផ្សេងៗ និងជើងសារពាក់ព័ន្ធយ៉ាងពិតប្រាកដទៅលើប្រតិបត្តិការ និង ថ្លៃសេវាកម្មដែលត្រូវបានចំណាយនៅពេលសេវាកម្មត្រូវបានទទួល ។

### (ង) ភតិសន្យា

ការទូទាត់លើភតិសន្យាត្រូវទទួលស្គាល់ក្នុងរបាយការណ៍ចំណេញឬខាតតាមមូលដ្ឋានថេរក្នុងអំឡុងពេល នៃភតិសន្យា ។ ការលើកទឹកចិត្តភតិសន្យាដែលបានទទួល ត្រូវទទួលស្គាល់ជាការរួមបញ្ចូលផ្នែកនៃការចំណាយភតិសន្យាសរុបក្នុងអំឡុងពេលនៃភតិសន្យា ។

### (ច) ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ វាត្រូវបានទទួលស្គាល់ជា ចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលលម្អិត លើកលែងតែធាតុណាបានទទួលស្គាល់ដោយផ្ទាល់ក្នុង មូលធន ឬនៅក្នុងរបាយការណ៍លម្អិតផ្សេងៗទៀត ។

#### (i) ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ រួមមានពន្ធដែលត្រូវបង់ឬទទួល លើប្រាក់ចំណេញ ឬខាតជាប់ពន្ធ ប្រចាំឆ្នាំនិងនិយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ ឬត្រូវទទួលពីការិយបរិច្ឆេទមុន ។ ចំនួនពន្ធលើប្រាក់ចំណេញដែលត្រូវបង់ឬត្រូវទទួល គឺជាការប៉ាន់ស្មានដ៏ល្អបំផុតនៃចំនួនពន្ធដែលរំពឹងថានឹងត្រូវទូទាត់ ឬ បានទទួលដែលបានបញ្ជាក់ពីភាពមិនប្រាកដប្រជាទាក់ទងនឹងពន្ធលើប្រាក់ចំណូលប្រសិនបើមាន ។ ការវាស់វែងដោយប្រើប្រាស់អត្រាពន្ធដែលបានអនុម័ត ជាធរមាននៅកាលបរិច្ឆេទនៃរបាយការណ៍ ។

#### (ii) ពន្ធពន្យារ

ពន្ធពន្យារត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្ដោះអាសន្នរវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវទទួលស្គាល់ចំពោះការខាតបង់ពន្ធមិនទាន់បានប្រើប្រាស់ឥណទានពន្ធ និងភាពលម្អៀងបណ្ដោះអាសន្នដែលអាចកាត់កងបាន ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត អាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្ដោះអាសន្ននោះបាន ។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវ

បានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន ។

ពន្ធពន្យារជាទ្រព្យសកម្មដែលមិនទទួលស្គាល់ ត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ហើយត្រូវបានកត់ត្រាក្នុងចំនួនដែលអាចនឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតអាចប្រើបាន ។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះអាសន្ននៅពេលដែលវាអាចប្រើប្រាស់បាន ឬកាត់កងបានដោយប្រើអត្រាពន្ធនៅកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងពន្ធពន្យារជាទ្រព្យសកម្ម ឆ្លុះបញ្ចាំងនូវពន្ធដែលក្រុមហ៊ុនរំពឹងនៅកាលបរិច្ឆេទរាយការណ៍ថាអាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល ។

### (ឆ) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

#### (i) ការទទួលស្គាល់

ក្រុមហ៊ុនទទួលស្គាល់ជាលើកដំបូងលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុនៅពេលដែលក្រុមហ៊ុនក្លាយជាភាគីកិច្ចសន្យា ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្របបូកនឹងថ្លៃដើមប្រតិបត្តិការ ដែលកើតមកពីការទិញ ឬលក់ ទ្រព្យ និងបំណុលទាំងនោះ ។

#### (ii) ការចាត់ចំណាត់ថ្នាក់

ក្រុមហ៊ុនចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ជាឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន ស្របទៅតាមផ្នែកទី 11 ឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន ។

#### (iii) ការឈប់ទទួលស្គាល់

ក្រុមហ៊ុនឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬបានទូទាត់ ឬការផ្ទេរសិទ្ធិទទួលលំហូរទឹកប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលហានិភ័យទាំងអស់ និងភាពជាកម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលក្រុមហ៊ុនមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាកម្មសិទ្ធិ ហើយវាមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ។

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលាយ ឬលុបចោល ឬផុតអាណត្តិ ។

#### (iv) ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចត្រូវកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែក្រុមហ៊ុនមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា ។

#### (v) ការវាស់វែងតាមរំលស់ថ្លៃដើម

រំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងនៅពេលទទួលស្គាល់ជាលើកដំបូង ដកការទូទាត់ប្រាក់ដើម និង បូក ឬដករំលស់បង្គរដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៃភាពខុសគ្នារវាងចំនួនទឹកប្រាក់ដែលបានទទួល ស្គាល់ដំបូង និងចំនួនទឹកប្រាក់ដល់កាលកំណត់ ដកឱនភាពនៃតម្លៃ ។

#### (vi) ការវាស់វែងតម្លៃសមស្រប

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារនាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោលគឺយកទីផ្សារដែលមានអត្ថប្រយោជន៍បំផុត ដែលក្រុមហ៊ុនអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យនៃការមិនអនុវត្តកាតព្វកិច្ច ។

ក្រុមហ៊ុនវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន ។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជា ទៀងទាត់ ។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះក្រុមហ៊ុនត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន ។





បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ ។

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយនៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅគឺជាតម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឲ្យ ឬបានទទួល ។ ប្រសិនបើក្រុមហ៊ុនកំណត់ថាតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃដោយប្រើប្រាស់ទិន្នន័យទីផ្សារដែលអាចអង្កេតបាន ត្រូវបានសន្មតថាមិនសារវន្តដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ ។ បន្ទាប់មកទៀត ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់ជាចំណេញ ឬខាត ផ្អែកលើអាយុកាលរបស់ឧបករណ៍នោះក៏ប៉ុន្តែមិនឲ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ ។

ក្រុមហ៊ុនទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្របនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង ។

#### (vii) ការកំណត់អត្តសញ្ញាណ និងការវាស់វែងឱនភាពនៃតម្លៃ

##### ភស្តុតាងដែលបញ្ជាក់ថាមានឱនភាពនៃតម្លៃ

នៅកាលបរិច្ឆេទរបាយការណ៍ នីមួយៗ ក្រុមហ៊ុនបានវាយតម្លៃថាតើមានភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកត់ត្រាតាមថ្លៃដើម ឬទេ ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ នៅពេលដែលភស្តុតាងបញ្ជាក់ថា មានការខាតបង់ព្រឹត្តិការការណ៍មួយ ឬច្រើនបានកើតឡើងបន្ទាប់ពីការទទួលស្គាល់ទ្រព្យសកម្ម លើកដំបូងហើយដែលនាំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរទឹកប្រាក់នាពេលអនាគត នៃទ្រព្យសកម្មដែលអាចប៉ាន់ស្មានដោយភាពជឿជាក់បាន ។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃរួមមាន៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការខកខានមិនបានសង ឬហួសកាលកំណត់របស់អតិថិជន
- ការរៀបចំឡើងវិញលើលក្ខខណ្ឌទូទាត់សង ដែលក្រុមហ៊ុនមិនបានរំពឹងទុក
- សញ្ញាណដែលបញ្ជាក់ថាអតិថិជន ឬ អ្នកបោះផ្សាយទំនងនឹងជួបប្រទះការក្ស័យធន
- ការបាត់បង់ទីផ្សារសកម្ម សម្រាប់ទ្រព្យបញ្ចាំ ឬ
- ទិន្នន័យដែលអាចអង្កេតបានពាក់ព័ន្ធនឹងក្រុមនៃទ្រព្យសកម្ម ដូចជាការផ្លាស់ប្តូរអវិជ្ជមាននៃស្ថានភាពនៃការទូទាត់របស់អ្នកខ្ចីឬអ្នកបោះផ្សាយជាក្រុម ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលទាក់ទងនឹងការខកខានមិនបានសងជាក្រុម ។

##### ការវាយតម្លៃជាលក្ខណៈទោល និងជាក្រុម

រាល់ទ្រព្យសកម្មជាសារវន្ត ត្រូវបានវាយតម្លៃជាលក្ខណៈទោលសម្រាប់ឱនភាពនៃតម្លៃការវាយតម្លៃជាលក្ខណៈទោលដែលត្រូវបានរកឃើញថាមិនមានឱនភាពនៃតម្លៃ ជាពិសេសត្រូវបានវាយតម្លៃជាក្រុមសំរាប់ឱនភាពនៃតម្លៃដែលបានកើតឡើងប៉ុន្តែមិនទាន់កើតឡើងនៅឡើយទេ ។

សមាសធាតុទោលនៃសំវិធានធនសរុបសម្រាប់ឱនភាពនៃតម្លៃ ត្រូវបានអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាយតម្លៃជាលក្ខណៈទោលនៃឱនភាពនៃតម្លៃ ហើយត្រូវបានរកឃើញថាមានឱនភាពនៃតម្លៃទោល និងផ្អែកតាមការប៉ាន់ស្មានដ៏ប្រសើរបំផុតរបស់អ្នកគ្រប់គ្រង លើតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលរំពឹងថានឹងទទួលបាន ។ ក្នុងការប៉ាន់ស្មានលំហូរទឹកប្រាក់ទាំងនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យអំពីស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុល និងតម្លៃសុទ្ធដែលអាចលក់បានចំពោះទ្រព្យបញ្ចាំណាមួយ ។ ទ្រព្យសកម្មដែលមានឱនភាពនៃតម្លៃនីមួយៗត្រូវបានវាយតម្លៃលើគុណសម្បត្តិរបស់វា ហើយយុទ្ធសាស្ត្រគណនា និងការប៉ាន់ស្មានលំហូរទឹកប្រាក់ដែលអាចប្រមូលបានមកវិញ ត្រូវបានអនុម័តឯករាជ្យដោយអ្នកគ្រប់គ្រង ។

សមាសធាតុរួមនៃឱនភាពនៃតម្លៃត្រូវបានបង្កើតឡើងសម្រាប់៖

- ជាក្រុមនៃភតិសន្យាត្រូវទទួល មានលក្ខណៈដូចគ្នា ដែលមិនត្រូវបានចាត់ទុកថាជាលក្ខណៈទោលសារវន្ត និង
- ក្រុមនៃទ្រព្យសកម្មដែលមានលក្ខណៈទោលជាសារវន្ត ប៉ុន្តែមិនត្រូវបានរកឃើញថាមានឱនភាពនៃតម្លៃទោលនោះ ។

## ២៧.គោលនយោបាយគណនេយ្យសំខាន់។

សំវិធានធនជាក្រុម សម្រាប់ក្រុមនៃភតិសន្យាត្រូវទទួលមានលក្ខណៈដូចគ្នា ត្រូវ បានបង្កើតឡើងដោយប្រើវិធីសាស្ត្រស្ថិតិ ដូចជាវិធីសាស្ត្រអត្រាវិល ឬសម្រាប់ផលប័ត្រតូចៗ ដែលមិនមានព័ត៌មានគ្រប់គ្រាន់ វិធីសាស្ត្រផ្អែកលើបទពិសោធន៍អត្រាបាត់បង់ប្រវត្តិសាស្ត្រ ។

ក្នុងការវាយតម្លៃសំវិធានធនលើខាតបង់ជាក្រុម អ្នកគ្រប់គ្រងបានពិចារណាលើកត្តាមួយចំនួនដូចជាគុណភាព ឥណទាន ទំហំផលប័ត្រ ការប្រមូលផ្តុំ និងកត្តាសេដ្ឋកិច្ចជាដើម ។ ដើម្បីប៉ាន់ប្រមាណនូវតម្រូវការសំវិធានធន ការសន្មតត្រូវបានធ្វើឡើងដើម្បីកំណត់ពីលក្ខណៈនៃការខាតបង់ ដែលត្រូវបានយកគំរូតាម និងការកំណត់ទិន្នន័យប៉ារ៉ាម៉ែត្រតាមតម្រូវការ ដោយផ្អែកលើបទពិសោធន៍ប្រវត្តិសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន ។ ភាពត្រឹមត្រូវនៃសំវិធានធនអាស្រ័យលើការសន្មតគំរូ និងប៉ារ៉ាម៉ែត្រដែលត្រូវបានប្រើក្នុងការកំណត់សំវិធានធនជាក្រុម ។

### ការវាស់វែង

ការខាតបង់លើឱនភាពនៃតម្លៃទៅលើទ្រព្យសកម្មដែលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ត្រូវបានគណនា ដោយភាពខុសគ្នារវាងតម្លៃយោង និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលបានប៉ានស្មាននាពេលអនាគតដែលត្រូវបានធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូងរបស់ទ្រព្យសកម្ម ។

### ការទទួលបានមកវិញ និងការលុបចោលឱនភាពនៃតម្លៃ

ប្រសិនបើ ក្នុងការិយបរិច្ឆេទបន្ទាប់ ចំនួនឱនភាពនៃតម្លៃមានការថយចុះ ហើយការថយចុះអាចទាក់ទងទៅ នឹងព្រឹត្តិការណ៍ដែលកើតឡើងបន្ទាប់ពីឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ ក្រុមហ៊ុនត្រូវធ្វើការកែប្រែលើការខាតបង់ឱនភាពនៃតម្លៃ ដែលបានទទួលស្គាល់ពីមុនដោយផ្ទាល់ ឬការធ្វើនិយ័តភាពចំពោះគណនី សំវិធានធន ។

ការទទួលបានមកវិញនូវឱនភាពនៃតម្លៃនឹងមិនបណ្តាលឲ្យមានតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ (គណនី សំវិធានធន) លើសពីចំនួនតម្លៃយោងដែលមានឱនភាពនៃតម្លៃដែលមិនបានទទួលស្គាល់ពីមុននោះទេ ។ ក្រុមហ៊ុនត្រូវទទួលស្គាល់ចំនួនទឹកប្រាក់ដែលទទួលបានមកវិញជាចំណេញ ឬខាតភ្លាមៗ ។

ក្រុមហ៊ុនធ្វើការលុបចោលឥណទាន ឬការវិនិយោគលើមូលបត្របំណុល ដោយផ្អែកឬក៏ទាំងស្រុង និងសំវិធានធនលើឱនភាពនៃតម្លៃ នៅពេលដែលអ្នកគ្រប់គ្រងកំណត់ថាមិនមានលទ្ធភាពជាក់លាក់ក្នុងការប្រមូលបានមកវិញ ។

### (ជ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យសាច់ប្រាក់ក្នុងធនាគារ ប្រាក់បញ្ញើ និងការវិនិយោគរយៈពេលខ្លី ដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល 3 ខែ ឬតិចជាង ដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរ តម្លៃហើយត្រូវបានប្រើដោយក្រុមហ៊ុនក្នុងការគ្រប់គ្រងកិច្ចសន្យារយៈពេលខ្លី ។

សាច់ប្រាក់ និងសាច់ប្រាក់សមមូលត្រូវបានគិតតាមរំលស់ថ្លៃដើមតាមរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

### (ឈ) ប្រាក់តម្កល់តាមច្បាប់

ប្រាក់តម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមារបស់ក្រុមហ៊ុន ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។

ប្រាក់តម្កល់តាមច្បាប់ មិនអាចយកមកប្រើប្រាស់ជាហិរញ្ញប្បទានសម្រាប់ ប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនឡើយ ដូច្នេះវាមិនត្រូវបានចាត់ទុកថាជាផ្នែកមួយនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល នៅក្នុងរបាយការណ៍លំហូរទឹកប្រាក់ឡើយ ។

ប្រាក់តម្កល់តាមច្បាប់ ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

### (ញ) ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន គឺជាទ្រព្យសកម្មហិរញ្ញវត្ថុអនិស្សន្ទដែលទូទាត់ប្រាក់ដែលមានកាលកំណត់ ឬកំណត់ដែលមិនត្រូវបានដកស្រង់នៅលើទីផ្សារសកម្ម ហើយក្រុមហ៊ុនមិនមានបំណងលក់ភ្លាមៗ ឬក្នុងរយៈពេលខ្លីនោះទេ ។

ឥណទានផ្តល់ដល់អតិថិជន ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្របបូករួមនឹងការចំណាយប្រតិបត្តិការ ដោយផ្ទាល់បន្ថែមហើយត្រូវបានវាស់វែងជាបន្តបន្ទាប់ដោយចំណាយរំលស់ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រកបដោយប្រសិទ្ធភាព ។




# របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

## ២៧.គោលនយោបាយគណនេយ្យសំខាន់។


### (ដ) ទ្រព្យសកម្មផ្សេងទៀត

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមរំលស់តម្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

### (ឋ) ទ្រព្យ និងបរិក្ខារ

(i) ផ្នែកនៃទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរនិងការខាតបង់លើឱនភាពនៃតម្លៃ បង្គរ ប្រសិនបើមាន ។ នៅពេលដែលផ្នែកនៃទ្រព្យ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ផ្នែកទាំងនោះត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នា សមាសធាតុចម្បងៗ នៃទ្រព្យ និងបរិក្ខារ ។

(ii) រំលស់លើទ្រព្យ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍ចំណេញ ឬខាត ដោយផ្អែកលើមូលដ្ឋានរំលស់ថេរ ទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យ និងបរិក្ខារ នីមួយៗ ដូចខាងក្រោម៖

| | អាយុកាល | វិធីសាស្ត្រ |
|---|---|---|
| ការកែលំអទ្រព្យជួល | ៥ ឆ្នាំ | រំលស់ថេរ |
| យានយន្ត | ៥ ឆ្នាំ | រំលស់ថេរ |
| បរិក្ខា ការិយាល័យ | ៤ ឆ្នាំ | រំលស់ថេរ |
| កុំព្យូទ័រ និងបរិក្ខារពត៌មានវិទ្យា | ៤ ឆ្នាំ | រំលស់ថេរ |
| គ្រឿងសង្ហារឹមនិងគ្រឿងបំពាក់ | ៤ ឆ្នាំ | រំលស់ថេរ |

នៅក្នុងការិយបរិច្ឆេទ ក្រុមហ៊ុនបានកែតម្រូវការប៉ាន់ស្មានអាយុកាលប្រើប្រាស់នៃការការកែលំអទ្រព្យជួល និងយានយន្ត ពី ៤ ឆ្នាំទៅ ៥ ឆ្នាំដើម្បីឆ្លុះបញ្ចាំងឱ្យកាន់តែត្រឹមត្រូវអំពីអាយុកាលប្រើប្រាស់នៃទ្រព្យទាំងនេះ ។ ការកែប្រែនេះមានសុពលភាពចាប់ពីថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០២០ និងធ្វើឲ្យមានការថយចុះនូវការចំណាយរំលស់ ចំនួន ៣,៤៨៨ ដុល្លារអាមេរិក សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០។ ការកែប្រែត្រូវបានអនុវត្តពីថ្ងៃកែប្រែតទៅមុខ ។

(iii) ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុនលើសពីស្តង់ដារដើម ។ រាល់ការចំណាយបន្ទាប់ផ្សេងៗទៀតត្រូវបាន ទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

(iv) ចំណេញ ឬខាតពីការឈប់ប្រើ ឬការលក់ចេញផ្នែកនៃទ្រព្យ និងបរិក្ខារណាមួយ ត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបាន ពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍លទ្ធផលនាថ្ងៃឈប់ប្រើ ឬលក់ចេញ ។

(v) ទ្រព្យ និងបរិក្ខារ ដែលបានដករំលស់អស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ពេលដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ចេញ ឬលុបចោល ។

### (ឌ) ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានសូហ្វវែរដែលរួមបញ្ចូលទាំងថ្លៃដើមក្នុងការទិញ និងដំឡើងសូហ្វវែរ ដែលមិនមែនជាជាធាតុនៃផ្នែករឹង ហើយត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន ។ ថ្លៃដើមសូហ្វវែរត្រូវបានដករំលស់ទៅតាមការប៉ាន់ស្មានអាយុកាលប្រើប្រាស់ ៤ ឆ្នាំ តាមវិធីសាស្ត្ររំលស់ថេរ ។

នៅក្នុងការិយបរិច្ឆេទ ក្រុមហ៊ុនបានកែតម្រូវការប៉ាន់ស្មានអាយុកាលប្រើ ប្រាស់ពី ៤ ឆ្នាំទៅ ៥ ឆ្នាំដើម្បីឆ្លុះបញ្ចាំងឲ្យកាន់តែត្រឹមត្រូវអំពីអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មអរូបី ។ ការកែប្រែនេះមានសុពលភាពចាប់ពីថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០២០ និងធ្វើឲ្យមានការថយចុះនូវចំណាយរំលស់ចំនួន ១,៥៥៥ដុល្លារអាមេរិក សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ។ ការកែប្រែត្រូវបានអនុវត្តពីថ្ងៃកែប្រែតទៅមុខ។

ការចំណាយដែលបានកើតឡើងនៅក្នុងការធ្វើផែនការឬវាយតម្លៃកម្មវិធីសូហ្វវែរ ឬការថែរក្សាប្រព័ន្ធបន្ទាប់ពីបានដាក់ឲ្យប្រើប្រាស់ មិនមែនមូលធនីយកម្មទេ ។

### (ឍ) ឱនភាពនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទ របាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមាន ឱនភាពនៃតម្លៃ ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបាន មកវិញរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង ។

## ២៧.គោលនយោបាយគណនេយ្យសំខាន់។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់សាច់ប្រាក់រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្នដោយប្រើអត្រាការប្រាក់ មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ សម្រាប់ទ្រព្យសកម្មទាំងនោះ ។ សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមដែល អាចបង្កើតសាច់ប្រាក់បានតូចបំផុតពីការបន្តការ ប្រើប្រាស់ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត ហៅកាត់ថា ("ឯកតាបង្កើតសាច់ប្រាក់") ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្មមួយ ឬឯកតា បង្កើតសាច់ប្រាក់ មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកបានវិញ ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ។

### (ណ) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែល ជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលា ក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ ។ អប្បហារនៅសល់ត្រូវបានទទួលស្គាល់ជាថ្លៃដើមហិរញ្ញវត្ថុ ។

### (ត) ប្រាក់កម្ចី និងបំណុលផ្សេងៗ

ប្រាក់កម្ចី និងបំណុលផ្សេងៗត្រូវបានគិតតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

### (ថ) អត្ថប្រយោជន៍និយោជិត

#### (i) អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លីត្រូវបានចំណាយ នៅពេលដែលសេវាកម្មត្រូវបានផ្ដល់ជូន ។ ចំនួនដែលរំពឹងទុកថានឹងត្រូវចំណាយ ត្រូវបានទទួលស្គាល់ជាបំណុល ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ក្នុងការទូទាត់ចំណាយ ដោយជាលទ្ធផលនៃការងារដែលបានបំពេញរួចមកហើយដោយបុគ្គលិក ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មានបាន ។

#### (ii) អត្ថប្រយោជន៍និយោជិតរយៈពេលវែងដទៃទៀត

កាតព្វកិច្ចសុទ្ធរបស់ក្រុមហ៊ុន ទាក់ទងនឹងអត្ថប្រយោជន៍រយៈពេលវែងរបស់និយោជិតគឺចំនួនទឹកប្រាក់នៃ អត្ថប្រយោជន៍ដែលនិយោជិតទទួលបានពីការផ្ដល់សេវាកម្មរបស់ខ្លួន ក្នុងអំឡុងពេលបច្ចុប្បន្ន និងរយៈពេល មុនៗ ។ អត្ថប្រយោជន៍នេះ ត្រូវបានធ្វើអប្បហារដើម្បីកំណត់តម្លៃបច្ចុប្បន្ន ។ ការវាស់វែងឡើងវិញត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលក្នុងអំឡុងពេលដែលបានកើតឡើង ។

### (ទ) ដើមទុន

ថ្លៃដើមកើនឡើងបណ្ដាលមកពីការបោះប័ណ្ណភាគហ៊ុនធម្មតាទៅឲ្យអ្នកកាន់កាប់ហ៊ុន ត្រូវបានទទួលស្គាល់ជាការកាត់កងពីមូលធន ។

### (ធ) ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទបញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នារវាងសំវិធានធនលើ ឱនភាពឥណទានតាម ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូចនិងមធ្យម និងសំវិធានធនតាមបទបញ្ញត្តិស្របតាមប្រកាស របស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៧ និងសារាចរណែនាំលេខ ធ ៧-០១៨-០០១ ស.រ.ឆ.ណ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស្ដីពីចំណាត់ថ្នាក់ហានិភ័យឥណទាននិងសំវិធានធនលើឱនភាពនៃតម្លៃសម្រាប់គ្រឹះស្ថានធនាគារនិងស្ថាប័នហិរញ្ញវត្ថុ ។

យោងតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា រាល់ឥណទាននិងអស់របស់អតិថិជនត្រូវធ្វើចំណាត់ថ្នាក់ទៅតាមសមត្ថភាពសងរបស់អ្នកខ្ចី និងចំនួនថ្ងៃដែលហួសកំណត់ដូចខាងក្រោម៖



របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២០

២៧.គោលនយោបាយគណនេយ្យសំខាន់។

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| ឥណទានរយៈពេលខ្លី | (តិចជាង ឬស្មើរមួយឆ្នាំ)៖ | |
| ឥណទានធម្មតា/ស្តង់ដារ | <១៥ ថ្ងៃ | ១% |
| ឥណទានឃ្លាំមើល | ១៥ ថ្ងៃ ដល់ ៣០ ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ៣១ ថ្ងៃ ដល់ ៦០ ថ្ងៃ | ២០% |
| ឥណទានជាប់សង្ស័យ | ៦១ ថ្ងៃ ដល់ ៩០ ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | ≥ ៩១ ថ្ងៃ | ១០០% |
| ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)៖ | | |
| ឥណទានធម្មតា | < ៣០ ថ្ងៃ | ១% |
| ឥណទានឃ្លាំមើល | > ៣០ថ្ងៃ ដល់ ៨៩ ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ≥ ៩០ថ្ងៃ ដល់ ១៧៩ ថ្ងៃ | ២០% |
| ឥណទានជាប់សង្ស័យ | ≥ ១៨០ថ្ងៃ ដល់ ៣៥៩ ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | ៣៥៩ថ្ងៃឬ ច្រើនជាងនេះ | ១០០% |

អនុលោមតាមប្រការ ៧៣ គ្រឹះស្ថានត្រូវប្រៀបធៀបសំវិធានធន ដែលគណនាតាមតម្រូវការខាងលើ ជាមួយនឹងសំវិធានធនដែលគណនាតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម៖

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិទាបជាង នោះក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាស ធុនតូច និងមធ្យម ឬ

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិខ្ពស់ជាង នោះក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុក ឬប្រាក់ខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងមូលធន នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

## ២៨. ព្រឹត្តិការណ៍សំខាន់

រហូតមកដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ កូវីដ-១៩ពុំទាន់មានផលប៉ះពាល់ជាសារវន្តណាមួយចំពោះក្រុមហ៊ុនទេ។ ពាក់ព័ន្ធនឹងការវិវឌ្ឍន៍ និងការរីករាលដាលនៃ កូវីដ-១៩បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍នេះ ការប្រែប្រួលបន្ថែមទាក់ទិននឹងលក្ខខណ្ឌសេដ្ឋកិច្ចសម្រាប់ក្រុមហ៊ុនដែលកើតមានឡើង អាចនឹងមានផលប៉ះពាល់លើលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្នុងកម្រិតមួយដែលពុំអាចវាស់វែងបាននាកាលបរិច្ឆេទនៃ របាយការណ៍នេះ។ ក្រុមហ៊ុននឹងរក្សាការតាមដានជាប្រចាំអំពីស្ថានភាពនៃកូវីដ-១៩និងធ្វើការឆ្លើយតបយ៉ាងសកម្មចំពោះផលប៉ះពាល់លើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន។





# សកម្មភាពសង្គមនិង ទំនួលខុសត្រូវសង្គម

- ការរួមចំណែកក្នុងទំនួលខុសត្រូវសង្គម
- ការទទួលបានវ៉ាក់សាំង( កូវីដ១៩ )
  នៃគណៈគ្រប់គ្រង និងបុគ្គលិកហ្វូណាន
- សកម្មភាព និងសុខមាលភាពបុគ្គលិក





## ការរួមចំណែកក្នុងទំនួលខុសត្រូវសង្គម

### ការផ្តល់វិភាគទានដល់ មន្ទីរពេទ្យគន្ធបុប្ផា

កម្មវិធី ជំនួយដល់មន្ទីរពេទ្យគន្ធបុប្ផា ជាគំនិតផ្តួចផ្តើមរបស់ អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ ដែលបាននឹងកំពុងអនុវត្តរយៈពេល ៣ឆ្នាំមកហើយ ពោលគឺចាប់តាំងពីឆ្នាំ២០១៨មក។

ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី និងក្រុមហ៊ុនផ្សេងៗជាច្រើនទៀតដែលជាសម្ព័ន្ធនៃ ក្រុមហ៊ុនវិនិយោគកាលណាឌីយ៉ា បានចូលរួមចំណែកក្នុងការធ្វើវិភាគទានដល់មន្ទីរពេទ្យគន្ធបុប្ផា ជាប្រចាំខែ ដើម្បីរួមចំណែកអោយមន្ទីរពេទ្យមួយនេះអាចបន្តបេសកកម្មរបស់ខ្លួនក្នុងការបន្តជួយសង្គ្រោះកុមារកម្ពុជា។ ទឹកប្រាក់វិភាគទានមានចំនួន១,២៥ដុល្លារអាមេរិក គណនាទៅនឹងចំនួនបុគ្គលិករបស់គ្រឹះស្ថាន។ ក្នុងនោះបុគ្គលិករបស់ហ្វូណនក៏បានចូលរួមចំណែក ៤០ភាគរយនៃវិភាគទាននេះផងដែរ។

### ការផ្តល់ការការពារកម្ចីជាមួយធានារ៉ាប់រងជីវិត

ដោយអតិថិជនមានប្រាក់ចំណូលទាប ងាយទទួលរងនូវហានិភ័យនិងងាយរងគ្រោះ ជាពិសេសនៅពេលដែលអ្នករកចំនូលចំបងទទួលមរណៈភាព។ ដូច្នោះកត្តព្វកិច្ចបំណុលនឹងធ្លាក់ទៅឱ្យក្រុមគ្រួសាររបស់ពួកគាត់ជាមិនខាន ហើយអាចនឹងបង្ករផល់វិបាក សម្រាប់កូនៗរបស់ពួកគាត់ទៀតផង។ ជាគ្រឹះស្ថានដែលតែងតែគិតដល់សុខមាលៈភាពសង្គម ហ្វូណន ធ្វើការផ្តល់អត្ថប្រយោជន៍បន្ថែមដល់អតិថិជន ជាពិសេសអតិថិជនដែលកំពុងប្រើប្រាស់កម្ចីខ្នាត់តូចជាមួយគ្រឹះស្ថាន ពោលគឺពួកគាត់ទទួលបាននូវការការពារកម្ចីជាមួយធានារ៉ាប់រងជីវិត។ ជាមួយនឹងការផ្តល់ជូននូវអត្ថប្រយោជន៍បន្ថែមនេះ ហ្វូណនធ្វើការចំនាយបុព្វលាភជូនអតិថិជនទៅឱ្យដៃគូរអាជីវកម្មរបស់ ហ្វូណនគឺក្រុមហ៊ុនធានារ៉ាបរងសុវណ្ណាភូមិឡាយ ហើយអតិថិជនទទួលបាននូវសងបំណុលជំនួសនៅពេលដែល អតិថិជនទទួលមរណៈភាព។ ក្នុងឆ្នាំ២០២០ អតិថិជនជាង៥៨ភាគរយទទួលបានការការពារនេះ។

## សកម្មភាពទទួលបានវ៉ាក់សាំង(កូវីដ១៩) នៃគណៈគ្រប់គ្រង និងបុគ្គលិកហ្វូណន

### សកម្មភាពទទួលបានវ៉ាក់សាំង(កូវីដ១៩) នៃគណៈគ្រប់គ្រង និងបុគ្គលិកហ្វូណន

ជាមួយនឹងក្រុមហ៊ុនវិនិយោគកាលណាឌីយ៉ា បុគ្គលិកនិងគណៈគ្រប់គ្រងរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វូណន មានអទិភាពក្នុងការទទួលបានការចាក់វ៉ាក់សាំងកូវីដ១៩ ដូចក្រុមអទីភាពផ្សេងទៀត។ បុគ្គលិកជាងមួយរយនាក់របស់ហ្វូណន ពីការិយាល័យកណ្តាល និងសាខាក្នុងនិងជាយក្រុងទទួលបានឱកាសចាក់វ៉ាកសាំងកូវីដ១៩ ទាំងពីរលើក។ ការទទួលបានវ៉ាក់សាំងសម្រាប់បុគ្គលិក គឺជាផ្នែកមួយនៃនិរន្តភាពអាជីវកម្មរបស់យើង កាត់បន្ថយការរីករាលដាល ហើយបុគ្គលិកមានសុវត្ថិភាពក្នុងការបំពេញការងារប្រចាំថ្ងៃរបស់ខ្លួន។ សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល និងលោកប្រធានក្រុមប្រឹក្សាភិបាល នៃហ្វូណនមីក្រូហិរញ្ញវត្ថុ សម្រាប់ឱកាសក្នុងការទទួលបានវ៉ាកសាំងនេះ។

# សកម្មភាព និងសុខមាលភាពបុគ្គលិក



















សកម្មភាពកីឡា








មហាសន្និបាតឆ្នាំ ២០២០

# សកម្មភាព និងសុខមាលភាពបុគ្គលិក








## ការផ្សព្វផ្សាយផលិតផលសេវាកម្ម








## សុខុមាលភាពបុគ្គលិក









អំណោយពីហ្វូណនដល់អតិថិជនដែលរងផលប៉ះពាល់






អត្តសញ្ញាណថ្មីរបស់ហ្វូណន













សកម្មភាពបណ្តុះបណ្តាល



# សាខាឆ្នើម និងតំបន់ប្រតិបត្តិការ

- សាខាឆ្នើម និងបុគ្គលិកនាំមុខ
- ទីតាំងការិយាល័យ និងតំបន់ប្រតិបត្តិការ

# សាខាឆ្នើមប្រចាំឆ្នាំ ២០២០



1

សាខាកំពង់ឆ្នាំង



2

សាខាបរសេដ្ឋ



3

សាខាកំពង់ត្រឡាច



4

សាខាស្ទឹងត្រង់



5

សាខាស្រីសន្ធរ

# កម្មវិធីមន្ត្រីឥណទានឆ្នើម

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វូណន បានរៀបចំកម្មវិធីផ្តល់រង្វាន់មន្ត្រីឥណទានប្រចាំឆ្នាំ ដល់មន្ត្រីឥណទានចំនួន១០នាក់ ដែលជាជ័យលាភីមកពី៩សាខាក្នុងចំណោមសាខាទាំង៥១របស់គ្រឹះស្ថាន ក្រោមអធិបតីភាពរបស់លោកប្រធាននាយកប្រតិបត្តិ និងគណៈគ្រប់គ្រងនៃការិយាល័យកណ្តាល។













# ទីតាំងការិយាល័យ និងតំបន់ប្រតិបត្តិការ

### ការិយាល័យកណ្ដាល
អគារលេខ៩៥ មហាវិថីព្រះមុនីវង្ស កែងផ្លូវ១១៨ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។
០៦៩ ៦៩ ២២២២ br0002@funan.com.kh

### សាខាស្រុកកៀនស្វាយ
ផ្លូវជាតិលេខ១ ភូមិភូមិធំ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។
០៨៧ ៤៩ ៦៦៦៦ br0003@funan.com.kh

### សាខាស្រុកបាធាយ
ផ្លូវជាតិលេខ៦ ភូមិផ្អាវ ឃុំផ្អាវ ស្រុកបាធាយ ខេត្តកំពង់ចាម។
០៦៩ ៥៣ ៨៨៨៨ br0004@funan.com.kh

### សាខាស្រុកបរសេដ្ឋ
ផ្ទះលេខ២៦AB ក្រុមទី២ ភូមិត្រពាំងខ្សុង ឃុំទួលអំពិល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។
០៦៩ ៥២ ៨៨៨៨ br0005@funan.com.kh

### សាខាស្រុកខ្សាច់កណ្ដាល
ផ្លូវជាតិលេខ៨ ភូមិព្រែកតាមាក់ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។
០៦៩ ៨៨៨៨ ៥៧ br0006@funan.com.kh

### សាខាខេត្តតាកែវ
ផ្ទះលេខ៩០ ផ្លូវជាតិលេខ២ ភូមិឡូរី សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ។
០៦៩ ៩២ ៨៨៨៨ br0007@funan.com.kh

### សាខាស្រុកបារាយណ៍
ផ្ទះលេខ១៦៨ ផ្លូវជាតិលេខ៦ ភូមិព្រៃតាត្រាវ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។
០៦៩ ៣៧ ៨៨៨៨ br0008@funan.com.kh

### សាខាស្រុកកំពង់ត្រឡាច
ផ្លូវជាតិលេខ៥ ភូមិប្រកមៀត ឃុំអូរឫស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។
០៦៩ ៣២ ៨៨៨៨ br0009@funan.com.kh

### សាខាស្រុកស្វាយអន្ទរ
ភូមិស្វាយអន្ទរទី១ ឃុំស្វាយអន្ទរ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។
០៦៩ ៥៣ ៨៨៨៨ br0010@funan.com.kh

### សាខាខេត្តពោធិ៍សាត់
ផ្ទះលេខ១៤៨, ផ្លូវជាតិលេខ៥, ភូមិមាន់ចៃ, សង្កាត់ព្រៃញី,ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។
០៦៩ ៣១ ៨៨៨៨ br0011@funan.com.kh

### សាខាខេត្តកំពង់ចាម
ផ្ទះលេខ១៦៣ ភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម។
០៦៩ ២០ ៨៨៨៨ br0012@funan.com.kh

### សាខាខេត្តកំពត
ភូមិកំពង់បាយខាងជើង សង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត។
០៦៩ ៨៨៨៨ ៥៦ br0013@funan.com.kh

### សាខាខេត្តសៀមរាប
ផ្លូវជាតិលេខ៨ ភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។
០៦៩ ៥១ ៨៨៨៨ br0014@funan.com.kh

### សាខាខេត្តស្វាយរៀង
ភូមិចុងព្រែក សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង។
០១០ ៨៨៨៨ ៥១ br0015@funan.com.kh

### សាខាខេត្តមណ្ឌលគិរី
ផ្លូវជាតិលេខ៦៧ ភូមិអូរស្ពាន សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី។
០១០ ៨៨៨៨ ៥៤ br0016@funan.com.kh

### សាខាស្រុកបាទី
ផ្លូវជាតិលេខ២ ភូមិចក ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ។
០៦៩ ៨៨៨៨ ០២ br0017@funan.com.kh

### សាខាខេត្តកំពង់ស្ពឺ
ផ្ទះលេខ៥ ផ្លូវជាតិលេខ ៤ ភូមិមុខខេត្ត សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។
០១០ ៨៨៨៨ ៥២ br0018@funan.com.kh

### សាខាខេត្តកំពង់ឆ្នាំង
ផ្ទះលេខH៦ ផ្លូវជាតិលេខ៥ ក្រុមទី១ ភូមិខ្សាម សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។
០១០ ៨៨៨៨ ៦០ br0019@funan.com.kh

### សាខាស្រុកបន្ទាយមាស
ផ្លូវជាតិលេខ៣១ ភូមិព្រៃក្រឡាខាងលិច ឃុំទូកមាសខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត។
០១០ ៨៨៨៨ ៥០ br0020@funan.com.kh

### សាខាស្រុកគិរីវង់
ផ្លូវជាតិលេខ២ ភូមិកំពង់ថ្មី ឃុំព្រះបាទជាន់ជុំ ស្រុកគីរីវង់ ខេត្តតាកែវ។
០១០ ៨៨៨៨ ៤៩ br0021@funan.com.kh

### សាខាខេត្តកំពង់ធំ
ផ្លូវជាតិលេខ៦ ភូមិក្ដី សង្កាត់ព្រៃតាហ៊ូ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។
០១០ ៨៨៨៨ ៥៦ br0022@funan.com.kh

### សាខាស្រុកព្រៃឈរ
ផ្លូវជាតិលេខ៧ ភូមិដូនដី ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។
០១០ ៨៨៨៨ ៥៧ br0023@funan.com.kh

### សាខាស្រុកឆ្លូង
ភូមិជ្រោយថ្មក្រោម ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ។
០១០ ៨៨៨៨ ៦៥ br0024@funan.com.kh

### សាខាស្រុកព្រែកប្បាស
ភូមិល្វាត្នោត ឃុំព្រៃល្វា ស្រុកព្រែកប្បាស ខេត្តតាកែវ។
០១០ ៨៨៨៨ ៦៧ br0025@funan.com.kh

### សាខាស្រុកពញាក្រែក
ផ្លូវជាតិលេខ៨ ភូមិពោធិ៍ស្រុក ឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។
០១០ ៨៨៨៨ ៦១ br0026@funan.com.kh

### សាខាស្រុកម៉ោងឫស្សី
ផ្លូវជាតិលេខ៥ ភូមិរាមគន់ ឃុំគៀរ ស្រុកមោងឫស្សី ខេត្តបាត់ដំបង។
០១០ ៨៨៨៨ ៥៩ br0027@funan.com.kh

### សាខាស្រុកក្រឡាញ់
ផ្លូវជាតិលេខ៦A ភូមិកំពង់ថ្ម២ ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប។
០១០ ៨៨៨៨ ៦៣ br0028@funan.com.kh

### សាខាស្រុកស្ទឹងត្រង់
ផ្លូវលេខ៥៧ ភូមិត្នោតតាសាយ ឃុំព្រែកកក់ ក្រុងស្ទឹងត្រង់ ខេត្តកំពង់ចាម។
០១០ ៨៨៨៨ ០៤ br0029@funan.com.kh

### សាខាស្រុកឈូក
ផ្លូវជាតិលេខ៣ ភូមិសត្វពង ឃុំសត្វពង ស្រុកឈូក ខេត្តកំពត។
០១០ ៨៨៨៨ ០២ br0030@funan.com.kh

### សាខាមង្គលបូរី
ផ្លូវជាតិលេខ៥ ភូមិចំការតាដោក ឃុំក្រោក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។
០១០ ៨៨៨៨ ១៤ br0031@funan.com.kh

### សាខាខេត្តបាត់ដំបង
ផ្លូវជាតិលេខ៥ ភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។
០១០ ៨៨៨៨ ១៩ br0032@funan.com.kh

### សាខាបវេល
ភូមិស្ពានកណ្ដាល ឃុំបវេល ស្រុកបវេល ខេត្តបាត់តំបង។
០១០ ៨៨៨៨ ៣៤ br0033@funan.com.kh

### សាខាស្រុកព្រៃនប់
ផ្លូវជាតិលេខ៤ ភូមិសំរុងក្រោម ឃុំសំរុង ស្រុកព្រៃនប់ ខេត្ត ព្រះសីហនុ។
០១០ ៨៨៨៨ ៩៤ br0034@funan.com.kh

### សាខាស្រុកត្រាំកក់
ផ្លូវជាតិលេខ២៥ ភូមិអង្គតាសោម ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ។
០១០ ៨៨៨៨ ៣៧ br0035@funan.com.kh

### សាខាខណ្ឌដង្កោ
ផ្លូវជាតិលេខ៣ ភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានី ភ្នំពេញ។
០១០ ៨៨៨៨ ៤០ br0036@funan.com.kh

### សាខាស្រុកកំពង់ត្របែក
ផ្លូវជាតិលេខ១ ភូមិចំបក់ ឃុំប្រាសាទ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
០១០ ៨៨៨៨ ១២ br0037@funan.com.kh

### សាខាខេត្តព្រះវិហារ
ភូមិអណ្ដូងពោធិ៍ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ។
០១០ ៨៨៨៨ ៧០ br0038@funan.com.kh

### សាខាស្រុកស្រីសន្ធរ
ភូមិរកាទ្វារ ឃុំព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។
០១០ ៨៨៨៨ ៤២ br0039@funan.com.kh

### សាខាស្រុកបាកាន
ផ្លូវជាតិលេខ៥ ភូមិអូរតាប៉ោង ឃុំអូរតាប៉ោង ស្រុកបាកាន ខេត្តពោធិ៍សាត់។
០១០ ៨៨៨៨ ៧១ br0040@funan.com.kh

### សាខាស្រុកពញាឮ
ផ្លូវជាតិលេខ៥ ភូមិធម្មត្រ័យ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល។
០៨១ ៨៨៨៨ ០៤ br0041@funan.com.kh

### សាខាស្រុកជីក្រែង
ផ្លូវជាតិលេខ៦ ក្រុមទី៦ ភូមិអន្លង់វិល ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប។
០១០ ៨៨៨៨ ៤១ br0042@funan.com.kh

### សាខាខេត្តក្រចេះ
ភូមិផ្សារវែង សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ។
០៨១ ៨៨៨៨ ៦៤ br0043@funan.com.kh

### សាខាស្រុកស្នួល
ភូមិក្បាលស្នួល ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ។
០៨១ ៨៨៨៨ ២០ br0044@funan.com.kh

### សាខាខេត្តស្ទឹងត្រែង
ផ្លូវលេខ៥៧ ភូមិកណ្ដាល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។
០៦៩ ៩៤ ១១១១ br0045@funan.com.kh

### សាខាខេត្តរតនគិរី
ភូមិជ័យជំនះ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។
០៦៩ ២០ ១១១១ br0046@funan.com.kh

### សាខាស្រុកសូទ្រនិគម
ផ្លូវជាតិលេខ៦ ភូមិដំដែកថ្មី ឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប។
០៦៩ ៨៦ ១១១១ br0047@funan.com.kh

### សាខាស្រុកក្រគរ
ផ្លូវជាតិលេខ៥ ភូមិសំរោង ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់។
០៦៩ ៨៥ ១១១១ br0048@funan.com.kh

### សាខាស្រុកស្ទោង
ផ្លូវជាតិលេខ៦ ភូមិកំពង់ក្ដី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ។
០៦៩ ៣៤ ១១១១ br0049@funan.com.kh

### សាខាស្រុកកោះធំ
ផ្លូវជាតិលេខ២១ ភូមិព្រែកថ្មី ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្ដាល។
០៦៩ ៨៤ ១១១១ br0050@funan.com.kh

### សាខាខេត្តព្រះសីហនុ
ភូមិ៣ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។
០៨៧ ៤០ ៣៣៣៣ br0051@funan.com.kh

### សាខាពោធិ៍សែនជ័យ
ផ្លូវលេខ៤ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោសែនជ័យ រាជធានីភ្នំពេញ។
០៩៦ ៤៤៤៤ ៩៨៥ br0052@funan.com.kh




www.funan.com.kh

@FUNAN Microfinance Plc

@FunanMFI

គ្រឹះស្ថាន ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

អគារលេខ៩៥ មហាវិថីព្រះមុនីវង្ស កែងផ្លូវ១១៨
សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

០២៣ ៨៨៨៨ ៣០
០៩៣ ៥០ ៨៨៨៨
info@funan.com.kh